ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិ
# ស្តីពី
# ការអភិវឌ្ឍបៃតង
# ឆ្នាំ២០១៣-២០៣០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុង

សម័យប្រជុំពេញអង្គនាថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣

**រៀបចំដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង**

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង

ក្រសួងបរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិ
# ស្តីពី
# ការអភិវឌ្ឍបៃតង
# ឆ្នាំ២០១៣ - ២០៣០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣
**រៀបចំដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# សារលិខិត

## របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## គាំទ្រគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍបៃតង
## និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្ដែងនូវសេចក្ដីសោមនស្សរីករាយជូនចំពោះជនរួមជាតិទាំងអស់ជាទីស្នេហា អំពីការប្ដេជ្ញាចិត្តនិងការគាំទ្រលើ **គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍបៃតងនិងផែនការយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០**។ ជាក់ស្ដែង ការអភិវឌ្ឍបៃតង គឺជាមធ្យោបាយគ្រឹះមួយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលនឹងត្រូវបញ្ជ្រាបចូលទៅក្នុងគោលនយោបាយនិងផែនការយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ហើយការអភិវឌ្ឍបៃតងនេះរួមចំណែកក្នុងការរក្សានូវកំណើនសេដ្ឋកិច្ចថេរ លើកកម្ពស់គុណភាពបរិស្ថាន និងកាត់បន្ថយភាពក្រីក្រ។

តាមសេចក្ដីសម្រេចឆ្នាំ២០១២ របស់អង្គការសហប្រជាជាតិស្ដីពី "**អនាគតដែលយើងចង់បាន**" ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការចូលរួមចំណែកថែរក្សានិងការពារភពផែនដីឲ្យមាននិរន្តរភាពសម្រាប់អ្នកជំនាន់ក្រោយ។ ផ្អែកលើលទ្ធផលនិងបទពិសោធដ៏ជោគជ័យបំផុតនៃការអនុវត្តគោលនយោបាយឈ្នះ ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល បានស្ដែងចេញនូវការអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយមានតុល្យភាពជាមួយនឹងកិច្ចការពារបរិស្ថាន ការពារប្រព័ន្ធអេកូឡូស៊ី ការកាត់បន្ថយភាពក្រីក្រ ការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន និងការរក្សាបាននូវបេតិកភណ្ឌវប្បធម៌ជាតិ ដែលបានលើកកម្ពស់កិត្យានុភាពបៃតងជាតិល្បីល្បាញរន្ទឺជាប្រទេសមានការអភិវឌ្ឍបៃតងគំរូក្នុងតំបន់អាស៊ាន និងអាស៊ីប៉ាស៊ីហ្វិក។

ការអភិវឌ្ឍបៃតងផ្ដោតលើការអភិវឌ្ឍសេដ្ឋកិច្ចដើរទន្ទឹមនឹងការថែរក្សាធនធានធម្មជាតិនិងប្រព័ន្ធអេកូឡូស៊ីឲ្យមាននិរន្តរភាព ដោយយកវិស័យបរិស្ថានជាស្នូលក្នុងការអភិវឌ្ឍប្រទេសដែលជួយបង្កើនប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ប្រើប្រាស់ថាមពលកកើតឡើងវិញ សន្សំសំចៃថាមពលនិងប្រសិទ្ធភាពថាមពល អភិរក្សធនធានទឹក និងប្រើប្រាស់ទឹកដោយសន្សំសំចៃ គ្រប់គ្រងដីធ្លីប្រកបដោយ

ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ ធ្វើឲ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ចថេរ បង្កើនគុណភាពជីវិត សុខភាពសាធារណៈ និងសុខភាពបរិស្ថាន។

ដើម្បីឲ្យសម្រេចបាននូវចក្ខុវិស័យបៃតងខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិនេះ សំដៅបន្តជំរុញកំណើនសេដ្ឋកិច្ចជាតិ កិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការលើកកម្ពស់សមភាពយេនឌ័រ សមធម៌សង្គម និងអភិបាលកិច្ចល្អ ដែលធ្វើឲ្យប្រទេសកម្ពុជាឈានឡើងជាប្រទេសអភិវឌ្ឍ។ គោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិនេះ ផ្តោតលើចក្ខុវិស័យបៃតង ដ៏វែងឆ្ងាយ គឺការធ្វើឲ្យមានសមភាព តុល្យភាព និងវឌ្ឍនភាព រវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដើម្បីឈានដល់អារ្យធម៌បៃតងដ៏រុងរឿង តាមរយៈកំណើនសេដ្ឋកិច្ច ការគាំពារនិងសុវត្ថិភាពសង្គម សុវត្ថិភាពអេកូឡូស៊ី និងការរក្សានិងការការពារបេតិកភណ្ឌវប្បធម៌រួមទាំងអត្តសញ្ញាណជាតិ។

ដើម្បីអនុវត្តគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិនេះប្រកបដោយប្រសិទ្ធភាព យុទ្ធសាស្ត្រសំខាន់ៗត្រូវបានដាក់ចេញដូចតទៅ : ការធ្វើឲ្យមានសុខដុមនីយកម្មនៃការអភិវឌ្ឍបៃតងក្នុងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ការអភិវឌ្ឍធនធានមនុស្ស ការផ្លាស់ប្តូរនិងផ្ទេរបច្ចេកវិទ្យាបៃតង ការវិនិយោគបៃតងនិងឱកាសការងារបៃតង ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងនិងសេដ្ឋកិច្ចខៀវប្រកបដោយនិរន្តរភាព ការជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង ដោយរក្សានិងការពារបាននូវបេតិកភណ្ឌវប្បធម៌បៃតង និងអត្តសញ្ញាណជាតិ។ យុទ្ធសាស្ត្រទាំងនេះជំរុញឲ្យសម្រេចបាននូវភាពមានការងារធ្វើជាប្រចាំ សមិទ្ធផលបៃតងនានា ពិសេសផលិតផល ទំនិញ និងសេវាកម្មដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ការធ្វើឲ្យប្រសើរ ឡើងនូវកម្រិតជីវភាពរបស់ប្រជាជន គុណភាពជីវិត សុខភាពបរិស្ថាន សុខភាពសាធារណៈ និងការកាត់បន្ថយភាពក្រីក្រ រហូតប្រទេសឈានដល់ "**អារ្យធម៌បៃតង**"។

គោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិនេះ រួមជាមួយនឹងលិខិតបទដ្ឋានគតិយុត្តបៃតងដទៃទៀត ដើរតួនាទីជាហេដ្ឋារចនាសម្ព័ន្ធបៃតងទន់ បង្កើតបានបរិយាកាសអំណោយផល និងលក្ខខណ្ឌល្អប្រសើរ ដើម្បីតម្រង់ទិសនិងលើកទឹកចិត្តដល់វិនិយោគិនទាំងបរទេសនិងក្នុងស្រុក ក្នុងការបណ្តាក់ទុនលើការអភិវឌ្ឍបៃតងជាតិមានជាអាទិ៍ កសិកម្មបៃតង ឧស្សាហកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍បៃតង ទេសចរណ៍បៃតង អគារនិងសំណង់បៃតង ថាមពលបៃតង ទូរគមនាគមន៍បៃតង ឥណទានបៃតង មូលនិធិទាយជ្ជទានបៃតង កម្រៃសេវាការពារប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងទីផ្សារហិរញ្ញវត្ថុបៃតង។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ មន្ត្រីរាជការ ជាពិសេស ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងបរិស្ថាន ដោយបានសហការគ្នាល្អ លើការកសាងឯកសារគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិនេះឲ្យចេញជារូបរាងឡើង។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ និងផ្នែកឯកជន ក៏ដូចជាប្រជាជនទាំងអស់ សូម

ចូលរួមគាំទ្រ និងរួមចំណែកឲ្យបានសកម្មក្នុងការអនុវត្ត **គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងនិងផែនការយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០** នេះឲ្យទទួលបានជោគជ័យជាទីមោទនៈ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ទាំងក្នុងជួររាជរដ្ឋាភិបាល ផ្នែកឯកជន អង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍ នឹងយក **គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងនិងផែនការយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០**នេះ ទៅប្រើប្រាស់ជាមធ្យោបាយគ្រឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពបរិស្ថាន សង្គម និងវប្បធម៌ និងក្នុងបុព្វហេតុលើកកម្ពស់នូវកិត្យានុភាពបៃតងកម្ពុជា ស្របតាមពាក្យស្លោក “**ការអភិវឌ្ឍបៃតងសម្រាប់អនាគតនៃភពផែនដី**” និង “**ការអភិវឌ្ឍបៃតងសម្រាប់យើងទាំងអស់គ្នា យើងទាំងអស់គ្នារួមគ្នាដើម្បីអារ្យធម៌បៃតង**”។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិនា ឆ្នាំ២០១៣

**នាយករដ្ឋមន្រ្តី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង
លេខៈ...០០៥...........ក.ជ.អ.ប.

ភ្នំពេញ ថ្ងៃទី...០១...ខែ...[illegible]...ឆ្នាំ២០១៣

# សេចក្តីថ្លែងអំណរគុណ
## របស់ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង

ក្នុងនាមក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជា**ស្ថាបនិកបៃតង** និងជា**មហាវីរៈបុរសបរិស្ថានជាតិ** ដ៏ល្បីល្បាញរន្ទឺទូទាំងប្រទេស និងលើឆាកអន្តរជាតិ ដែល**សម្តេចនាយករដ្ឋមន្ត្រី** បានដឹកនាំប្រទេសដ៏ឈ្លាសវៃបំផុតប្រកបដោយបញ្ញាញាណ និងគតិបណ្ឌិត ឲ្យមានការអភិវឌ្ឍរីកចំរើនយ៉ាងខ្លាំងក្លាលើគ្រប់វិស័យ ជាពិសេសការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ការអនុវត្តដោយជោគជ័យនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី និងកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល និងព្រៃឈើ។

ខ្ញុំបាទសូមសម្តែងការកោតសរសើរ និងមានមោទនភាពដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** ដែលតែងតែយកចិត្តទុកដាក់ខ្ពស់បំផុតលើអភិវឌ្ឍន៍បៃតង និងពុះពារការពារបរិស្ថានឲ្យមាននិរន្តរភាពស្របពេលជាមួយនឹងកំណើនម៉ាក្រូសេដ្ឋកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនជីវភាពរស់នៅរបស់ប្រជាជន ឈរលើបទពិសោធដ៏ជោគជ័យបំផុតក្នុងការអនុវត្តយុទ្ធសាស្ត្រឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលលើកតម្កើងកិត្យានុភាពបៃតងជាតិ ពិសេសនៅក្នុងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដោយជំរុញឲ្យមានតុល្យភាព និងវឌ្ឍនភាពរវាងបង្គោលគ្រឹះទាំងបួននេះជាកម្លាំងចលករដ៏សកម្ម តាមរយៈការបង្កើតស្ថាប័នអភិវឌ្ឍន៍បៃតងជាតិ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ដើម្បីឲ្យប្រទេសឆ្ពោះទៅកាន់ **អារ្យធម៌បៃតង** ដើរទន្ទឹមនឹងចរន្តសេដ្ឋកិច្ចបៃតងពិភពលោក។ ចក្ខុវិស័យបៃតង និងស្នាដៃបៃតងដ៏ល្បីល្បាញរន្ទឺរបស់ **សម្តេចនាយករដ្ឋមន្ត្រី** កំពុងធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ជា **ប្រទេសអភិវឌ្ឍបៃតងអច្ឆរិយៈ** និងជាគំរូអភិវឌ្ឍន៍បៃតងដ៏ល្អសម្រាប់ប្រទេសកំពុងអភិវឌ្ឍក៏ដូចជាប្រទេសអភិវឌ្ឍនៅក្នុងសកលលោក។

ទន្ទឹមនឹងនេះដែរ ខ្ញុំបាទក្នុងនាមក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងសូមសម្តែងនូវកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** និងរាជរដ្ឋាភិបាល...

ដែលបានគាំទ្រយ៉ាងខ្លាំងលើគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០។ ការអនុម័តរបស់រាជរដ្ឋាភិបាលនូវគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រជាតិទាំងពីរនេះក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ គឺពិតជាផ្តល់នូវសារៈសំខាន់ដ៏គួរឲ្យស្ញប់ស្ញែងដល់អភិវឌ្ឍន៍បៃតងគំរូរបស់ព្រះរាជាណាចក្រកម្ពុជាទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ ក៏ដូចជាពិភពលោក ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កាត់បន្ថយភាពក្រីក្រក្នុងអត្រា១%ក្នុង១ឆ្នាំ ការពារប្រព័ន្ធអេកូឡូស៊ីប្រកបដោយសុវត្ថិភាព កសាងសង្គមមួយដែលបញ្ចេញកាបូនតិច លើកតម្កើងនិងរក្សាអត្តសញ្ញាណវប្បធម៌បៃតងជាតិ ដោយធានាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងលទ្ធិប្រជាធិបតេយ្យ ហើយធ្វើឲ្យប្រទេសឈានឡើងជាប្រទេសអភិវឌ្ឍប្រកបដោយអារ្យធម៌បៃតង។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ បានបង្ហាញនូវចក្ខុវិស័យដ៏វែងឆ្ងាយ និងយ៉ាងច្បាស់លាស់ ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងឲ្យមានប្រសិទ្ធភាព និងតុល្យភាពស៊ីជម្រៅរវាងការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងបរិស្ថាន ជាមួយនឹងសង្គមវប្បធម៌ តាមរយៈយុទ្ធសាស្ត្រសំខាន់ៗជាអាទិ៍ ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពជាមួយបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ ការបណ្តុះបណ្តាលធនធានមនុស្សបៃតង ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព ការជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង ការរក្សានិងការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិ និងអភិបាលកិច្ចលើការអភិវឌ្ឍបៃតង។ ជាមួយគ្នានេះដែរ ឯកសារគោលទាំងពីរនេះបានបង្ហាញពីយន្តការអនុវត្តយ៉ាងច្បាស់លាស់រួមមានរចនាសម្ព័ន្ធស្ថាប័ន ការបង្កើតក្របខ័ណ្ឌគតិយុត្ត ផែនការសកម្មភាពការងារ ធនធានហិរញ្ញវត្ថុ និងការតាមដានត្រួតពិនិត្យនិងការវាយតម្លៃនៃដំណើរការអនុវត្ត។

តាងនាមឲ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ផ្នែកឯកជន អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍនានា និងសង្គមស៊ីវិល ដែលបានចូលរួមមតិយោបល់ និងកិច្ចសហការនានាក្នុងការរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ដើម្បីឲ្យឯកសារគោលទាំងពីរនេះត្រូវបានយកមកអនុវត្តក្នុងថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។

ក្នុងនាមក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ខ្ញុំបាទសូមប្តេជ្ញាយ៉ាងម៉ឺងម៉ាត់បង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ផ្នែកឯកជន អង្គការជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍនានា និងសង្គមស៊ីវិល ដើម្បីសម្របសម្រួល និងជំរុញអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ឲ្យទទួលបានជោគជ័យដែលធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាឈានឡើងជាប្រទេសអភិវឌ្ឍ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**និងជាប្រធាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង**

ម៉ុក.ម៉ារ៉េត
បណ្ឌិត.វិទ្យា

# មាតិកា


**១- សេចក្តីផ្តើម** ..................... ១

**២- ចក្ខុវិស័យ** ..................... ២

**៣- បេសកកម្ម** ..................... ២

**៤- គោលបំណងនិងគោលដៅ** ..................... ២

៤.១- គោលបំណង ..................... ២

៤.២- គោលដៅ ..................... ២

**៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ..................... ២

៥.១- ការវិភាគជាយុទ្ធសាស្ត្រ ..................... ២

៥.២- ទិសដៅជាយុទ្ធសាស្ត្រនិងយុទ្ធសាស្ត្រ ..................... ៣

១- ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង ..................... ៤

២- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានគុណភាពជាមួយបរិស្ថាន ..................... ៦

៣- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព ..................... ៩

៤- ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ ..................... ១០

៥- ការបណ្តុះបណ្តាលធនធានមនុស្សនិងការអប់រំបៃតង ..................... ១៧

៦- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព ..................... ១៨

៧- ជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង ..................... ១៩

៨- ការរក្សានិងការការពារបេតិកភណ្ឌវប្បធម៌បៃតង និងអត្តសញ្ញាណជាតិ ..................... ២០

៩- អភិបាលកិច្ចលើការអភិវឌ្ឍបៃតង ..................... ២២

**៦- សកម្មភាពការងារ** ..................... ២៤

៦.១- រចនាសម្ព័ន្ធស្ថាប័ន ..................... ២៤

៦.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត ..................... ២៤

៦.៣- ផែនការសកម្មភាពអភិវឌ្ឍន៍បៃតង ..................... ២៤

**៧- ធនធានហិរញ្ញវត្ថុ** ..................... ៣០

**៨- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ..................... ៣០

**៩- សេចក្តីសន្និដ្ឋាន** ..................... ៣០

**ឧបសម្ព័ន្ធ** ..................... ៣១

**សទ្ទានុក្រម** ..................... I

## ១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាបានអនុម័តនិងកំពុងអនុវត្តច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនេះក្លាយជាយន្តការគ្រឹះ ដើម្បីចូលរួមអនុវត្តគោលការណ៍សេដ្ឋកិច្ចបៃតងពិភពលោក ដោយផ្តោតលើកិច្ចការពារបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលអង្គការសហប្រជាជាតិបានប្រជុំសម្រេចយកគោលការណ៍នេះនៅក្នុងសន្និសីទកំពូលភពផែនដី Rio+20 នៅប្រទេសប្រេស៊ីល នាខែមិថុនា ឆ្នាំ២០១២ កន្លងមក។ សព្វថ្ងៃនេះ ប្រទេសកម្ពុជាកំពុងដើរឈានមុខគេ និងជាគំរូក្នុងការអភិវឌ្ឍបៃតងនៅក្នុងបណ្តាប្រទេសអាស៊ាន អាស៊ីប៉ាស៊ីហ្វិក និងបណ្តាប្រទេសជាសមាជិកវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល។

ក្នុងក្របខ័ណ្ឌពិភពលោក ផ្អែកលើសន្និសីទកំពូលភពផែនដី Rio ឆ្នាំ១៩៩២ នៅប្រទេសប្រេស៊ីល បានដាក់ចេញនូវគោលការណ៍អភិវឌ្ឍន៍ប្រកបដោយចីរភាព សន្និសីទកំពូលភពផែនដី Rio+10 ឆ្នាំ២០០២ នៅប្រទេសអាហ្វ្រិកខាងត្បូង បានដាក់ចេញផែនការសកម្មភាពការអភិវឌ្ឍប្រកបដោយចីរភាព និងសន្និសីទកំពូលភពផែនដី Rio+20 ឆ្នាំ២០១២ នៅប្រទេសប្រេស៊ីល បានដាក់ចេញគោលការណ៍ថ្មីដោយផ្តោតលើការអភិវឌ្ឍបៃតង ដែលយកចិត្តទុកដាក់លើកិច្ចការពារបរិស្ថានជាស្នូលក្នុងការអភិវឌ្ឍនិងកាត់បន្ថយភាពក្រីក្រ។ នៅក្នុងសន្និសីទកំពូលភពផែនដី Rio+20 ឆ្នាំ២០១២នោះ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលទៅជាអង្គការអន្តរជាតិ ដោយមានប្រទេសជាហត្ថលេខីផ្សេង ទៀតសរុបចំនួន១៦ និងបច្ចុប្បន្ននេះ ប្រទេសបានចូលរួមជាសមាជិកកើនដល់ចំនួន១៨ ហើយអង្គការនេះ គឺជាយន្តការសម្រាប់អនុវត្តសេចក្តីសម្រេចលើ "អនាគតដែលយើងចង់បាន" របស់អង្គការសហប្រជាជាតិ។

គោលការណ៍នៃការអភិវឌ្ឍបៃតងផ្អែកលើបង្គោលគ្រឹះ៤ គឺសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង សុខភាពសាធារណៈ គុណភាពបរិស្ថាន ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។ ដើម្បីអនុវត្តគោលការណ៍នេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងមានអគ្គលេខាធិការដ្ឋានជាសេនាធិការផ្ទាល់ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍បៃតងដោយបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ នៅកម្ពុជា រាជរដ្ឋាភិបាលបានប្រកាន់យកការអភិវឌ្ឍបៃតងជាយុទ្ធវិធីឈ្នះ ឈ្នះ សម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពទៅថ្ងៃអនាគត ក្លាយខ្លួនទៅជាប្រទេសអភិវឌ្ឍ។

ក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១២-២០៣០ ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង ដែលផ្តោតលើប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតងដូចជាពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទានបៃតង មីក្រូហិរញ្ញវត្ថុបៃតង និងវិនិយោគទុនបៃតង ដោយឈរលើជោគជ័យនៃគោលនយោបាយឈ្នះ ឈ្នះរបស់រាជរដ្ឋាភិបាល និងផ្អែកលើបទពិសោធដ៏ជោគជ័យបំផុតនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ ជាពិសេសរួមចំណែកក្នុងសេដ្ឋកិច្ចបៃតងពិភពលោក ស្របពេលជាមួយគ្នានឹងការថែរក្សាគុណភាពបរិស្ថាន ការលើកកម្ពស់សុខភាពសាធារណៈ ការជំរុញប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គមឆ្ពោះទៅកាន់ការកសាងសង្គមដែលបញ្ចេញកាបូនតិច។

## ២- ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រជាតិនេះ មានចក្ខុវិស័យធ្វើការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនិងនិរន្តរភាព បរិស្ថាន សង្គម និងវប្បធម៌ ដើម្បីកាត់បន្ថយភាពក្រីក្រ។

## ៣- បេសកកម្ម

ផែនការយុទ្ធសាស្ត្រជាតិនេះមានបេសកកម្មជំរុញ លើកកម្ពស់ និងអនុវត្តឲ្យមានប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍបៃតង តាមដំណាក់កាលបញ្ជ្រាបនិងវឌ្ឍនភាពបៃតង។

## ៤- គោលបំណងនិងគោលដៅ

### ៤.១- គោលបំណង

ផែនការយុទ្ធសាស្ត្រជាតិនេះមានគោលបំណងធ្វើឲ្យមានការអភិវឌ្ឍបៃតង ដោយធានាបាននូវស្ថិរភាពនយោបាយនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីឈានឡើងជាប្រទេសអភិវឌ្ឍ។

### ៤.២- គោលដៅ

ផែនការយុទ្ធសាស្ត្រជាតិនេះមានគោលដៅជំរុញសេដ្ឋកិច្ចជាតិឲ្យមានកំណើនថេរ កាត់បន្ថយនិងទប់ស្កាត់ការបំពុលបរិស្ថាន រក្សាសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី កាត់បន្ថយភាពក្រីក្រ បង្កើនសេវាសុខភាពសាធារណៈនិងគុណភាពអប់រំ គ្រប់គ្រងធនធានធម្មជាតិ ការប្រើប្រាស់ដីធ្លីនិងធនធានទឹកប្រកបដោយនិរន្តរភាព បង្កើនប្រសិទ្ធភាពថាមពល ធានាសុវត្ថិភាពចំណីអាហារ និងលើកតម្កើងវប្បធម៌ជាតិ។

## ៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រជាតិនេះ ផ្តល់នូវការតម្រង់ទិសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍបៃតងដោយមានតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ សំដៅកាត់បន្ថយភាពក្រីក្រទូទាំងប្រទេស។ យុទ្ធសាស្ត្រជាតិនេះទទួលបានជោគជ័យ អាស្រ័យលើការបំពេញភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ ដោយមានការគាំទ្រ ការចូលរួម និងកិច្ចសហការជិតស្និទ្ធពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ផ្នែកសាធារណៈ ឯកជន សង្គមស៊ីវិល និងសាធារណជនទូទៅ។

### ៥.១- ការវិភាគជាយុទ្ធសាស្ត្រ

បញ្ហាប្រែប្រួលអាកាសធាតុសំដៅដល់ការឡើងកំដៅភពផែនដី កំណើនសីតុណ្ហភាព រលកកំដៅ ភាពរាំងស្ងួត ការឡើងកម្ពស់ទឹកសមុទ្រ កំណើនទឹកប្រៃ កង្វះទឹកសាប ការរលាយភ្នំទឹកកក ទឹកជំនន់ ដីស្ងួតហួតហែងខ្សោះជីជាតិ និងបញ្ហាគ្រោះមហន្តរាយដែលបណ្តាលមកពីសកម្មភាពមនុស្សនិងកត្តាធម្មជាតិ គឺជាក្តីកង្វល់និងបញ្ហាប្រឈម ដូចជា អសន្តិសុខស្បៀងអាហារ ថាមពល សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អស្ថិរភាពសង្គម និងបាត់លំនឹងប្រព័ន្ធអេកូឡូស៊ី ទាំងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ ក៏ដូចជាពិភពលោកទាំងមូល។ បញ្ហាទាំងពីរនេះ បើគ្មានដំណោះស្រាយរួមមួយត្រឹមត្រូវទេ នោះភពផែនដីមិនអាចទ្រទ្រង់ជីវិតមនុស្ស សត្វ រុក្ខជាតិដែលមានសព្វថ្ងៃបានឡើយ ពិសេសកំណើនប្រជាជនក្នុងពិភពលោកដែលបច្ចុប្បន្នមានចំនួនប្រហែលជាង៧០០០លាននាក់ នឹងត្រូវកើនដល់ប្រហែលជាង៨០០០លាននាក់ នៅឆ្នាំ២០៥០។

តាមការវិភាគបង្ហាញថា ហេតុប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់សក្តានុពលនៃធនធានធម្មជាតិហួសកម្រិត ដោយកំណើននៃប្រជាជនដែលមានតម្រូវការខ្ពស់ទៅលើធនធានទាំងនេះ និងកំណើនវិស័យឧស្សាហកម្មបានដាក់សម្ពាធយ៉ាងខ្លាំងមកលើបរិស្ថាន ដែលបង្កឲ្យមានអតុល្យភាពរវាងកំណើនសេដ្ឋកិច្ចនិងការ

អភិរក្សធនធានធម្មជាតិ ពិសេស ជីវៈចម្រុះ ព្រៃឈើ ជលផល ធនធានទឹក ធនធានរ៉ែ ដីធ្លី។ បញ្ហានេះ បើមិនអាចដោះស្រាយបាននឹងបង្កឲ្យមានបញ្ហាបរិស្ថានជាច្រើនរួមមាន ការបំពុលទឹក ដីខ្សោះជីជាតិ ការបំផ្លាញស្រទាប់អូហ្សូន ការផុតពូជប្រភេទសត្វ ការបំផ្លិចបំផ្លាញប្រភេទរុក្ខជាតិ ខ្យល់ព្យុះ គ្រោះទឹកជំនន់ ភាពរាំងស្ងួត និងលក្ខខណ្ឌអាកាសធាតុមានភាពមិនប្រក្រតី ដែលបង្កើនគម្លាតក្នុងសង្គមជាការគំរាមកំហែងដល់មនុស្សជាតិទាំងមូលនិងការអភិវឌ្ឍប្រទេសនានាលើពិភពលោក។

ជាការដោះស្រាយ រាល់បញ្ហាទាំងនេះទាមទារឲ្យមានកិច្ចសហប្រតិបត្តិការល្អ រវាងប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍ លើការចែករំលែក ការការពារ និងការអភិរក្សធនធានធម្មជាតិដ៏កម្រទៅវិញទៅមកក្នុងការបំពេញតម្រូវការបច្ចុប្បន្ន និងបន្សល់ទុកជូនអ្នកជំនាន់ក្រោយៗ។

យើងទាំងអស់គ្នាត្រូវប្រែក្លាយទស្សនៈនៃការអភិវឌ្ឍប្រកបដោយចីរភាព ឲ្យទៅជាការពិតជាក់ស្តែងក្នុងន័យថាការអភិវឌ្ឍសម្រាប់ទាំងអស់គ្នានិងសម្រាប់អ្នកជំនាន់ក្រោយ ដែលមានការអភិវឌ្ឍបៃតងជាមធ្យោបាយគ្រឹះឈរលើបង្គោលគ្រឹះ៤គឺ សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពិសេសការធ្វើឲ្យមានសុខដុមនីយកម្មរវាងបង្គោលគ្រឹះទាំង៤ ដែលនាំមកនូវភាពរីកចម្រើនលូតលាស់សេដ្ឋកិច្ច សង្គម គុណភាពជីវិត សុខុមាលភាព ជីវភាពរស់នៅធូរធារបស់ប្រជាជន បរិស្ថានបៃតងល្អ ឆ្ពោះទៅរក**អារ្យធម៌បៃតង**។

ដើម្បីចូលរួមចំណែកក្នុងការការពារនិងថែរក្សាភពផែនដីឲ្យមាននិរន្តរភាព ព្រះរាជាណាចក្រកម្ពុជាបានបង្កើតផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតងជាតិឆ្នាំ២០១០ សម្រាប់និរន្តរភាពបរិស្ថាន ការបង្កើតភាគរភាពសង្គម ការអភិវឌ្ឍសេដ្ឋកិច្ច និងការលើកតម្លៃអត្តសញ្ញាណជាតិ។ លើសពីនេះ ព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវយន្តការអភិវឌ្ឍន៍បៃតងជាតិគឺក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង សម្រាប់កំណត់ទិសដៅយុទ្ធសាស្ត្រនៃការអភិវឌ្ឍប្រកបដោយចីរភាព។

### ៥.២- ទិសដៅជាយុទ្ធសាស្ត្រនិងយុទ្ធសាស្ត្រ

ការរៀបចំនិងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះឲ្យឆ្លើយតបទៅនឹងគោលការណ៍អភិវឌ្ឍបៃតងត្រូវមានការចូលរួមយ៉ាងសកម្មពីផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល និងសាធារណជនទូទៅ ដើម្បីប្រសិទ្ធភាពអភិវឌ្ឍន៍បៃតង ដែលមានតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌។

រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវយុទ្ធវិធីបៃតងឈ្នះ ឈ្នះ រវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ដោយកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងដើម្បីរក្សាស្ថិរភាពនយោបាយនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព តម្លាភាព គណនេយ្យភាព សមធម៌ យុត្តិធម៌ និងកាលានុវត្តភាពបៃតង។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ត្រូវជំរុញអនុវត្តការអភិវឌ្ឍបៃតងដោយផ្តោតលើទិសដៅជាយុទ្ធសាស្ត្រ រួមមាន៖

១- ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង។
២- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពជាមួយបរិស្ថាន។
៣- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព។
៤- ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ។
៥- ការបណ្តុះបណ្តាលធនធានមនុស្សនិងការអប់រំបៃតង។
៦- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព។
៧- ជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង។
៨- ការរក្សានិងការការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិ។
៩- អភិបាលកិច្ចលើការអភិវឌ្ឍបៃតង។

## ១- ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង

រាជរដ្ឋាភិបាលបង្កើតឱកាសការងារបៃតង តាមរយៈការបង្កើតនិងការប្រើប្រាស់បច្ចេកវិទ្យាបៃតង ព្រមទាំងការលើកកម្ពស់វិនិយោគទុនបៃតង។ ការវិនិយោគបៃតង សំដៅដល់ការបណ្តាក់ទុនទាំងបច្ចេកទេស និងថវិកាលើការអភិវឌ្ឍគ្រប់វិស័យ ដោយធានាបាននូវការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ក៏ដូចជាធនធានធម្មជាតិ និងផ្ទុយទៅវិញ វាជួយកែលម្អគុណភាពបរិស្ថាន ថែរក្សាប្រព័ន្ធអេកូឡូស៊ី អភិរក្សជីវៈចម្រុះ កាត់បន្ថយការប្រើប្រាស់ថាមពលនិងធនធានធម្មជាតិ កាត់បន្ថយការបញ្ចេញកាបូន និងកាត់បន្ថយការបំពុលបរិស្ថាន។ ការងារបៃតងមានជាអាទិ៍ កសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផល និងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង។

រាល់ផលិតផល សេវាកម្មបៃតង និងទីផ្សារហិរញ្ញវត្ថុបៃតង ចាំបាច់ត្រូវមានការលើកទឹកចិត្តដល់ការវិនិយោគពីផ្នែកឯកជនលើកសិកម្មបៃតង ឧស្សាហកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង សំណង់អគារបៃតង ទេសចរណ៍បៃតង ពាណិជ្ជកម្មបៃតង ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុបៃតង ព្រមទាំងពន្ធដារបៃតង និងបច្ចេកវិទ្យាបៃតង។

កសិកម្មបៃតងលើកទឹកចិត្តឯកជន ព្រមទាំងប្រជាកសិករទាំងអស់ ឲ្យប្រើប្រាស់ជីសរីរាង្គធម្មជាតិ កាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្មនិងសារធាតុគីមី ធ្វើប្រពលវប្បកម្មដំណាំ និងបង្កើនការយល់ដឹងបន្ថែមអំពីបច្ចេកវិទ្យាបៃតងសម្រាប់កសិកម្ម។

ឧស្សាហកម្មបៃតងលើកទឹកចិត្តការប្រើប្រាស់ថាមពលកកើតឡើងវិញ សន្សំសំចៃថាមពលនិងប្រសិទ្ធភាពថាមពល និងប្រើប្រាស់វត្ថុធាតុដើមប្រកបដោយប្រសិទ្ធភាព ព្រមទាំងបង្កើនផលិតផល ឧស្សាហកម្មមានគុណភាពខ្ពស់។

ពាណិជ្ជកម្មបៃតងលើកទឹកចិត្តដល់ការផ្គត់ផ្គង់ ក៏ដូចជាការប្រមូលទិញផលិតផលបៃតង និងដល់ការបង្ហាញផលិតផលបៃតង ព្រមទាំងលើកទឹកចិត្តដល់ការវិនិយោគពាក់ព័ន្ធ និងការផ្ទេរ ការផ្លាស់ប្តូរបច្ចេកវិទ្យាទាំងឡាយសម្រាប់ផលិតកម្មបៃតងនិងទីផ្សារបៃតង។

ហេដ្ឋារចនាសម្ព័ន្ធបៃតងនិងគមនាគមន៍បៃតង ជាពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបៃតងទាំងអស់ត្រូវបានលើកទឹកចិត្តចំពោះការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងធានាកាត់បន្ថយឲ្យបាននូវឥទ្ធិពលអវិជ្ជមានលើបរិស្ថានពីហេដ្ឋារចនាសម្ព័ន្ធ។

មធ្យោបាយដឹកជញ្ជូនបៃតងត្រូវបានលើកទឹកចិត្តលើការមិនបំពុលបរិស្ថាន។

ទេសចរណ៍បៃតងសំដៅអនុវត្តបានជោគជ័យលើគោលការណ៍ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ។

អគារនិងសំណង់បៃតងត្រូវបានលើកទឹកចិត្តលើមូលដ្ឋានប្រើថាមពលកកើតឡើងវិញ សន្សំសំចៃថាមពលនិងប្រសិទ្ធភាពថាមពល សន្សំសំចៃទឹក និងសោភណភាពបរិស្ថាន។

ថាមពលបៃតងត្រូវបានលើកទឹកចិត្តទៅលើការប្រើប្រាស់បច្ចេកវិទ្យាបៃតងដែលផ្តល់ប្រសិទ្ធភាពថាមពលពិសេស ថាមពលកកើតឡើងវិញ។

ទូរគមនាគមន៍បៃតងត្រូវបានលើកទឹកចិត្តទៅលើប្រព័ន្ធបច្ចេកវិទ្យាដែលមិនបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈនិងបរិស្ថាន។

ការវិនិយោគបៃតងនិងការបង្កើតការងារបៃតងត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖

**១.១- ជំរុញលើកទឹកចិត្តដល់វិនិយោគិនដែលគិតគូរដល់ការអភិវឌ្ឍបៃតងនិងបង្កើនការងារដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង**

- ទាក់ទាញវិនិយោគិនបៃតងលើកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផល និងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈការលើកទឹកចិត្តពីទីក្រុង ភូមិ ឃុំបៃតង ព្រមទាំងឥណទាន ហិរញ្ញវត្ថុ និងពន្ធដារបៃតង
- បញ្ជ្រាបការអភិវឌ្ឍបៃតងទៅក្នុងប្រព័ន្ធសេដ្ឋកិច្ច ធនាគារ និងហិរញ្ញវត្ថុ
- ចេញវិញ្ញាបនបត្របៃតង ជូនក្រុមហ៊ុន សហគ្រាស សណ្ឋាគារ ភោជនីយដ្ឋាន អង្គការ គ្រឹះស្ថានហិរញ្ញវត្ថុ ធនាគារវិនិយោគ និងធនាគារពាណិជ្ជ ដែលជួយការពារថែរក្សាបរិស្ថាន និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ពិសេសមិនបង្កផលប៉ះពាល់អវិជ្ជមានដល់សង្គមនិងបរិស្ថាន
- លើកកម្ពស់អាជីវកម្ម និងឧស្សាហកម្មបៃតង ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង
- លើកទឹកចិត្តដល់នីតិបុគ្គលដែលទទួលជ័យលាភីបៃតង មានជាអាទិ៍ រង្វាន់បៃតង ទង់បៃតង មេដាយ បរិក្ខារបៃតង បណ្ណសរសើរបៃតង និងគ្រឿងឥស្សរិយយសបៃតងផ្សេងៗ។

**១.២- វិនិយោគលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព**

- អនុវត្តគោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់អាជីវកម្មនិងវិនិយោគទាក់ទងនឹងធនធានធម្មជាតិ
- បញ្ជ្រាបក្របខ័ណ្ឌផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាពនៅក្នុងគម្រោងវិនិយោគទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិ
- កំណត់តម្លៃសមស្របដល់កត្តាផលិតចេញពីធនធានធម្មជាតិ
- លើកកម្ពស់ប្រសិទ្ធភាពប្រើប្រាស់ធនធាន ព្រមទាំងការគ្រប់គ្រងសំណល់ដោយអនុវត្តគោលការណ៍អ្នកបំពុលជាអ្នកបង់ថ្លៃ
- ប្រើប្រាស់គោលការណ៍កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ក្នុងការវិនិយោគដែលប្រើប្រាស់ធនធានធម្មជាតិនិងធនធានផ្សេងទៀត។

**១.៣- ការគ្រប់គ្រងហិរញ្ញវត្ថុផ្នែកសាធារណៈនិងផ្នែកឯកជនប្រកបដោយប្រសិទ្ធភាព**

- ជំរុញនិងលើកកម្ពស់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឯកជននិងកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយអនុវត្តគោលការណ៍អភិបាលកិច្ចល្អ ជាពិសេស តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវ
- រៀបចំគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធីនិងគម្រោងសាកល្បងបៃតង នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការបែងចែកថវិកាទៅតាមវិស័យនីមួយៗនៃការអភិវឌ្ឍបៃតងឲ្យមានប្រសិទ្ធភាព
- ជំរុញការប្រើប្រាស់ថវិកាផ្នែកឯកជននិងសាធារណៈឲ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពទៅតាមវិស័យអភិវឌ្ឍន៍នីមួយៗ ដើម្បីឈានដល់គោលដៅអភិវឌ្ឍន៍បៃតងជាតិ

- ធ្វើការតាមដានត្រួតពិនិត្យ ការបែងចែក និងការប្រើប្រាស់ថវិកា ទាំងផ្នែកឯកជន ទាំងផ្នែកសាធារណៈ ដើម្បីធានាការអភិវឌ្ឍបៃតងជាតិឲ្យមានប្រសិទ្ធភាព
- រៀបចំមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតងសម្រាប់ការអភិវឌ្ឍបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតង
- បញ្ជ្រាបមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតងទៅក្នុងប្រព័ន្ធគណនីជាតិ ដើម្បីកត់ត្រាចំណូលជាតិចេញពីបរិស្ថានបៃតង ការប្រើប្រាស់ធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- ធ្វើការតាមដានត្រួតពិនិត្យគណនីនិងហិរញ្ញវត្ថុ ទាក់ទងនឹងការអភិវឌ្ឍបៃតង។

**២- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានគុណភាពជាមួយបរិស្ថាន**

ការវិវឌ្ឍនៃប្រព័ន្ធសេដ្ឋកិច្ចពិភពលោក ពិសេសការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្នកំពុងយកវិស័យបរិស្ថានជាស្នូលនៃការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព។ យោងតាមសេចក្តីសម្រេចឆ្នាំ២០១២ ស្តីពី **អនាគតដែលយើងចង់បាន** របស់អង្គការសហប្រជាជាតិ សេដ្ឋកិច្ចបៃតងត្រូវបានទទួលស្គាល់ជាមធ្យោបាយគ្រឹះនិងជាឧបករណ៍សេដ្ឋកិច្ច ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល និងគោលដៅកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ សេដ្ឋកិច្ចបៃតងសំដៅដល់ការរីកចម្រើនលូតលាស់ សេដ្ឋកិច្ចដើរទន្ទឹមនឹងនិរន្តរភាពបរិស្ថាន ដែលធ្វើឲ្យមានការរីកចម្រើននិងភាតរភាពសង្គម បង្កើនគុណភាពជីវិតនិងបង្កើតឱកាសការងារបៃតងសម្រាប់ប្រជាជនទូទាំងប្រទេស តាមរយៈការអភិវឌ្ឍបៃតងដោយឈរលើការថែរក្សាប្រព័ន្ធអេកូឡូស៊ីភពផែនដីឲ្យមានគុណភាពជាមួយនឹងសមត្ថភាពទ្រទ្រង់ជីវិតរបស់ភពផែនដី។

ជាសំខាន់ សេដ្ឋកិច្ចបៃតងផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតង ពិសេសពន្ធបៃតង ហិរញ្ញវត្ថុបៃតង ឥណទានបៃតង និងមីក្រូនិងម៉ាក្រូហិរញ្ញវត្ថុបៃតង ដែលជាមូលដ្ឋានម៉ាក្រូសេដ្ឋកិច្ចថេរ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍប្រកបដោយចីរភាព។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍដូចករណីប្រទេសកម្ពុជាដែលនឹងឈានឡើងជាប្រទេសអភិវឌ្ឍដោយប្រកាន់យកគោលជំហរនិងគោលការណ៍សេដ្ឋកិច្ចបៃតង ដែលជាកត្តាលីករជំរុញកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចស៊ីជម្រៅ ពិសេសកំណែទម្រង់គោលនយោបាយសេដ្ឋកិច្ច ឆ្ពោះទៅកាន់ការអភិវឌ្ឍបៃតង ដែលដើរតួនាទីចម្បងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេស នាពេលបច្ចុប្បន្ននិងអនាគត ដោយមាននិរន្តភាពបរិស្ថាននិងកាត់បន្ថយភាពក្រីក្របានស្របតាមគោលដៅរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រឲ្យបានអត្រា១%ក្នុងមួយឆ្នាំ។ គោលការណ៍អភិវឌ្ឍន៍បៃតងរួមទាំងសេដ្ឋកិច្ចបៃតងមានជាអាទិ៍ ១- ការប្រើប្រាស់វត្ថុធាតុដើមនិងធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព ២- បច្ចេកវិទ្យាបៃតងរួមជាមួយបច្ចេកទេស ៣- គុណភាពបរិស្ថានសំដៅយកគុណភាព ផលិតផល សេវាកម្មដែលគ្មានការបំពុលបរិស្ថាន ដូចជា ទឹក ដី ខ្យល់ ព្រៃឈើ ជលផល ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ៤- ការបញ្ចេញសំណល់តិច ៥- ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ដែលធ្វើឲ្យកាន់តែមានប្រសិទ្ធភាពដល់ការផលិតនិងប្រើប្រាស់ថាមពលដោយ ចំណាយតិច ផ្អែកលើទំនើបកម្មបច្ចេកទេសនិងបច្ចេកវិទ្យាបៃតង ៦- ការប្រើប្រាស់ទឹកនិងថាមពលដោយ សន្សំសំចៃ ៧- មីក្រូ ម៉ាក្រូហិរញ្ញវត្ថុបៃតងដូចជាឥណទាន កម្មវិថវិកាបៃតងដែលជួយការពារបរិស្ថាននិងថែរក្សាប្រព័ន្ធអេកូឡូស៊ីឲ្យមានសុវត្ថិភាព ៨- ការអភិវឌ្ឍសេដ្ឋកិច្ចដោយបញ្ចេញកាបូនតិចសំដៅបន្សាំទៅនឹង ការប្រែប្រួល អាកាសធាតុ និងធន់ទ្រាំទៅនឹងអាកាសធាតុ ៩- ពន្ធបៃតងមានជាអាទិ៍ ពន្ធកាត់បន្ថយការ បំពុលបរិស្ថាន ពន្ធបញ្ចេញសំណល់រឹងនិងរាវ និងពន្ធប្រើប្រាស់ធនធានធម្មជាតិ ព្រមទាំងសេវាការពារ ប្រព័ន្ធបរិស្ថាន និងការទូទាត់តម្រៃសេវា

បរិស្ថាន។ គោលការណ៍ទាំង៩ខាងលើ ត្រូវបានទទួលស្គាល់ជាគោលការណ៍សេដ្ឋកិច្ចបៃតងដែលត្រូវប្រើជាមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតសូចនាករសម្រាប់វាស់ការអនុវត្តនៃការរីកចម្រើននិងស្ថានភាពអន្តរកាលនៃសេដ្ឋកិច្ចបៃតង។

**ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានគុណភាពជាមួយបរិស្ថានត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

**២.១- ការគ្រប់គ្រងសារពើពន្ធបៃតង**

- រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយសេដ្ឋកិច្ចបៃតង ដើម្បីជានាកំណើនសេដ្ឋកិច្ច គុណភាពបរិស្ថាន គុណភាពជីវិត សុខុមាលភាពរបស់ប្រជាជន និងសុវត្ថិភាពអេកូឡូស៊ី
- រៀបចំកសាងប្រភេទពន្ធដារបៃតងទៅតាមគោលការណ៍អភិវឌ្ឍន៍បៃតង
- ប្រើពន្ធបៃតងជាឧបករណ៍លើកទឹកចិត្តដល់ការអភិវឌ្ឍបៃតងលើគ្រប់វិស័យអភិវឌ្ឍន៍ពាក់ព័ន្ធ
- រៀបចំសូចនាករដើម្បីបង្ហាញពីកំណើនសេដ្ឋកិច្ចបៃតងផ្អែកលើគោលការណ៍អភិវឌ្ឍន៍បៃតង
- រៀបចំយន្តការគ្រប់គ្រងក្នុងដំណាក់កាលអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតងឲ្យមានប្រសិទ្ធភាព
- កែលម្អគុណភាពអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព ដោយបង្កើនផលិតភាពនិងបរិមាណផលិតផល ឈរលើបច្ចេកទេសនិងបច្ចេកវិទ្យាបៃតង ដែលប្រើវត្ថុធាតុដើមនិងធនធានតិចក្នុងខ្សែចង្វាក់និងវដ្តផលិតកម្ម
- បញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតងទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងវិស័យអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិនិងក្រោមជាតិ
- ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចប្រពៃណីទៅកាន់សេដ្ឋកិច្ចបៃតង ដើម្បីបញ្ជ្រាប បន្ស៊ី និងបន្សុំគ្នារវាងសេដ្ឋកិច្ចនិងប្រព័ន្ធអេកូឡូស៊ីប្រកបដោយប្រសិទ្ធភាព
- បង្កើតហេដ្ឋារចនាសម្ព័ន្ធប្រសិទ្ធភាពបៃតងតាមរយៈការធ្វើផែនការសេដ្ឋកិច្ចបៃតង
- បង្កើតឱកាសពាណិជ្ជកម្មបៃតង
- លើកកម្ពស់សុខុមាលភាពស្ត្រី កុមារ យុវជន ជនពិការ ប្រជាកសិករ ជនជាតិដើមភាគតិច ចាស់ជរា និងសហគមន៍តាមរយៈកំណើនសេដ្ឋកិច្ចបៃតង និងប្រព័ន្ធសុវត្ថិភាពសង្គមបៃតង
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច
- ធ្វើទីផ្សារសេដ្ឋកិច្ចបៃតងឲ្យមានដំណើរការល្អនិងប្រសិទ្ធភាពឈរលើតម្លៃទីផ្សារបៃតងសមរម្យ តម្លៃវត្ថុធាតុដើមសមរម្យ និងតម្លៃផលិតផលសម្រេចសមរម្យ ស្របតាមគោលការណ៍សេដ្ឋកិច្ចបៃតងអន្តរជាតិនិងសេដ្ឋកិច្ចបៃតងសកលភាវូបនីយកម្ម
- ជំរុញការចូលរួមអនុវត្តគោលការណ៍សេដ្ឋកិច្ចបៃតងពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចបៃតងពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ។

**២.២- ការគ្រប់គ្រងនយោបាយហិរញ្ញវត្ថុបៃតង**

- រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយហិរញ្ញវត្ថុបៃតង
- បញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតងទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារ
- រៀបចំនីតិវិធីនិងការគ្រប់គ្រងលទ្ធកម្មបៃតង
- រៀបចំគម្រោងឥណទាន កម្ចីបៃតងឈរលើគោលការណ៍អភិវឌ្ឍន៍បៃតងនៅតាមបណ្តាក្រុមហ៊ុនហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដើម្បីលើកកម្ពស់សេដ្ឋកិច្ចបៃតង ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ

- រៀបចំប្រព័ន្ធសេវាកម្មបៃតង តាមរយៈម៉ាស៊ីនស្វ័យប្រវត្តិសម្រាប់ដក ដាក់សាច់ប្រាក់នៅក្នុង បណ្ដាគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធបៃតងក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ ដោយប្រើបច្ចេកវិទ្យាបៃតង អគារបៃតង និងលម្អបៃតង
- ប្រើប្រព័ន្ធបច្ចេកវិទ្យាបៃតង ដើម្បីគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការគណនេយ្យនិងលំហូរហិរញ្ញវត្ថុ ស្របតាមគោលការណ៍អភិវឌ្ឍន៍បៃតង
- បង្កើតបរិយាកាសអំណោយផល នៅតាមបណ្ដាក្រុមហ៊ុនហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុបៃតង នៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ
- ធ្វើទីផ្សារហិរញ្ញវត្ថុឲ្យមានលក្ខណៈបៃតង ពិសេសឲ្យតម្លៃវត្ថុធាតុដើមនិងផលិតផលមិនទាន់ កែច្នៃមានតម្លៃថេរសមរម្យ ដោយមានគុណភាពជាមួយនឹងលំនឹងកំណើនសេដ្ឋកិច្ច សុវត្ថិភាព ប្រព័ន្ធអេកូឡូស៊ី សុខុមាលភាពហិរញ្ញវត្ថុ និងគុណភាពជីវិត
- ជំរុញលើកទឹកចិត្តដល់សាធារណជន និងប្រជាជនទូទៅឲ្យប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុនិង ធនាគារបៃតង
- កាត់បន្ថយភាពក្រីក្រទូទាំងប្រទេស តាមរយៈការផ្ដល់សេវាកម្មហិរញ្ញវត្ថុនិងធនាគារបៃតង ព្រមទាំងផលិតផលបៃតង ដូចជា ប្រតិបត្តិការហិរញ្ញវត្ថុស្អាតស្អំ ជំនាញហិរញ្ញវត្ថុ និងធនាគារ បៃតង សេវាកម្មបៃតង អត្រាការប្រាក់សម្រាប់គុណភាពបរិស្ថានផ្ដើមចេញពីក្រុមហ៊ុន ហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា។

**២.៣- ការគ្រប់គ្រងការទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន**

- រៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្ត សម្រាប់ការទូទាត់កម្រៃសេវាការពារប្រព័ន្ធ បរិស្ថាន
- រៀបចំមូលនិធិទាយជ្ជទានបៃតងសម្រាប់យកទៅចាត់ចែងក្នុងការអភិវឌ្ឍបៃតងក្នុងព្រះរាជា-ណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ហិរញ្ញវត្ថុ
- លើកកម្ពស់ផលិតភាពនៃសេវាប្រព័ន្ធអេកូឡូស៊ី នៅតាមបណ្ដាតំបន់ការពារធម្មជាតិ តំបន់ អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរ
- ជំរុញការអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតង នៅតាមបណ្ដាតំបន់ការពារធម្មជាតិ តំបន់ អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរ ដើម្បីកំណើនកម្រៃសេវាការពារប្រព័ន្ធបរិស្ថាន ដែលជា មូលដ្ឋានអេកូឡូស៊ីគ្រឹះ ក្នុងការការពារប្រភពទឹក ទីជម្រាល ដីសើម និងធនធានធម្មជាតិ ការ អភិរក្សជីវៈចម្រុះ ព្រមទាំងទប់ស្កាត់សកម្មភាពអភិវឌ្ឍដែលបង្កការខូចខាតដល់បរិស្ថាននិង ទប់ស្កាត់ការបំពុលបរិស្ថាន
- ប្រើប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន ជាឧបករណ៍លើកទឹកចិត្តដល់សហគមន៍ មូលដ្ឋាននិងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីឲ្យចូលរួមការពារនិងថែរក្សាធនធានធម្មជាតិឲ្យមាន និរន្តរភាព
- បង្កើនលទ្ធភាពផ្ទុកកាបូនតាមយន្តការកម្រៃសេវាការពារប្រព័ន្ធបរិស្ថានឈរលើគោលការណ៍ អភិវឌ្ឍន៍បៃតង
- បញ្ជ្រាបប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថានផ្អែកលើគោលការណ៍អភិវឌ្ឍន៍បៃតង
- ទាញយកទីផ្សារលក់ឥណទានកាបូន តាមរយៈការអនុវត្តការទូទាត់កម្រៃសេវាការពារប្រព័ន្ធ បរិស្ថាននៅតាមបណ្ដាតំបន់ការពារធម្មជាតិ តំបន់អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរ នៅ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- សម្របសម្រួលដល់ការកំណត់តំបន់ ដើម្បីបែងចែកជាតំបន់សម្រាប់ផលិតភាពនៃសេវាការពារប្រព័ន្ធបរិស្ថាន មានជាអាទិ៍ តំបន់អភិវឌ្ឍន៍សហគមន៍ តំបន់ការពារព្រៃឈើ តំបន់ទីជម្រាល សហគមន៍តំបន់ការពារធម្មជាតិ
- ធ្វើសមាហរណកម្មវិស័យកសិកម្មបៃតងចូលទៅក្នុងតំបន់ការពារព្រៃឈើ តំបន់ទីជម្រាល សហគមន៍តំបន់ការពារធម្មជាតិ និងមូលនិធិការពារប្រព័ន្ធអេកូឡូស៊ី ដើម្បីគាំទ្រដល់ការអភិវឌ្ឍកសិកម្មក្នុងតំបន់គោលដៅ និងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជន។

**២.៤- ការគ្រប់គ្រងចំណូល ចំណាយប្រកបដោយប្រសិទ្ធភាព**

- បង្កើនចំណូលជាតិ ដោយអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតងនិងសេដ្ឋកិច្ចបៃតង ទៅតាមវិស័យអភិវឌ្ឍន៍នីមួយៗ
- កត់ត្រាចំណូល ចំណាយ សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ តាមបែបគណនេយ្យបៃតង ឈរលើគោលការណ៍អភិវឌ្ឍន៍បៃតងនិងសេដ្ឋកិច្ចបៃតង
- ជំរុញការចំណាយផ្នែកឯកជន ផ្នែកសាធារណៈ និងរបស់ប្រជាជនទូទៅ លើបច្ចេកវិទ្យាបៃតង ទីផ្សារហិរញ្ញវត្ថុបៃតង ប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន ផលិតផល និងសេវាកម្មបៃតង
- តាមដានត្រួតពិនិត្យការវិនិយោគទាំងផ្នែកឯកជននិងផ្នែកសាធារណៈ ដើម្បីប្រសិទ្ធភាពនៃសេដ្ឋកិច្ចបៃតងនិងការកាត់បន្ថយភាពក្រីក្រ។

## ៣- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព

សមុទ្រកម្ពុជាមានកោះនិងប្រជុំកោះតូចធំ ដែលមានទីតាំងស្ថិតនៅខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ហើយកោះមួយចំនួនជាតំបន់អភិវឌ្ឍន៍អេកូទេសចរណ៍ និងជាទីកន្លែងសំចតរបស់អ្នកនេសាទ អ្នកសិក្សាស្រាវជ្រាវ និងការឆ្លងកាត់របស់អ្នកដើរនាវាធំៗផងដែរ។ ចំណែកធនធានក្នុងទឹករួមមានមច្ឆជាតិ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃកោងកាង ព្រៃលិចទឹក សារាយ និងប្រភេទជីវៈចម្រុះសមុទ្រផ្សេងៗទៀត ហើយនៅបាតសមុទ្រវិញ មានធនធានរ៉ែប្រេងកាតនិងឧស្ម័ន។ល។

ការអភិវឌ្ឍនៅតំបន់សមុទ្រគឺជាផ្នែកមួយដ៏សំខាន់សម្រាប់ទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្ម ការដឹកជញ្ជូនតាមផ្លូវទឹក ការសាងសង់កំពង់ផែ ការអភិវឌ្ឍតំបន់អេកូទេសចរណ៍នៅតាមកោះ តំបន់ទេចរណ៍តំបន់ឆ្នេរ ការរុករកនិងការធ្វើអាជីវកម្មរ៉ែប្រេងនិងឧស្ម័ន ការនេសាទ និងការអភិវឌ្ឍផ្សេងៗទៀតដែលមិនមានការបំពុលដល់បរិស្ថានសមុទ្រ។

**ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាពត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

**៣.១- ការគ្រប់គ្រងនិងអភិវឌ្ឍសេដ្ឋកិច្ចខៀវ**

- ការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងអន្តរជាតិ ដើម្បីពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមានគុណភាពជាមួយបរិស្ថាននិងសង្គមក្នុងតំបន់សមុទ្រ
- ការគ្រប់គ្រងធនធានសមុទ្រ តំបន់ឆ្នេរ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឲ្យមានសុវត្ថិភាព ចីរភាព និងនិរន្តរភាព ដោយបន្តការពង្រឹងការងារគ្រប់គ្រងនិងអភិរក្សតំបន់ដីសើម ទីជម្រាលឆ្នេរសមុទ្រ និងតំបន់ការពារធម្មជាតិនៅតំបន់សមុទ្រ
- ការអភិរក្សនិងការប្រើប្រាស់ធនធានសមុទ្រប្រកបដោយនិរន្តរភាព ជួយផ្តល់នូវការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន កំណើនសេដ្ឋកិច្ចថេរ សន្តិសុខស្បៀង និងការបង្កើនជីវភាពរស់នៅប្រកបដោយនិរន្តរភាព។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវការពារនិងស្តារបរិស្ថានសមុទ្រនិងប្រព័ន្ធអេកូឡូស៊ីសមុទ្រ សម្រាប់ផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចសង្គមជាតិ

- ការសិក្សានិងការវាយតម្លៃពីការប៉ះពាល់ដល់ធនធានសមុទ្របណ្ដាលមកពីគម្រោងអភិវឌ្ឍនានា
- ការគ្រប់គ្រងការបំពុលសមុទ្រ ដូចជា ការគ្រប់គ្រងការបោះចោលសំណល់រឹង សំណល់ប្លាស្ទិក សារធាតុបំពុលសរីរាង្គ សារធាតុលោហៈធ្ងន់ និងការបង្ហូរសំណល់រាវ ដើម្បីទប់ស្កាត់មិនឲ្យមានការប៉ះពាល់ដល់សុខភាពសមុទ្រនិងជីវៈចម្រុះសមុទ្រ។

**៣.២- ការអង្កេតតាមដានការបំពុលសមុទ្រ**

- ការជំរុញលើការងារអង្កេតតាមដាន និងការធ្វើអធិការកិច្ចលើគុណភាពទឹកសមុទ្រដែលមានសារធាតុអាស៊ីដ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីសមុទ្រដែលងាយទទួលរងការប៉ះពាល់ និងសហគមន៍នេសាទដែលពឹងអាស្រ័យដោយសារធនធានទាំងនេះ
- គាំទ្រនិងលើកទឹកចិត្តដល់អ្នកវិទ្យាសាស្ត្រស្រាវជ្រាវដែលរកឃើញនូវសារធាតុបំពុលទឹកសមុទ្រនិងថែរក្សាគុណភាពទឹកសមុទ្រ
- កំណត់កត្តាហេតុប៉ះពាល់ និងកាត់បន្ថយហេតុប៉ះពាល់សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ ជាពិសេស អ្នករស់នៅតំបន់កោះ ដោយសារការធ្វើអាជីវកម្មនេសាទត្រីហួសកម្រិតនិងការបំពុលដល់ប្រភេទជីវៈចម្រុះ ប្រភេទត្រី ផ្កាថ្ម និងព្រៃកោងកាងជាដើម។

**៣.៣- ការធានាសន្តិសុខស្បៀងនៅតំបន់សមុទ្រ**

- ការបង្កើនទិន្នផលស្តុកត្រីឲ្យដល់កម្រិតអតិបរមា និងការធ្វើវារីវប្បកម្មសមុទ្រ ដើម្បីផ្តល់នូវការផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់ ដោយសម្រេចបានគោលដៅអភិវឌ្ឍន៍បៃតង
- ការកំណត់យុទ្ធសាស្ត្រក្នុងការពង្រឹងសមត្ថភាពការអភិរក្សនិងការគ្រប់គ្រងបរិស្ថានសមុទ្រប្រកបដោយនិរន្តរភាព គឺជាការផ្តល់ផលប្រយោជន៍សម្រាប់ប្រជានេសាទ។

**៣.៤- ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ**

- សិក្សា ស្រាវជ្រាវ និងវិភាគពីការប្រែប្រួលអាកាសធាតុដែលនាំឲ្យមានការឡើងកម្ពស់ទឹកសមុទ្រនិងការហូរច្រោះឆ្នេរ ដោយមានការគំរាមកំហែងយ៉ាងខ្លាំងទៅលើតំបន់សមុទ្រនិងបណ្តាកោះ ជាពិសេស ប្រជាជនរស់នៅតាមកោះដែលនឹងជួបបញ្ហាប្រឈមទាំងនេះ ដូច្នេះ ការស្វែងយល់ពីគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនិងការបំពុលសមុទ្រគឺជាការសំខាន់
- ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញដូចជាការផលិតថាមពលដោយកម្លាំងខ្យល់ និងកម្លាំងរលកសមុទ្រ និងកាត់បន្ថយការបញ្ចេញកាបូនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខៀវ
- រៀបចំទុកជាមុន បង្ការ និងការពារពីគ្រោះមហន្តរាយនៅតំបន់សមុទ្រ និងបំពាក់ឧបករណ៍និងផ្តល់ព័ត៌មានបន្ទាន់លើគ្រោះធម្មជាតិនិងគ្រោះមហន្តរាយផ្សេងៗ ដល់អ្នករស់នៅតំបន់កោះ អ្នកធ្វើពាណិជ្ជកម្ម និងអ្នកធ្វើសកម្មភាពផ្សេងៗនៅតំបន់សមុទ្រ តាមបច្ចេកទេសនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

**៤- ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ**

ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិរបស់រាជរដ្ឋាភិបាល សំដៅដល់ការអភិវឌ្ឍស្អាត ការមិនបំពុលដល់គុណភាពទឹក គុណភាពដី និងគុណភាពខ្យល់ ព្រមទាំងការគ្រប់គ្រងព្រៃឈើ ជលផល ធនធានទឹកជាដើមប្រកបដោយនិរន្តរភាព ដើម្បីការលើកកម្ពស់ជីវភាពរស់នៅនិងសុខុមាលភាពសាធារណៈរបស់ប្រជាជន ដែលជាកត្តាចម្បងក្នុងការលើកស្ទួយសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពទៅនឹងចីរភាពបរិស្ថាន សង្គមនិងវប្បធម៌។

ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖

**៤.១- កសិកម្មបៃតង សន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងអនាម័យ**

ព្រះរាជាណាចក្រកម្ពុជាទទួលបានជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រនិងកង្វះអាហារូបត្ថម្ភ ដោយសារស្ថិរភាពនយោបាយនិងកំណើនសេដ្ឋកិច្ច ក្នុងទសវត្សរ៍កន្លងមក ជាពិសេស នាពេលថ្មីៗនេះ កំណើនសេដ្ឋកិច្ចពឹងផ្អែកលើវិស័យសំខាន់មួយចំនួនដូចជាកសិកម្ម កសិឧស្សាហកម្ម សំណង់ ការនាំចេញសម្លៀកបំពាក់និងវិស័យទេសចរណ៍។ ប្រទេសកម្ពុជាជាប្រទេសងាយរងការប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ហើយផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺងាកទៅរកការកែលម្អសន្តិសុខស្បៀងឲ្យមាននិរន្តរភាព ជាពិសេសសន្តិសុខស្បៀងនៅតាមគ្រួសារនីមួយៗ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

ការកែលម្អសន្តិសុខស្បៀងនិងអនាម័យដែលសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍបៃតងត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖

- កសិកម្មបៃតង : សកម្មភាពនៃកសិកម្មបៃតងគឺជាសុខដុមនីយកម្មរវាងការអភិវឌ្ឍនិងបរិស្ថាន ដូចជាការបង្កើនទិន្នផលស្រូវជាមួយការមិនបង្កឲ្យមានគ្រោះថ្នាក់ដល់បរិស្ថានដែលជាផ្នែកមួយនៃកសិកម្មបៃតង។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវមានផែនការកាត់បន្ថយការប្រើប្រាស់ជីគីមីនិងថ្នាំពុលគីមី ដោយលើកទឹកចិត្តឲ្យមានការប្រើប្រាស់ជីសរីរាង្គ ព្រមទាំងជំរុញនិងលើកទឹកចិត្តដល់ការចូលរួមក្នុងចលនាភូមិមួយ ផលិតផលមួយ
- ការអភិរក្សកសិកម្ម : ការអភិរក្សកសិកម្មគឺពឹងផ្អែកលើការមិនឲ្យមានការខូចខាតដល់គុណភាពដីដែលមានជីជាតិ ព្រមជាមួយការប្រើប្រាស់ជីកំប៉ុស្តិ៍ ការកែលម្អដី ការកាត់បន្ថយការហូរច្រោះដី ជាមួយនឹងការប្រើប្រាស់កម្លាំងពលកម្ម ពេលវេលា និងប្រេងតិច ព្រមទាំងការរក្សាគ្រឿងម៉ាស៊ីនបានល្អនិងយូរអង្វែង។ រាជរដ្ឋាភិបាលបានកំណត់ពីការមិនយកពន្ធលើដីកសិកម្ម ដើម្បីជួយឲ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ កាត់បន្ថយភាពក្រីក្រ និងរក្សាបាននូវប្រពៃណីធ្វើកសិកម្មជានិរន្តរ៍។ ការចេះកែច្នៃនិងការគ្រប់គ្រងដីស្រែរបស់កសិករគឺការដាំស្រូវ ផងនិងដាំដំណាំរួមផ្សំផង ដើម្បីទទួលបានផលិតផលកសិកម្មពីការប្រើប្រាស់ដីពេញមួយឆ្នាំ។ ទន្ទឹមនឹងនេះ ការរៀបចំប្រព័ន្ធត្រួតពិនិត្យគុណភាពចំណីអាហារនិងជំរុញឲ្យមានចំណីអាហារគ្មានគីមី ដោយត្រូវផ្តល់ការលើកទឹកចិត្តដល់អ្នកផលិតចំណីអាហារធម្មជាតិ ដូចជាវិញ្ញាបនបត្របៃតងនិងពានរង្វាន់បៃតងជាដើម
- កសិកម្មអេកូឡូស៊ី : អាស្រ័យដោយវិស័យកសិកម្មរបស់ប្រទេសកម្ពុជាមានភាពងាយរងការប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលត្រូវបង្កើតប្រព័ន្ធកសិកម្មអេកូឡូស៊ីសម្រាប់សន្តិសុខចំណីអាហារដ៏ប្រសើរសម្រាប់រយៈពេលវែង។ ការអនុវត្តប្រព័ន្ធកសិកម្មអេកូឡូស៊ីនេះគឺបង្កើនទិន្នផលខ្ពស់ និងកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។

**៤.២- ការគ្រប់គ្រងធនធានទឹកប្រកបដោយចីរភាព**

ទឹកគឺជាប្រភពធនធានមួយយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍបៃតងនៅកម្ពុជា ដែលមិនអាចចៀសបានសម្រាប់បម្រើផ្នែកកសិកម្ម ការអភិវឌ្ឍធនធានមនុស្ស និងការអភិរក្សប្រព័ន្ធអេកូឡូស៊ី។ ដោយឡែកការគ្រប់គ្រងធនធានទឹកមានបញ្ហាប្រឈមមួយចំនួនចំពោះមុខ ដូចជាបញ្ហាប្រឈមខ្លាំងចំពោះផ្នែកកសិកម្មដែលពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង ដោយត្រូវការផ្គត់ផ្គង់ទឹកឲ្យមានគុណភាពនៅតាមតំបន់ តាមឆ្នាំ និងរដូវដើម្បីកាត់បន្ថយការប៉ះពាល់ដោយសារគ្រោះធម្មជាតិទាក់ទងទៅនឹងទឹកឲ្យដល់កម្រិតអប្បបរមា។ ចំពោះការប្រើប្រាស់ទឹកនៅក្នុងផ្នែកឧស្សាហកម្មនៅកម្ពុជា គឺត្រូវគិតពីសារៈសំខាន់នៃអនាម័យនិងប្រព្រឹត្តកម្មសំណល់រាវ ដើម្បីចូលរួមថែរក្សាប្រព័ន្ធអេកូឡូស៊ីឲ្យមាននិរន្តរភាព ព្រមទាំងការទទួលបាននូវទឹកស្អាតនិងអនាម័យ។

ដើម្បីធានាសន្តិសុខទឹកនិងការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលបានយកគោលនយោបាយទឹកជាគោលនយោបាយអាទិភាពក្នុងការគ្រប់គ្រងធនធានទឹក ប្រភពទឹក រក្សាគុណភាពទឹក និងការពារតំបន់ដីសើមនិងទីជម្រាលសម្រាប់និរន្តរភាពនៃការផ្គត់ផ្គង់ទឹក ដែលត្រូវបែងចែកទៅតាមតម្រូវការនៃការអភិវឌ្ឍនិងអភិរក្សដែលជាលំនឹងនៃប្រព័ន្ធអេកូឡូស៊ី និងជាប្រភពចំណីអាហារប្រកបដោយគុណភាព។ គោលនយោបាយនិងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាជនតាមរយៈការបង្កើតសហគមន៍ប្រើប្រាស់ទឹកនិងយន្តការគ្រប់គ្រងទឹកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចក្ខុវិស័យសម្រាប់សន្តិសុខទឹកសំដៅធានាការប្រើប្រាស់ទឹកនិងធនធានទឹកប្រកបដោយសមធម៌ ប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់ច្រើនយ៉ាងដែលមានគុណភាពជូនប្រជាជន ប្រជាកសិករ សហគ្រាស និងអ្នកប្រើប្រាស់ទូទៅ ដោយឈរលើគោលការណ៍សុវត្ថិភាពទឹក ភាពគ្រប់គ្រាន់នៃធនធានទឹក គុណភាពទឹក អនាម័យ និងតម្លៃសមរម្យ។

ការសិក្សា ស្រាវជ្រាវ និងវិភាគបង្ហាញថា ការគ្រប់គ្រងទឹកនិងធនធានទឹកមានសារៈសំខាន់បំផុតសម្រាប់ទ្រទ្រង់ជីវិត សុខុមាលភាពប្រព័ន្ធអេកូឡូស៊ី សុខភាពបរិស្ថាន និងកំណើនសេដ្ឋកិច្ចសង្គម ហើយវិស័យទឹកកំពុងជួបប្រទះបញ្ហាប្រឈមលើពិភពលោក ពិសេសកង្វះទឹកសាបនិងទឹកទទួលទានដោយសារការខ្សត់កម្រទឹកសាបសម្រាប់ប្រើប្រាស់ និងឥទ្ធិពលអវិជ្ជមានពីគ្រោះធម្មជាតិ ព្រមទាំងបញ្ហាប្រែប្រួលអាកាសធាតុ ពិសេសការកើនឡើងកំដៅភពផែនដីនិងភាពរាំងស្ងួត ដែលគំរាមកំហែងនិងដាក់សម្ពាធយ៉ាងខ្លាំងមកលើជីវិតរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ។ ជាមូលដ្ឋានក្នុងការធានាបាននូវនិរន្តរភាពនៃការផ្គត់ផ្គត់ទឹកប្រកបដោយសុវត្ថិភាពនិងគុណភាពនៅកម្ពុជា ទាមទារឲ្យមានការចូលរួមពេញទំហឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រួមទាំងអ្នកប្រើប្រាស់ទឹកទូទៅ ដោយត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការប្រើប្រាស់ទឹកនានា។

ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព ដែលសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍបៃតងត្រូវមានយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- កសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកឲ្យមានលក្ខណៈបៃតង សម្រាប់ការផ្គត់ផ្គង់ទឹកប្រកបដោយនិរន្តរភាព ដើម្បីបង្ការនិងបញ្ចៀសទឹកជំនន់ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- រៀបចំនិងកសាងអាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធស្រោចស្រព ដើម្បីបង្កើនកសិកម្មបៃតង ឧស្សាហកម្មបៃតង និងពាណិជ្ជកម្មបៃតង ដែលទប់ទល់ទៅនឹងភាពរាំងស្ងួត ព្រមទាំងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងធន់ទ្រាំទៅនឹងអាកាសធាតុ
- ជំរុញការការពារប្រភពទឹកនិងទីជម្រាលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- សាងសង់អាងប្រព្រឹត្តិកម្មសំណល់រាវរួមនៅទីប្រជុំជនរាជធានី ខេត្ត
- គ្រប់គ្រងធនធានទឹកសម្រាប់សន្តិសុខទឹក រាជរដ្ឋាភិបាលត្រូវការស្តារឡើងវិញនិងសាងសង់ប្រព័ន្ធស្រោចស្រព ដោយពឹងផ្អែកលើដីសម្រាប់ផលិតកម្ម ហើយការផ្គត់ផ្គង់ទឹកនិងអនាម័យអនុលោមទៅតាមតម្រូវការចាំបាច់នៅថ្នាក់មូលដ្ឋានរបស់ខ្លួន។ ការទទួលបាននូវទឹកហូបស្អាតនិងអនាម័យនិងការពង្រីកប្រព័ន្ធស្រោចស្រពសម្រាប់ផ្នែកសិកម្ម គឺជួយលើកកម្ពស់ការគ្រប់គ្រងនិងស្តុកទឹកនៅតាមតំបន់នីមួយៗ សម្រាប់ធ្វើស្រែឲ្យបានច្រើនដងក្នុង១ឆ្នាំដោយទទួលបានទិន្នផលខ្ពស់ បង្កើនប្រាក់ចំណូលខ្ពស់ ដែលជាការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមជនបទ
- ការគ្រប់គ្រងធនធានទឹកសម្រាប់ភាពរីកចម្រើនសេដ្ឋកិច្ច ការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងការត្រួតពិនិត្យការប្រើប្រាស់ទឹកទៅតាមផ្នែកនីមួយៗ គឺជាការសម្របសម្រួលយ៉ាងសំខាន់សម្រាប់សហគមន៍ប្រើប្រាស់ទឹក ដែលត្រូវការចាំបាច់ក្នុងសកម្មភាពគ្រប់គ្រងធនធានទឹក

ហើយតម្រូវឲ្យមានការរៀបចំប្រព័ន្ធព្យាករនិងសញ្ញាអាសន្នសម្រាប់គ្រោះធម្មជាតិដែលទាក់ទងនឹងទឹក គឺជាផ្នែកមួយក្នុងការជួយកាត់បន្ថយការខូចខាតដែលនឹងកើតឡើង។ ការជូនដំណឹងជាមុននិងការបង្កើនការយល់ដឹងពីការប្រែប្រួលអាកាសធាតុនិងភាពគ្រោះថ្នាក់ដល់ប្រជាជន គឺអាចកាត់បន្ថយភាពរងគ្រោះដល់ប្រជាជនក្នុងពេលទឹកជំនន់ និងខ្យល់ព្យុះជាដើម

- សមាហរណកម្មប្រព័ន្ធអេកូឡូស៊ីនិងការគ្រប់គ្រងធនធានទឹក ការបង្កើនសមត្ថភាពនៃការសាងសង់អាងប្រព្រឹត្តកម្មសំណល់រាវនិងការគ្រប់គ្រងសំណល់រឹង គឺជាការការពារនិងរក្សានូវតម្លៃប្រព័ន្ធអេកូឡូស៊ីនិងការអភិរក្សធនធានធម្មជាតិ។ ការផ្តល់ទឹកស្អាតជនបទតាមរយៈការជីកអណ្តូងទឹក ស្រះទឹក ថ្នាំសម្លាប់មេរោគ និងការផ្តល់កម្មវិធីអប់រំអនាម័យ។

### ៤.៣- ការគ្រប់គ្រងថាមពលប្រកបដោយប្រសិទ្ធភាពនិងថាមពលកកើតឡើងវិញ

សេដ្ឋកិច្ចប្រទេសកម្ពុជានឹងកើនឡើងនាពេលអនាគត តម្រូវការថាមពលចម្រុះនឹងកើនឡើង។ ការគ្រប់គ្រងថាមពលសម្រាប់ការអភិវឌ្ឍបៃតងគឺត្រូវសន្សំសំចៃថាមពល និងការផ្គត់ផ្គង់ថាមពលចម្រុះបន្ថែមដើម្បីកសាងសង្គមកម្ពុជាឲ្យទៅជាសង្គមមួយបញ្ចេញកាបូនតិចដោយកាត់បន្ថយការប៉ះពាល់ដល់បរិស្ថាន និងចៀសវាងវិបត្តិហិរញ្ញវត្ថុសម្រាប់អ្នកប្រើប្រាស់ ជាពិសេសប្រជាជននៅតាមជនបទ។

ការគ្រប់គ្រងថាមពលនិងថាមពលកកើតឡើងវិញប្រកបដោយប្រសិទ្ធភាព ដែលសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍបៃតង ត្រូវមានយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រេងផូស៊ីល ការប្រើប្រាស់ឧស្ម័នធម្មជាតិសម្រាប់រយៈពេលយូរ គឺមានប្រសិទ្ធភាពផ្គត់ផ្គង់បានច្រើនដល់ទីប្រជុំជនធំៗ ហើយការកែលម្អប្រសិទ្ធភាពប្រើប្រាស់រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មសម្រាប់រយៈពេលវែងដោយរាជរដ្ឋាភិបាលត្រូវកាត់បន្ថយការបំពុលបរិស្ថាន និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីរោងចក្រអគ្គិសនីទាំងនេះ
- ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតំបន់ជនបទ រាជរដ្ឋាភិបាលត្រូវជំរុញការប្រើប្រាស់ជីវឧស្ម័នសម្រាប់តំបន់ជនបទជាមួយនឹងគោលការណ៍អភិវឌ្ឍភូមិបៃតង។ ការពង្រឹងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលនៅតំបន់ជនបទឲ្យមានលក្ខណៈល្អប្រសើរ ត្រូវបង្កើនការគ្រប់គ្រងសំណល់ធម្មជាតិ និងការផលិតជីកំប៉ុស្តិ៍សម្រាប់វិស័យកសិកម្មមាននិរន្តរភាព
- ការបង្កើតបរិស្ថានពាណិជ្ជកម្មបៃតងជាមួយបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផលិតថាមពល ត្រូវបានជំរុញឲ្យមានការប្រកួតប្រជែងសម្រាប់ការប្រើប្រាស់ថាមពលកកើតឡើងវិញ ការកែលម្អប្រសិទ្ធភាពថាមពល និងការអភិវឌ្ឍឧស្សាហកម្មបៃតង។

### ៤.៤- ការគ្រប់គ្រងនិងការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព

ដីគឺជាធនធានធម្មជាតិមួយដែលបម្រើឲ្យកិច្ចដំណើរការអភិវឌ្ឍ ទៅតាមតម្រូវការផ្សេងៗរបស់មនុស្ស ហើយកំណើនប្រជាជនត្រូវឲ្យមានការពង្រីកផ្ទៃដីប្រើប្រាស់ និងតម្រូវការដីសម្រាប់ការសាងសង់នៅទីប្រជុំជន និងជនបទ។ ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រនេះឲ្យទទួលបានជោគជ័យ ក្រសួងមានសមត្ថកិច្ចត្រូវមានផែនការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការដាំដំណាំកសិឧស្សាហកម្ម ការគ្រប់គ្រងព្រៃឈើ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការបង្កើតសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ការរៀបចំផែនការអភិវឌ្ឍនិងវិនិយោគ និងការអភិវឌ្ឍរបស់ផ្នែកឯកជន។

ការជំរុញការកំណត់តំបន់សម្រាប់ជាមូលដ្ឋាននៃការធ្វើផែនការប្រើប្រាស់ដីធ្លី និងកំណត់តំបន់គ្រប់គ្រងបរិស្ថានក្នុងតំបន់ការពារធម្មជាតិ ព្រមទាំងសិក្សាពីសក្តានុពលធម្មជាតិ ដើម្បីបង្កើតតំបន់ការពារធម្មជាតិ

ថ្នាក់ខេត្ត។ យុទ្ធសាស្ត្រនេះគាំទ្រ ជំរុញ និងចូលរួមអនុវត្តក្នុងកម្មវិធីការងារចុះបញ្ជីដីរដ្ឋនៅតាមតំបន់ការពារធម្មជាតិ តំបន់ឆ្នេរ តំបន់ព្រៃការពារ តំបន់ឧស្សាហកម្ម តំបន់ទេសចរណ៍ និងការប្រើប្រាស់ដីផ្សេងៗសម្រាប់តម្រូវការជាសាធារណៈ ដោយត្រូវមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។

រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី ដើម្បីសម្រេចគោលការណ៍នៃការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ដោយបានកំណត់យ៉ាងច្បាស់លាស់រវាងដីសម្បទានសេដ្ឋកិច្ចនិងដីសម្រាប់ប្រើប្រាស់ជាឯកជនរបស់ប្រជាជនដូចជាដីកសិកម្មនិងដីលំនៅឋានជាដើម។

ភាពជោគជ័យនៃកំណែទម្រង់ដីធ្លីស៊ីជម្រៅរបស់រាជរដ្ឋាភិបាល សំដៅធ្វើឲ្យកាន់តែច្បាស់លាស់ដីកម្មសិទ្ធិរបស់ប្រជាកសិករតាមពាក្យស្លោករបស់រាជរដ្ឋាភិបាល "**មិនមានកសិករអត់ដីធ្វើស្រែ**" កំណត់បែងចែកដីកាន់តែច្បាស់លាស់នូវដីស្រែ ចម្ការសម្រាប់កសិករ និងដីសម្បទានសេដ្ឋកិច្ចកសិឧស្សាហកម្មឬសម្បទានសេដ្ឋកិច្ចផ្សេងទៀត ដើម្បីលើកទឹកចិត្តដល់វិនិយោគិន ដីព្រៃឈើសម្រាប់អភិរក្ស និងដីព្រៃឈើទុកជាព្រៃឈើអចិន្ត្រៃយ៍សម្រាប់យកផលនិងអនុផល ក៏ដូចជាការត្រៀមដីទុកសម្រាប់ដីសម្បទានសង្គមកិច្ចធានាដល់ការបែងចែកដីជូនប្រជាកសិករកាន់តែមានប្រសិទ្ធភាព។

### ៤.៤.១- ការអភិរក្ស គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព

ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំយុទ្ធសាស្ត្រ និងផែនការបែងចែក និងកំណត់តំបន់គ្រប់គ្រងសម្រាប់ការពារធនធានធម្មជាតិ ដូចជា ធនធានរ៉ែ ព្រៃឈើ ទឹក និងជលផល ដោយធ្វើឲ្យមានតុល្យភាពរវាងការអភិរក្សនិងការអភិវឌ្ឍ ដើម្បីលើកស្ទួយសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចជនបទ។ ការពង្រឹងនិងការជំរុញលើការអភិរក្សធនធានព្រៃឈើនិងជីវៈចម្រុះ សម្រាប់បម្រើសេវាកម្មសេដ្ឋកិច្ចបរិស្ថានតាមរយៈការអនុវត្តគម្រោង**ឥណទានកាបូន** ជាកត្តាមួយនៃការអភិវឌ្ឍបៃតង ក៏ដូចជាការចូលរួមអនុវត្តឲ្យបានជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយគ្រប់គ្រងវិស័យជលផល ព្រៃឈើ រ៉ែ និងថាមពល។

### ៤.៤.២- ការប្រើប្រាស់តំបន់ឆ្នេរសមុទ្រកម្ពុជា

ឆ្នេរសមុទ្រប្រទេសកម្ពុជាមានប្រវែងប្រមាណ៤៤០គីឡូម៉ែត្រ លាតសន្ធឹងតាមបណ្តោយខេត្តជាប់មាត់សមុទ្រចំនួន៤គឺ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប។ ឆ្នេរសមុទ្រកម្ពុជាជាកន្លែងទេសចរណ៍ល្អប្រណីតដោយមានឆ្នេរខ្សាច់ពណ៌សស្អាត ហើយមានខ្យល់អាកាសបរិសុទ្ធផ្តល់នូវផាសុកភាព ដោយហេតុនេះហើយ ឆ្នេរសមុទ្រកម្ពុជាបានចូលជាសមាជិកពេញសិទ្ធិក្នុងក្លឹបឆ្នេរសមុទ្រដែលស្អាតជាងគេលើពិភពលោក កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ កន្លងមក។

ការគ្រប់គ្រងតំបន់ឆ្នេរឲ្យមាននិរន្តរភាពដែលសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍបៃតង ត្រូវមានយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនដែលរស់នៅក្បែរតំបន់ឆ្នេរ
- ការកំណត់តំបន់ឆ្នេរសមុទ្រសម្រាប់គោលដៅអភិវឌ្ឍន៍និងការអភិរក្ស
- រៀបចំការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ ក្នុងគោលដៅសាងសង់ហេដ្ឋារចនាសម្ព័ន្ធ លំនៅឋានសំណង់សាធារណៈនិងឯកជនសម្រាប់បម្រើវិស័យទេសចរណ៍ ព្រមទាំងការប្រើប្រាស់ដីសម្រាប់ផ្នែកកសិកម្ម និងការអភិវឌ្ឍតំបន់ឧស្សាហកម្ម ជាដើម
- ធ្វើការសិក្សា វាយតម្លៃ និងវិភាគឲ្យបានលម្អិតពីសកម្មភាពទាំងឡាយនៅតាមឆ្នេរសមុទ្របណ្តោយឆ្នេរសមុទ្រ ដៃសមុទ្រ ស្ទឹង ព្រែក(ដែលតភ្ជាប់នឹងសមុទ្រ) និងកោះ
- ការគ្រប់គ្រងធនធានទឹកសមុទ្រនិងធនធានដែលពាក់ព័ន្ធនឹងទឹកសមុទ្រ

- ធ្វើការផ្សព្វផ្សាយនិងអប់រំពីការអភិវឌ្ឍបៃតងនៅតំបន់ឆ្នេរដល់សាធារណជនទូទៅ។

**៤.៥- ការអភិរក្សនិងការគ្រប់គ្រងជលផលប្រកបដោយនិរន្តរភាព**

ច្បាប់ស្តីពីជលផលឆ្នាំ២០០៦និងគោលនយោបាយស្តីពីការបង្កើនធនធានមច្ឆជាតិ ក៏ដូចជាលិខិតបទដ្ឋានពាក់ព័ន្ធ បាននិងកំពុងកែលម្អឡើងវិញឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីថែរក្សានិងបង្កើនធនធានមច្ឆជាតិទឹកសាបនិងទឹកប្រៃ។ រដ្ឋបាលជលផលដោយមានការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាពិសេស រដ្ឋបាលថ្នាក់ក្រោមជាតិ បានពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងធនធានជលផលដោយមានការចូលរួមពីប្រជានេសាទ តាមរយៈសហគមន៍នេសាទ។

ដោយសារៈសំខាន់នៃជលផលនិងធនធានជីវៈចម្រុះទាំងនៅក្នុងទឹកសាប ទាំងក្នុងទឹកប្រៃគឺជាប្រភពអាហារដែលផ្តល់នូវប្រូតេអ៊ីនដ៏សម្បូរបែបនិងចាំបាច់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននិងការនាំចេញក្រសួង ស្ថាប័នពាក់ព័ន្ធបានសហការគ្រប់គ្រងជលផលតាមច្បាប់ស្តីពីជលផលនិងគោលនយោបាយដើម្បីរក្សាឲ្យមាននិរន្តរភាព ទោះបីជាយើងមានច្បាប់និងគោលនយោបាយយ៉ាងណាក្តី ក៏ភាពអនាធិបតេយ្យនេសាទខុសច្បាប់ ការធ្វើអាជីវកម្មខុសច្បាប់ និងការបំផ្លិចបំផ្លាញធនធានជលផលនៅតែបន្ត។

សកម្មភាពកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផលបង្កើនស្តុកត្រីធម្មជាតិឲ្យបានល្អប្រសើរ ធានាបាននូវសន្តិសុខស្បៀងនិងរួមចំណែកដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានរៀបចំបែងចែកតំបន់ដែលត្រូវអភិរក្សមានជាអាទិ៍ តំបន់សហគមន៍នេសាទ តំបន់ប្រជានេសាទ តំបន់អភិរក្សជលផល និងតំបន់នេសាទសាធារណៈព្រមទាំងលើកកម្ពស់ការទទួលខុសត្រូវដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

ផ្អែកលើកំណែទម្រង់វិស័យជលផលស៊ីជម្រៅថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទដើម្បីទុកជូនប្រជាជនធ្វើការនេសាទជាលក្ខណៈគ្រួសារ ហើយជំរុញឲ្យមានកំណើនស្តុកជលផលបានកើនឡើងវិញ ដែលប្រជាជនអាចប្រើប្រាស់ធនធានទាំងនេះក្នុងភាពជាម្ចាស់។

ផលត្រីនេសាទបាននៅឆ្នាំ២០១២ និងដើមឆ្នាំ២០១៣បង្ហាញឲ្យឃើញថាត្រីមានភាពសម្បូរជាងឆ្នាំណាៗទាំងអស់ តម្លៃទីផ្សារត្រីចុះថោកជាងឆ្នាំមុនៗនិងថេរ ហើយបានធ្វើឲ្យកម្រិតអតិផរណាថយចុះ។

**៤.៦- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍បៃតង**

ការបង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគឺជាកត្តាមួយដ៏សំខាន់ក្នុងប្រទេសកម្ពុជា ដោយសារបញ្ហាប្រឈមជាច្រើនដែលពិបាកដោះស្រាយបានលើការងារគមនាគមន៍នេះ ដូចជា ការកកស្ទះចរាចរណ៍ កង្វះការដឹកជញ្ជូនសាធារណៈ ការរំលោភច្បាប់ចរាចរណ៍ កង្វះការត្រួតពិនិត្យចំនួនយានយន្តនៅតាមដងផ្លូវ និងការទុកចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើងមិនអាចផ្តល់បានគ្រប់គ្រាន់ ដែលបង្កឲ្យមានការបញ្ចេញឧស្ម័នពុលទៅក្នុងបរិយាកាស។ ដូច្នេះ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះឲ្យទទួលបានជោគជ័យ ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចជាការកំណត់លម្អដងផ្លូវបៃតង ការដាំដើមឈើនិងអភិរក្សព្រៃឈើ ការចែករំលែកការដឹកជញ្ជូនបៃតងដោយប្រើប្រាស់រថយន្តក្រុង រថភ្លើងដើរដោយចរន្តអគ្គិសនី ការប្រើប្រាស់យានយន្តដែលប្រើថាមពលកកើតឡើងវិញ ក៏ដូចជាការប្រើកង់និងម៉ូតូអគ្គិសនី សម្រាប់ការធ្វើដំណើរក្នុងទីប្រជុំជន ព្រមទាំងតម្រូវឲ្យមានការវិភាគការបញ្ចេញឧស្ម័នពីយានយន្តជាទៀងទាត់។

**៤.៧- ការអភិវឌ្ឍទេសចរណ៍បៃតង**

រាជរដ្ឋាភិបាលបានប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាពនិងចីរភាព ដោយផ្អែកលើបរិយាកាសសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាពសង្គម និងការអភិវឌ្ឍបៃតង។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រទេសចរណ៍បៃតង ការជំរុញទេសចរណ៍វប្បធម៌និងធម្មជាតិកម្ពុជាឲ្យក្លាយទៅជាគោលដៅទេសចរណ៍លំដាប់ពិភពលោកប្រកបដោយភាពបៃតង រួមទាំងតំបន់ទេសចរណ៍បៃតងសេវាកម្មបៃតង ភ្ញៀវទេសចរបៃតង ការផ្គត់ផ្គង់ម្ហូបអាហារបៃតង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតងសម្រាប់

បម្រើឲ្យវិស័យទេសចរណ៍ បរិស្ថានបៃតង ផលិតផលកសិកម្មនិងឧស្សាហកម្មបៃតង ការដឹកជញ្ជូនបៃតង ស្របតាមពាក្យស្លោក "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"។

ការអភិវឌ្ឍទេសចរណ៍បៃតង ជួយជំរុញនិងទាក់ទាញអ្នកទេសចរជាតិនិងអន្តរជាតិឲ្យមកទស្សនាតំបន់ទេសចរណ៍វប្បធម៌និងធម្មជាតិកាន់តែច្រើននិងស្នាក់នៅរយៈពេលយូរ ដោយសារភាពទាក់ទាញនៃផលិតផល ចំណីអាហារ ការស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធនានាមានលក្ខណៈបៃតងនិងមានផាសុកភាព។

ការអភិវឌ្ឍទេសចរណ៍បៃតងដែលសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍបៃតង ត្រូវមានយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ជំរុញវិស័យទេសចរណ៍ឲ្យមានសក្តានុពលជាវិជ្ជមានដល់សេដ្ឋកិច្ចជាតិ
- រៀបចំការអភិវឌ្ឍទេសចរណ៍ដើម្បីទប់ទល់នឹងបញ្ហាប្រឈមនៃវិបត្តិហិរញ្ញវត្ថុ
- ពង្រីកទេសចរណ៍បៃតងសម្រាប់បង្កើតនូវការងារបៃតង
- រៀបចំការអភិវឌ្ឍទេសចរណ៍សម្រាប់គាំទ្រដល់សេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ
- ជំរុញការអភិវឌ្ឍវិស័យអេកូទេសចរណ៍និងទេសចរណ៍សហគមន៍
- លើកទឹកចិត្តការវិនិយោគលើទេសចរណ៍បៃតងជួយកាត់បន្ថយលើការចំណាយទៅលើការប្រើប្រាស់ថាមពល ទឹក សំណល់ និងរក្សាតម្លៃប្រព័ន្ធអេកូឡូស៊ីនិងបេតិកភណ្ឌជាតិ
- ជំរុញការអភិវឌ្ឍទេសចរណ៍ទីក្រុងដោយផ្អែកលើទស្សនាទានទីក្រុងស្អាត ទីក្រុងបៃតង
- ទាក់ទាញភ្ញៀវទេសចរលើការអភិវឌ្ឍទេសចរណ៍បៃតងតាមរយៈការលើកកម្ពស់គុណភាពផលិតផលនិងសេវាកម្មទេសចរណ៍
- ការចូលរួមនិងការគាំទ្រផ្នែកឯកជនលើទេសចរណ៍បៃតង
- សក្តានុពលសេដ្ឋកិច្ចសម្រាប់ទេសចរណ៍បៃតងគឺផ្អែកលើសហគ្រាសធុនតូចនិងមធ្យម
- ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍សម្រាប់ទេសចរណ៍បៃតង
- ការលើកទឹកចិត្តដល់វិស័យឯកជនលើទេសចរណ៍បៃតង
- លើកទឹកចិត្តអ្នកទេសចរណ៍ក្នុងគមនាគមន៍បៃតង។

### ៤.៨- លើកកម្ពស់គុណភាពបរិស្ថាន

គុណភាពបរិស្ថានសំដៅដល់បរិស្ថានគ្មានការបំពុល ដូចជា គុណភាពទឹក គុណភាពដី គុណភាពខ្យល់ ការរំខានដោយសំឡេងនិងរំញ័រ ព្រមទាំងការគ្រប់គ្រងសំណល់គ្រប់ប្រភេទបានត្រឹមត្រូវ។ គុណភាពទាំងនេះជួយដល់គុណភាពចំណីអាហារ និងការផ្គត់ផ្គង់ចំណីអាហារដោយនិរន្តរភាពដែលបំពេញសេចក្តីត្រូវការរបស់ប្រជាជន ព្រមទាំងលើកកម្ពស់សុខុមាលភាពអេកូឡូស៊ីផ្សារភ្ជាប់និងសុខភាពសាធារណៈ តាមរយៈអនាម័យបរិស្ថាននិងចំណីអាហារ។

ការលើកកម្ពស់គុណភាពបរិស្ថាន ពឹងផ្អែកទៅលើការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ ការត្រួតពិនិត្យការបំពុលទឹក និងការត្រួតពិនិត្យការបំពុលខ្យល់ ព្រមទាំងត្រូវអនុវត្តទៅតាមបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចការពារគុណភាពបរិស្ថាននិងសុខភាពសាធារណៈ។ រាជរដ្ឋាភិបាលត្រូវប្រកាន់យកគោលការណ៍កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ និងទាញយកធនធានពីសំណល់ ព្រមទាំងគោលការណ៍បង់ថ្លៃសម្រាប់អ្នកបង្កើតសំណល់ច្រើននិងអ្នកបំពុលបរិស្ថាន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល ត្រូវលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងសារធាតុបំពុលខ្យល់ ការគ្រប់គ្រងការបំពុលខ្យល់ ការរំខានដោយសំឡេងនិងរំញ័រ ព្រមទាំងពង្រីកការតាមដាននិងការត្រួតពិនិត្យការបំពុលទាំងនេះនៅតាមតំបន់គោលដៅ។ ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់គុណភាពបរិស្ថាន រាល់ការអភិវឌ្ឍទាំង

ផ្នែកសាធារណៈនិងឯកជន ត្រូវតែបន្តការបំពាក់អាងប្រព្រឹត្តិកម្មសំណល់រាវនៅតាមបណ្តារោងចក្រសហគ្រាស សាងសង់អាងស្តុកសំណល់មកពីបង្គន់ក្នុងតំបន់អភិវឌ្ឍន៍ ប្រព័ន្ធប្រព្រឹត្តិកម្មបំប្លែងលាមកទៅជាជីធម្មជាតិ ការរៀបចំទីលានចាក់សំរាមថ្មីនិងកសាងរោងចក្រកែច្នៃសំរាមនិងសំណល់សរីរាង្គតាមក្រុងសំខាន់ៗ ការរៀបចំឡដុតសំណល់វេជ្ជសាស្ត្រនៅតាមបណ្តាមន្ទីរពេទ្យ ព្រមទាំងសាងសង់រោងចក្រផលិតទឹកស្អាតខ្នាតតូចនិងមធ្យមក្នុងទីប្រជុំជននិងនៅទីក្រុងសំខាន់ៗ។

### ៥. ការបណ្តុះបណ្តាលធនធានមនុស្សនិងការអប់រំបៃតង

ការបណ្តុះបណ្តាលធនធានមនុស្សជាកត្តាសំខាន់ក្នុងការអភិវឌ្ឍបៃតងកម្ពុជាប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលជួបនឹងបញ្ហាប្រឈម ដូចជាកង្វះខាតធនធានមនុស្សទាក់ទងនឹងការអភិវឌ្ឍបៃតងទាំងផ្នែកសាធារណៈ ផ្នែកឯកជន និងផ្នែកសង្គមស៊ីវិល នៅពេលដែលការអភិវឌ្ឍកាន់តែមានកំណើនយ៉ាងខ្លាំងដោយទាមទារឲ្យមានធនធានមនុស្សទាំងបរិមាណ ទាំងគុណភាព ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍបៃតង។

**ការបណ្តុះបណ្តាលធនធានមនុស្សនិងការអប់រំបៃតងត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

#### ៥.១. ការជំរុញការអប់រំនៃការអភិវឌ្ឍបៃតងនៅក្នុងប្រព័ន្ធ

- ការបង្កើតឲ្យមានការអប់រំពីការអភិវឌ្ឍបៃតងនៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត ដើម្បីបញ្ជ្រាបការអភិវឌ្ឍបៃតងឲ្យកាន់តែស៊ីជម្រៅដល់ស្រទាប់សិស្សានុសិស្សនិងនិស្សិតឲ្យក្លាយទៅជាយុវជនបៃតងតាមសាលា
- ការបង្កើតគ្រឹះស្ថានសិក្សាអភិវឌ្ឍន៍បៃតងថ្នាក់ជាតិ ជាការទាក់ទាញអ្នកវិនិយោគ អ្នកផ្តល់ជំនួយ ដៃគូអភិវឌ្ឍនានា និងប្រទេសជាសមាជិកអង្គការអន្តរជាតិបៃតងឲ្យជួយដល់វិស័យអប់រំនៅកម្ពុជា។

#### ៥.២. ការជំរុញការអប់រំនៃការអភិវឌ្ឍបៃតងនៅក្រៅប្រព័ន្ធ

- ការបណ្តុះបណ្តាលការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌក្រៅប្រព័ន្ធដល់ផ្នែកសាធារណៈ ឯកជននៅតាមទីក្រុង ភូមិ ឃុំ និងទីប្រជុំជន ដើម្បីបង្កើនសមត្ថភាពយល់ដឹងពីការអភិវឌ្ឍបៃតងដល់មន្ត្រីរាជការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឲ្យក្លាយជាយុវជនបៃតងតាមក្រសួង ស្ថាប័ន។
- ការបណ្តុះបណ្តាលដល់ស្រទាប់យុវជននិងយេនឌ័រនៅតាមភូមិ ឃុំ ដើម្បីឲ្យក្លាយទៅជាយុវជនបៃតង យុវជនបៃតងតាមភូមិ ដែលជាយុវជនបៃតងគំរូនិងជាទំពាំងស្នងឫស្សីក្នុងការបន្តវេនលើការអភិវឌ្ឍបៃតង។

#### ៥.៣. ការផ្លាស់ប្តូរចំណេះដឹង បទពិសោធ និងបច្ចេកទេសបៃតង

- បង្កើតបណ្តាញការងារអភិវឌ្ឍន៍បៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ផ្លាស់ប្តូរបទពិសោធនិងចែករំលែកចំណេះដឹង ដើម្បីប្រមូលការគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍបៃតងនៅកម្ពុជា
- ផ្លាស់ប្តូរបទពិសោធនិងបច្ចេកទេសបៃតងពីការអភិវឌ្ឍបៃតង រវាងប្រទេសក្នុងតំបន់អាស៊ានប្រទេសសមាជិកវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(អង្គការGGGI) និងពិភពលោក។

#### ៥.៤. ការផ្សព្វផ្សាយនិងអប់រំតាមប្រព័ន្ធព័ត៌មាន

- ការផ្តល់ព័ត៌មានពីការអភិវឌ្ឍបៃតងដល់សាធារណជនទូទៅ តាមរយៈប្រព័ន្ធផ្សព្វផ្សាយពីការអភិវឌ្ឍបៃតង
- បង្កើតឲ្យមានកម្មវិធីនិងវេទិកាជជែកពិគ្រោះយោបល់ពីការអភិវឌ្ឍបៃតងក្នុងចំណោមសិស្សានុសិស្ស និស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រ
- បង្កើតឲ្យមានមជ្ឈមណ្ឌលសារព័ត៌មានបៃតង បណ្ណាល័យបៃតង ប្រព័ន្ធព័ត៌មានវិទ្យាបៃតង និងវិទ្យាស្ថានស្រាវជ្រាវបៃតង។

## ៦- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព

ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតកម្មវិធីអប់រំផ្សព្វផ្សាយដោយបញ្ចូលបច្ចេកវិទ្យាបៃតងដែលនាំមកនូវការប្រើប្រាស់ធនធានធម្មជាតិតិច រក្សាគុណភាពបរិស្ថាន បង្កើនផលិតភាពនិងគុណភាព ដោយផ្អែកលើតម្រូវការទីផ្សារ និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការប្រើប្រព័ន្ធបច្ចេកទេសនិងបច្ចេកវិទ្យាបៃតង រួមមានបច្ចេកវិទ្យាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាត និងបច្ចេកវិទ្យាសម្រាប់ការកែច្នៃ និងការប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើរួច។

**ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាពត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

### ៦.១- ការបំពាក់បច្ចេកវិទ្យាបៃតង

- ការអភិវឌ្ឍលើវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផល និងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង ត្រូវបំពាក់ដោយបច្ចេកវិទ្យាបៃតង
- ផ្លាស់ប្តូរនិងផ្ទេរបច្ចេកវិទ្យាបៃតងរវាងផ្នែកសាធារណៈនិងផ្នែកឯកជន តាមរយៈកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល និងអង្គការអន្តរជាតិ ព្រមទាំងជាមួយបណ្តាប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍ
- ជំរុញពាណិជ្ជកម្មលើបច្ចេកវិទ្យាបៃតងក្នុងវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផល និងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង។

### ៦.២- ការបណ្តុះបណ្តាលបច្ចេកវិទ្យាបៃតង

- លើកទឹកចិត្តនិងគាំទ្រដល់អ្នកស្រាវជ្រាវបច្ចេកវិទ្យាបៃតងទាំងផ្នែកសាធារណៈ ផ្នែកឯកជន និងសង្គមស៊ីវិល ក្នុងការអនុវត្តបច្ចេកវិទ្យាបៃតង
- ផ្តល់នូវចំណេះដឹងអំពីបច្ចេកវិទ្យាបៃតង
- ចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាបៃតងនៅក្នុងសិក្ខាសាលាជាតិនិងអន្តរជាតិ
- រៀបចំវគ្គបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាបៃតង។

### ៦.៣- ការវិនិយោគលើបច្ចេកវិទ្យាបៃតង

- លើកទឹកចិត្តដល់វិនិយោគិនក្នុងការបណ្តាក់ទុនលើបច្ចេកវិទ្យាបៃតងក្នុងវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផល និងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព
- ជំរុញការបង្កើតបច្ចេកវិទ្យាបៃតងថ្មី។

## ៧- ជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង

ឈរលើបទពិសោធដ៏ជោគជ័យបំផុតនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលបានផ្តល់នូវកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងសេដ្ឋកិច្ច បរិស្ថាន សង្គម និង វប្បធម៌ រាជរដ្ឋាភិបាលដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ ទឹក ដីធ្លី ព្រៃឈើ ជលផល រ៉ែ និងថាមពល ដើម្បីនិរន្តរភាពនិងភាពគង់វង្សសម្រាប់អ្នកជំនាន់ក្រោយ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព និងកំណែទម្រង់លើវិស័យដីធ្លី ព្រៃឈើ និងជលផលស៊ីជម្រៅ កំពុងជំរុញប្រទេសឈានទៅរកការអភិវឌ្ឍសេដ្ឋកិច្ចបៃតងគំរូដែលទទួលស្គាល់ជាសង្គមមួយដែលមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមខ្ពស់ ដោយបញ្ចេញកាបូនតិច ឆ្ពោះទៅកាន់ការកសាងសុវត្ថិភាពសង្គមវប្បធម៌បៃតងដ៏យូរអង្វែង។

ជោគជ័យប្រកបដោយមោទនភាពនេះ បានលើកទឹកចិត្តនិងជំរុញឲ្យរាជរដ្ឋាភិបាលខិតខំបន្ថែមទៀតសំដៅធានាប្រព័ន្ធសុវត្ថិភាពសង្គមមួយមានលក្ខណៈបៃតង តាមគោលការណ៍អភិវឌ្ឍបៃតង។

**ជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតងត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

### ៧.១- សុវត្ថិភាពសង្គមវប្បធម៌បៃតង

សុវត្ថិភាពនេះសំដៅដល់ការកសាងសង្គមមួយ ដែលឈរលើទិសដៅជាយុទ្ធសាស្ត្រអភិវឌ្ឍបៃតងដោយផ្តើមចេញពីសង្គមដែលបញ្ចេញកាបូនតិច ចីរភាពបរិស្ថាន និរន្តរភាពធនធានធម្មជាតិ និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងធន់ទ្រាំទៅនឹងអាកាសធាតុ ដោយប្រើប្រព័ន្ធគាំពារសង្គមនិងមធ្យោបាយអភិវឌ្ឍបៃតង សេដ្ឋកិច្ចបៃតង រួមជាមួយបច្ចេកវិទ្យាបៃតង លើកកម្ពស់សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ដែលសុវត្ថិភាពនេះពឹងផ្អែកលើសសរទ្រូងនៃការអភិវឌ្ឍប្រទេស ពិសេសយុវជនបៃតង មាតាបៃតង និងស្រទាប់មហាជនបៃតងទូទៅ ប្រកបដោយសមភាពយេនឌ័រ។

### ៧.២- ការគាំពារសង្គម

ការគាំពារសង្គមផ្តោតលើគោលនយោបាយនិងទីផ្សារការងារ ការធានារ៉ាប់រងសង្គមដោយមានភាគទាន (ប្រាក់សោធននិវត្ត ការធានារ៉ាប់រងសុខភាព បេឡាជាតិសន្តិសុខសង្គម ការគាំពារសន្តិសុខសង្គម) សំណាញ់សុវត្ថិភាពសង្គមដោយពុំមានភាគទាន និងសេវាកម្មសុខុមាលភាពសង្គមបន្ថែម។

កិច្ចគាំពារសង្គមនេះមានប្រសិទ្ធភាពផ្អែកលើសំណាញ់សុវត្ថិភាពសង្គម កំណើនសេដ្ឋកិច្ចបៃតង-សេដ្ឋកិច្ចខៀវថេរ និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី។ សំណាញ់សុវត្ថិភាពសង្គមសំដៅដល់កម្មវិធីសំណង់សាធារណៈ(សាច់ប្រាក់ឬស្បៀងពលកម្ម) ការឧបត្ថម្ភជាសាច់ប្រាក់ឬសម្ភារៈ ការឧបត្ថម្ភធនដើម្បីទទួលបានការសម្រួលមធ្យោបាយសាធារណៈ សុខភាព និងផ្ទះសម្បែង ស្របតាមយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះរបស់រាជរដ្ឋាភិបាល។

ការលើកកម្ពស់ការគាំពារសង្គម ក៏ដូចសង្គមវប្បធម៌បៃតង ពិតជាពឹងផ្អែកលើគុណភាពជីវិតនិងសុខភាពបរិស្ថាន និងការលើកកម្ពស់សុខុមាលភាពស្ត្រី កុមារ យុវជន ជនពិការ ប្រជាកសិករ ជនជាតិដើមភាគតិច ចាស់ជរា និងសហគមន៍ តាមរយៈកំណើនសេដ្ឋកិច្ចបៃតងនិងប្រព័ន្ធសុវត្ថិភាពសង្គមបៃតង។ ការចូលរួមពីសាធារណជននៅក្នុងកិច្ចគាំពារសង្គមធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈប្រសិទ្ធភាពអភិវឌ្ឍន៍ដោយមានគុណភាពជាមួយនឹងគុណភាពជីវិត សំណាញ់សុវត្ថិភាពសង្គមបៃតង និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី។

ដូច្នេះ ការងារទាំងអស់នេះធានាដល់ប្រព័ន្ធសុវត្ថិភាពសង្គមនិងការលើកកម្ពស់ដល់គុណភាពបរិស្ថាន សុខភាពប្រព័ន្ធអេកូឡូស៊ី និងសុខភាពសាធារណៈប្រកបដោយគុណភាព ដើម្បីលើកទឹកចិត្តនិងការពារសុខុមាលភាពរបស់ប្រជាជន។

## ៨. ការរក្សានិងការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិ

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦ សំដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិនិងសម្បត្តិវប្បធម៌ទូទៅ។ ច្បាប់នេះផ្តល់អាទិភាពខ្ពស់ទៅលើការថែរក្សានិងអភិវឌ្ឍន៍សម្បត្តិបេតិកភណ្ឌវប្បធម៌ និងលើកតម្កើងស្នាដៃបុរាណ។ ជាការរួមចំណែកដល់កិច្ចការពារបេតិកភណ្ឌវប្បធម៌ រាជរដ្ឋាភិបាលបានបង្កើតយន្តការគ្រប់គ្រងបេតិកភណ្ឌមនុស្សរស់ សំដៅថែរក្សានិងលើកទឹកចិត្តដល់ស្នាដៃឥស្សរជនបេតិក-ភណ្ឌក្នុងគោលដៅរក្សានិងផ្សព្វផ្សាយវប្បធម៌ល្អប្រសើររបស់ជាតិឲ្យនៅគង់វង្ស ស្របតាមអនុសញ្ញាស្តីពីកិច្ចការពារបេតិកភណ្ឌអរូបី និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាផ្សេងទៀតដែលធានាបានកម្មសិទ្ធិបញ្ញា ជាពិសេសការការពារតក្កកម្ម ម៉ាក ពាណិជ្ជនាម គំនិតច្នៃប្រឌិត និងបង្កើតថ្មីទាំងឡាយ។ ការអនុវត្តបទប្បញ្ញត្តិខាងលើ គឺដើម្បីឲ្យបេតិកភណ្ឌវប្បធម៌ជាតិមានភាពស្ថិតស្ថេរ និងត្រូវរក្សាបានគង់វង្ស ដោយផ្តោតលើការថែរក្សា ការពារ ការអភិរក្ស និងការអភិវឌ្ឍនូវសម្បត្តិវប្បធម៌ជាតិទូទៅស្របតាមការរីកចម្រើនរបស់ជាតិនិងសកម្មភាពសេដ្ឋកិច្ចសកលភាវូបនីយកម្ម ឈរលើគោលការណ៍អភិវឌ្ឍន៍បៃតង។

តាមរយៈការធ្វើសមាហរណកម្មកម្ពុជាស៊ីជម្រៅនៅក្នុងតំបន់អាស៊ាន ក៏ដូចជាពិភពលោក ទីកន្លែងសក្ការៈបូជា ជំនឿ សាសនា ប្រពៃណី និងប្រាសាទបុរាណនានា ពិសេសប្រាសាទអង្គរវត្ត ប្រាសាទអង្គរធំ ប្រាសាទបាខែង ប្រាសាទបន្ទាយស្រី និងប្រាសាទព្រះវិហារ ព្រមទាំងរមណីយដ្ឋានធម្មជាតិ ទឹកជ្រោះ ព្រៃភ្នំ បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ ក្លាយជាគោលដៅទេសចរណ៍ធម្មជាតិបៃតង ដែលទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិឲ្យចូលមកទស្សនា ធ្វើពាណិជ្ជកម្ម និងវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាជាច្រើន ដែលធ្វើឲ្យកំណើនចំណូលជាតិពីវិស័យទេសចរណ៍ធម្មជាតិនិងវប្បធម៌ បានកើនឡើងប្រមាណ១ ៧៨៦លានដុល្លារអាមេរិក ឆ្នាំ២០១០ និងប្រមាណ១ ៨៥០ លានដុល្លារអាមេរិកឆ្នាំ២០១១ ហើយនៅឆ្នាំ២០២០ ត្រូវបានព្យាករថាកើនឡើងដល់ប្រមាណ៥ ០០០លានដុល្លារអាមេរិក។

តាមផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ១០១២-២០៣០ ប្រទេសកម្ពុជាឈានឡើងជាប្រទេសអភិវឌ្ឍ ឈរលើបទពិសោធដ៏ជោគជ័យបំផុតនៃនយោបាយឈ្នះ ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលរក្សាបានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងកំណើនម៉ាក្រូសេដ្ឋកិច្ចថេរ។ សព្វថ្ងៃនេះ សមិទ្ធផលដ៏អស្ចារ្យផ្តើមចេញពីការអនុវត្តដ៏ជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ បានធ្វើឲ្យការអភិវឌ្ឍបៃតងក្លាយជាកត្តាលីករស្នូល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឲ្យដើរទន្ទឹមនឹងកិច្ចការពារបរិស្ថាន ដើម្បីកាត់បន្ថយភាពក្រីក្រទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាពខ្ពស់ និងលើកកម្ពស់គុណភាពជីវិតរបស់ ប្រជាជនទូទៅ។

ការសម្រេចបាននូវទិសដៅនៃការអភិវឌ្ឍបៃតង ចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទាំងអស់ ទាំងផ្នែកសាធារណៈ ទាំងផ្នែកឯកជន តាមរយៈការអនុវត្តគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ដើម្បីជំរុញការអភិវឌ្ឍបៃតងកម្ពុជាឆ្ពោះទៅរកសង្គមវប្បធម៌បៃតងរុងរឿង ដែលធ្វើឲ្យអភិវឌ្ឍន៍បៃតងទទួលស្គាល់ជាមធ្យោបាយគ្រឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ការការពារបរិស្ថាន ការការពារនិងថែរក្សាសម្បត្តិវប្បធម៌ជាតិ រួមទាំងបេតិកភណ្ឌវប្បធម៌រូបីនិងអរូបី។

ជាពិសេស ការកសាងសេដ្ឋកិច្ចសង្គមដែលបញ្ចេញកាបូនតិច ការគ្រប់គ្រងបានធនធានធម្មជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងនិងខៀវប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ពិតជាជួយកម្ពុជាឲ្យរក្សាបាននូវបេតិកភណ្ឌជាតិនិងសម្បត្តិវប្បធម៌ជាតិឲ្យមានលក្ខណៈបៃតងគង់វង្ស និងស្ថិតស្ថេរដែលកាត់បន្ថយនូវឋានភាពក្រីក្រមួយកម្រិតធំ បង្កើនភាតរភាពសង្គម សមភាពយេនឌ័រ និងសមធម៌ ដោយមានកំណើនម៉ាក្រូសេដ្ឋកិច្ចថេរ ស្របពេលជាមួយនឹងការរក្សាបាននូវសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។

យុទ្ធសាស្ត្របេតិកភណ្ឌវប្បធម៌បែតងនេះ ផ្ដោតសំខាន់ប្រែក្លាយប្រាសាទបុរាណបេតិកភណ្ឌវប្បធម៌ជាតិ និងរមណីយដ្ឋានធម្មជាតិឲ្យក្លាយទៅជាគោលដៅទេសចរណ៍មាសបៃតង ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០របស់រាជរដ្ឋាភិបាល និងដោយរក្សាបាននូវអត្តសញ្ញាណវប្បធម៌ជាតិ ដើរទន្ទឹមនឹងការអភិវឌ្ឍនិងអភិរក្សនិងដែលបានលើកតម្កើងតម្លៃនិងផ្ដល់នូវសោភណភាពបៃតង។

**ការរក្សានិងការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

**៨.១- ការរក្សានិងការពារវប្បធម៌បៃតង**

- ផ្លាស់ប្ដូរបទពិសោធ ចំណេះដឹង និងបច្ចេកវិទ្យាបៃតង ដែលជួយលើកតម្កើងការយល់ដឹងអំពីតម្លៃវប្បធម៌ ទាំងសម្បត្តិវប្បធម៌មានលក្ខណៈធម្មជាតិ ទាំងសម្បត្តិវប្បធម៌ជាស្នាដៃរបស់មនុស្ស
- រក្សា ការពារ អភិរក្ស ធ្វើទំនើបកម្ម និងធ្វើសមាហរណកម្មនូវបេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌវប្បធម៌អរូបី និងវប្បធម៌សង្គមបៃតង តាមរយៈពិធីភាវូនីយកម្មវប្បធម៌និងការផ្លាស់ប្ដូរវប្បធម៌ សាសនា ប្រពៃណី ទំនៀមទម្លាប់រស់នៅ ទេសចរណ៍ កីឡា អប់រំ របកគំហើញថ្មី និងបច្ចេកវិទ្យាបៃតង
- លើកតម្កើងកិត្យានុភាពជាតិនិងរក្សាអត្តសញ្ញាណជាតិ ឈរលើគោលការណ៍និងវឌ្ឍនភាពបៃតង នៅក្នុងវិស័យកសិកម្មបៃតង ពាណិជ្ជកម្មបៃតង ឧស្សាហកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង សំណង់អគារបៃតង ឧបករណ៍ហិរញ្ញវត្ថុបៃតង វិនិយោគបៃតង និងទីផ្សារហិរញ្ញវត្ថុបៃតង ជាដើម។

**៨.២- ការអភិរក្សបេតិកភណ្ឌវប្បធម៌បៃតង**

- ការអភិរក្សកេរដំណែលសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬកើតចេញពីធម្មជាតិ ឬរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ ដែលជាស្នាដៃរបស់មនុស្ស និងផលិតផលរបស់ធម្មជាតិ ដោយមានលក្ខណៈវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា និងលក្ខណៈធម្មជាតិបៃតង
- ការបង្កើនវឌ្ឍនភាពសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌របស់ប្រទេស ផ្សារភ្ជាប់ទៅនឹងការវិវត្តនៃអភិវឌ្ឍន៍បៃតង
- ជំរុញអាជីវកម្មជឿនលឿនតាមបែបធម្មជាតិដែលឆ្លុះបញ្ចាំងពីសម្បត្តិវប្បធម៌បៃតងជាតិទាំងឡាយ ដើម្បីផលប្រយោជន៍ជូនប្រជាជន និងប្រទេសជាតិទាំងមូល។

**៨.៣- ការលើកតម្កើងបេតិកភណ្ឌវប្បធម៌អរូបីបៃតង**

- លើកកម្ពស់និងលើកទឹកចិត្តដល់ការប្រតិបត្តិ ការសម្ដែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍វត្ថុ ដែលមានប្រភពសិប្បនិម្មិត លម្អបៃតង និងពិធីភាវូបនីយកម្មវប្បធម៌ទទួលស្គាល់ និងទទួលយកក្នុងសង្គម
- ជំរុញការបន្តវេនពីជំនាន់មួយទៅជំនាន់មួយនូវបេតិកភណ្ឌវប្បធម៌អរូបីបៃតង និងរាល់ស្នាដៃទាំងឡាយ
- លើកទឹកចិត្តដល់ការបង្កើតថ្មីឡើងវិញជាអចិន្ត្រៃយ៍នូវបេតិកភណ្ឌវប្បធម៌អរូបីបៃតង ដោយឈរលើគោលការណ៍អភិវឌ្ឍន៍បៃតង
- បង្កើនសុខដុមនីយកម្មរបស់មនុស្សជាមួយនឹងធម្មជាតិ ព្រមទាំងជាមួយនឹងប្រវត្តិសាស្ត្រភូមិសាស្ត្រ ជំនឿ សាសនា ប្រពៃណី ទំនៀមទន្លាប់ និងអក្សរសាស្ត្ររបស់ពួកគេ
- ផ្លាស់ប្ដូរនិងផ្ទេរស្នាដៃនិងគំនិតច្នៃប្រឌិត សម្រាប់រួមចំណែកក្នុងការជំរុញឲ្យមានការគោរពវប្បធម៌ប្លែកៗគ្នា និងភាពចេះបង្កើតថ្មីរបស់មនុស្ស។

### ៩- អភិបាលកិច្ចលើការអភិវឌ្ឍបៃតង

អភិបាលកិច្ចគឺជាកត្តាមិនអាចខ្វះបាននៅក្នុងចលនាអភិវឌ្ឍន៍បៃតង។ ការងារនេះទាមទារឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនិងសាធារណជនទូទៅ។ ការយល់ដឹងពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងទាមទារឲ្យមានការផ្សព្វផ្សាយគោលនយោបាយនិងការស្វែងយល់។ គោលការណ៍អភិបាលកិច្ចបៃតងត្រូវបញ្ជ្រាបចូលទៅក្នុងស្រទាប់យុវជនបៃតង សិស្សានុសិស្ស និងជនបៃតងគំរូ តាមរយៈខ្លឹមសារ ស្មារតីនៃលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ សំដៅធានាឲ្យបាននូវតម្លាភាពនៃការគ្រប់គ្រងដឹកនាំ ការទទួលខុសត្រូវ គណនេយ្យភាព និងប្រសិទ្ធភាព។ រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់**សម្តេចនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩ ក្រោមការដឹកនាំសម្របសម្រួលផ្ទាល់របស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាលទ្ធផលកើតចេញមកពីជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ ច្បាប់ស្តីពីការបោះឆ្នោតឃុំសង្កាត់ ច្បាប់ស្តីពីរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត។ តាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩នេះ អភិបាលកិច្ចផ្តោតលើកំណែទម្រង់ស្ថាប័នស៊ីជម្រៅ ដើម្បីប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ ដែលធានាបាននូវការកាត់បន្ថយភាពក្រីក្រប្រកបដោយជោគជ័យ ផ្អែកលើការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងមុខងារនៃស្ថាប័ននេះ ដែលផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាពឡើង និងអភិវឌ្ឍបានឆាប់រហ័សតាមបែបប្រជាធិបតេយ្យ។ ភាពចាំបាច់និងប្រសិទ្ធភាពនៃអភិបាលកិច្ចនេះ គឺដើម្បីលើកកម្ពស់គណនេយ្យភាព តម្លាភាព ការទទួលខុសត្រូវថ្នាក់ក្រោមជាតិ ការចែករំលែកព័ត៌មាន ការផ្សព្វផ្សាយគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ពិសេសទាក់ទងនឹងការបញ្ជ្រាបយេនឌ័រអភិវឌ្ឍន៍បៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលជារួម ជំរុញឲ្យមានម៉ាក្រូសេដ្ឋកិច្ចចីរ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងធន់ទ្រាំទៅនឹងអាកាសធាតុ ហើយកាត់បន្ថយភាពក្រីក្រ។

ជាជំហានៗ យុទ្ធសាស្ត្របញ្ជ្រាបអភិវឌ្ឍន៍បៃតងនឹងចូលរួមចំណែកក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈដោយឈរលើគោលការណ៍នៃគោលនយោបាយស្តីពីសេវាសាធារណៈរបស់រាជរដ្ឋាភិបាល។ មន្ត្រីរាជការនឹងមានការយល់ដឹងខ្ពស់អំពីតួនាទីនិងភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន នៅក្នុងការផ្តល់សេវាសាធារណៈជូនប្រជាជនក្នុងគោលដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើងទៅតាមពាក្យស្លោក "មន្ត្រីរាជការស៊ីវិលមានវប្បធម៌មិនមែនជាអ្នកត្រួតត្រា តែជាអ្នកផ្តល់សេវា"។ ក្នុងនេះ អភិបាលកិច្ចបៃតងមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល ហើយនឹងត្រូវសមាហរណកម្មទៅក្នុងរាល់សកម្មភាពនៃការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រទាំងនេះ ក្នុងគោលដៅបង្កើនប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសក្តិសិទ្ធិនៅក្នុងផ្នែកសាធារណៈនិងឯកជន។

អភិបាលកិច្ចបៃតងសំដៅលើអភិបាលកិច្ច ការគ្រប់គ្រង និងដឹកនាំ ទាំងស្ថាប័ន ទាំងនីតិបុគ្គល ដើម្បីសម្រេចបាននូវទិសដៅជាយុទ្ធសាស្ត្រទាំងអស់នេះរួមមាន ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានគុណភាពជាមួយបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ ការបណ្តុះបណ្តាលធនធានមនុស្ស និងការអប់រំបៃតង ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព ការជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង និងការរក្សានិងការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិ។

អភិបាលកិច្ចរួមមានទាំងផ្លូវការទាំងមិនផ្លូវការ ទាក់ទងនឹងអាជ្ញាធរកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងផ្នែកឯកជន ហើយគុណភាពរបស់វាពឹងផ្អែកលើបដិការស៊ីជម្រៅ ការជឿជាក់ និងភាពត្រឹមត្រូវតាមច្បាប់។ អភិបាលកិច្ចនេះត្រូវបានជំរុញដោយយន្តការនិងឱកាសនៃការសម្របសម្រួលចរចា និង

ការរៀបចំត្រឹមត្រូវនៅផ្នែកសាធារណៈ ផ្នែកឯកជន និងផ្នែកសង្គមស៊ីវិល។ ចំពោះអាជ្ញាធរថ្នាក់មូលដ្ឋានត្រូវមានការទទួលខុសត្រូវចំពោះមុខតាមឋានានុក្រម បទបញ្ជា និងវិធានហិរញ្ញវត្ថុក្នុងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធបៃតង ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងគោលការណ៍អភិវឌ្ឍន៍ទីក្រុងប្រកបដោយនិរន្តរភាព។

តាមគោលការណ៍នៃការអភិវឌ្ឍបៃតងធានាបាននូវអភិបាលកិច្ចនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិអនុវត្តការងារប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវ ព្រមទាំងពង្រឹងនយោបាយការបរទេសស្តីអំពីការអភិវឌ្ឍបៃតង ព្រមទាំងការធ្វើសមាហរណកម្មការអភិវឌ្ឍបៃតងនៅគ្រប់ថ្នាក់ពាក់ព័ន្ធ។

**អភិបាលកិច្ចលើការអភិវឌ្ឍបៃតងត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖**

**៩.១. ការជំរុញកិច្ចសហប្រតិបត្តិការលើអភិបាលកិច្ចរវាងស្ថាប័នបៃតងជាតិនិងអន្តរជាតិ**

- ផ្លាស់ប្តូរបទពិសោធដឹកនាំនិងគ្រប់គ្រងលើការអភិវឌ្ឍបៃតងជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល បណ្តាប្រទេសជាសមាជិកនៃអង្គការអន្តរជាតិនិងស្ថាប័នអន្តរជាតិនានា
- ការកសាងភាពជាដៃគូជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធររាជធានី ខេត្ត និងអង្គការជាតិនានា ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពលើការអភិវឌ្ឍបៃតង
- ប្រើប្រាស់បច្ចេកវិទ្យាបៃតង ដើម្បីឲ្យអភិបាលកិច្ចបៃតងមានប្រសិទ្ធភាព។

**៩.២. ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងគោលនយោបាយ**

- រៀបចំក្របខ័ណ្ឌគតិយុត្តនិងផែនការសកម្មភាពនានាឲ្យមានលក្ខណៈបៃតង
- ពិនិត្យឡើងវិញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់
- ជំរុញអភិបាលកិច្ចបៃតងទៅលើរាល់ទិសដៅយុទ្ធសាស្ត្រ
- រៀបចំធ្វើលិខិតបទដ្ឋានស្តីពីការអភិវឌ្ឍបៃតង។

**៩.៣. កសាងសមត្ថភាពធនធានមនុស្ស**

- ពង្រឹងសមត្ថភាពអភិបាលកិច្ចបៃតងទាំងថ្នាក់ជាតិនិងថ្នាក់រាជធានី ខេត្ត
- ការអប់រំការអភិវឌ្ឍបៃតងតាមរយៈការពង្រឹងសមត្ថភាពដល់គ្រូបង្រៀនគ្រប់កម្រិត
- បណ្តុះបណ្តាលជនបង្គោលអភិបាលកិច្ចបៃតង ដើម្បីបង្កើនការយល់ដឹង ផ្លាស់ប្តូរបទពិសោធនិងបញ្ជ្រាបគោលការណ៍អភិបាលកិច្ចបៃតងទៅក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**៩.៤. ការកៀរគរធនធានហិរញ្ញវត្ថុនិងមូលនិធិអភិវឌ្ឍន៍**

- ទាក់ទាញវិនិយោគិនបរទេសដើម្បីជំរុញអភិបាលកិច្ចបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- កៀរគរគ្រប់ធនធានហិរញ្ញវត្ថុទាំងអស់ទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ ពិសេសពីដៃគូអភិវឌ្ឍនានា ក៏ដូចជាវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដើម្បីអនុវត្តអភិបាលកិច្ចបៃតងនៅគ្រប់ទិសដៅយុទ្ធសាស្ត្រ
- លើកទឹកចិត្តដល់ផ្នែកឯកជនឲ្យអនុវត្តអភិបាលកិច្ចបៃតងនៅក្នុងការវិនិយោគរបស់ខ្លួន ក៏ដូចជាក្នុងការធ្វើពាណិជ្ជកម្មនិងការអនុវត្តគម្រោងនានា ដើម្បីប្រសិទ្ធភាពប្រើប្រាស់ធនធាននិងការសម្រេចបាននូវគោលដៅរបស់ខ្លួន។

**៩.៥. ការលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវ**

- បញ្ជ្រាបការយល់ដឹងពីគោលការណ៍អភិបាលកិច្ចបៃតងដល់ស្រទាប់មន្ត្រីរាជការស៊ីវិល មន្ត្រីសាធារណៈ យុវជនបៃតង សមភាពយេនឌ័រ រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជនដើម្បីបង្កើននូវមនសិការវិជ្ជាជីវៈ ការទទួលខុសត្រូវចំពោះសេវាសាធារណៈដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- លើកទឹកចិត្តប្រតិភូកម្មអំណាច ធនធានហិរញ្ញវត្ថុ និងការទទួលខុសត្រូវ តាមរយៈការកំណត់ឲ្យមានផែនការសកម្មភាពការងារ សំដៅធានាប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃគុណភាពសេវា

- លើកកម្ពស់សិទ្ធិទទួលបានព័ត៌មាននានាទាក់ទងនឹងការអភិវឌ្ឍបៃតង តាមរយៈការផ្លាស់ប្តូរបទពិសោធ ការចែករំលែកព័ត៌មាន ការផ្សព្វផ្សាយ ការបង្កើនចំណេះដឹង ការគាំទ្រ និងការចូលរួមអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតង ក៏ដូចអភិបាលកិច្ចបៃតងនៅគ្រប់ស្រទាប់ទាំងអស់ ពិសេសនៅក្នុងទិសដៅអភិវឌ្ឍន៍បៃតងទាំងអស់។

## ៦. សកម្មភាពការងារ

### ៦.១. រចនាសម្ព័ន្ធស្ថាប័ន

រៀបចំពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍បៃតងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍបៃតង។

### ៦.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត

រៀបចំនិងបង្កើតនូវលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងការអភិវឌ្ឍបៃតង ដូចជាច្បាប់ស្តីពីការអភិវឌ្ឍបៃតង ជាដើម។

### ៦.៣. ផែនការសកម្មភាពអភិវឌ្ឍន៍បៃតង

តាមការបង្ហាញពីភាពខ្លាំង បញ្ហាប្រឈម និងការអនុវត្តយុទ្ធសាស្ត្រ ឈានទៅសម្រេចបានចក្ខុវិស័យនៃការអភិវឌ្ឍបៃតង រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង ដើម្បីជំរុញការអភិវឌ្ឍបៃតងកម្ពុជាស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានកំណត់។ ការអនុវត្តផែនការសកម្មភាពការងារនៃផែនការយុទ្ធសាស្ត្រនេះមានពីរដំណាក់កាលគឺ(១) សម្រាប់រយៈពេលខ្លីឆ្នាំ២០១៣-២០១៧(៣ឆ្នាំទៅ៥ឆ្នាំ) ដោយត្រូវខិតខំប្រឹងប្រែង អនុវត្តឲ្យបាន និង(២) សម្រាប់រយៈពេលមធ្យមនិងវែងឆ្នាំ២០១៨-២០៣០(៦ឆ្នាំទៅ១៣ឆ្នាំ) ដើម្បីនិរន្តរភាពនៃ ការអភិវឌ្ឍសេដ្ឋកិច្ច ឲ្យមានតុល្យភាពទៅនឹងបរិស្ថាន សង្គម និងវប្បធម៌។ ការអនុវត្តនេះគឺចាំបាច់ត្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងសាធារណជនទូទៅ។

#### ៦.៣.១. ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- ធ្វើការទាក់ទាញវិនិយោគិនបៃតងលើថាមពលកកើតឡើងវិញ ទឹក ដីធ្លី ព្រៃឈើ និងជលផលព្រមទាំងសហគ្រាសនិងពាណិជ្ជកម្មបៃតង នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការបញ្ជ្រាបការអភិវឌ្ឍបៃតងទៅក្នុងប្រព័ន្ធសេដ្ឋកិច្ច ធនាគារ និងហិរញ្ញវត្ថុ
- ធ្វើការចេញវិញ្ញាបនបត្របៃតងជូនក្រុមហ៊ុន សហគ្រាស សណ្ឋាគារ ភោជនីយដ្ឋាន អង្គការគ្រឹះស្ថានហិរញ្ញវត្ថុ ធនាគារវិនិយោគ និងធនាគារពាណិជ្ជ ដែលជួយការពារថែរក្សាបរិស្ថាន និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព
- ធ្វើការលើកកម្ពស់អាជីវកម្មនិងឧស្សាហកម្មបៃតង ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង
- រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយពាណិជ្ជកម្មបៃតង
- ពង្រីកការលក់ដូរផលិតផលបៃតង នៅក្នុងស្រុកនិងក្រៅស្រុក
- លើកទឹកចិត្តដល់អ្នកវិនិយោគដែលផលិតផលបៃតង ពិសេសផលិតផលកសិកម្មគ្មានសារធាតុគីមី
- បង្កើនឱកាសការងារបៃតងជូនសាធារណជន តាមរយៈការងារទេសចរណ៍បៃតង ការងារបរិស្ថានបៃតង ការងារថាមពលបៃតង ការងារកសិកម្មបៃតង ការងារឧស្សាហកម្មបៃតង ការងារបច្ចេកវិទ្យាបៃតង ការងារពាណិជ្ជកម្មបៃតង និងសេវាកម្មបៃតង

- ជួយសម្រួលដល់ការវិនិយោគពាក់ព័ន្ធនិងការផ្ទេរ ការផ្លាស់ប្តូរបច្ចេកវិទ្យាទាំងឡាយសម្រាប់ផលិតកម្មបៃតងនិងទីផ្សារបៃតង
- បញ្ជ្រាបក្របខ័ណ្ឌផលិតកម្មនិងការប្រើប្រាស់ដោយចីរភាពនៅក្នុងគម្រោងវិនិយោគទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិ
- ប្រើប្រាស់ធនធានធម្មជាតិដោយអនុវត្តគោលការណ៍អ្នកបំពុលជាអ្នកបង់ថ្លៃ
- ធ្វើកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុផ្នែកឯកជននិងសាធារណៈ ដោយអនុវត្តគោលការណ៍អភិបាលកិច្ច
- រៀបចំគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធីនិងគម្រោងសាកល្បងបៃតង នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការបែងចែកថវិកាទៅតាមវិស័យនីមួយៗ នៃការអភិវឌ្ឍបៃតងឲ្យមានប្រសិទ្ធភាព
- ធ្វើការជំរុញការប្រើប្រាស់ថវិកាផ្នែកឯកជននិងសាធារណៈឲ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពទៅតាមវិស័យអភិវឌ្ឍន៍នីមួយៗ ដើម្បីឈានដល់គោលដៅអភិវឌ្ឍន៍បៃតងជាតិ
- ធ្វើការតាមដានត្រួតពិនិត្យ ការបែងចែក និងប្រើប្រាស់ថវិកា ទាំងផ្នែកឯកជន ទាំងសាធារណៈ ដើម្បីធានាការអភិវឌ្ឍបៃតងជាតិឲ្យមានប្រសិទ្ធភាព
- រៀបចំមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតងសម្រាប់ការអភិវឌ្ឍបៃតង នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បញ្ជ្រាបមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតងទៅក្នុងប្រព័ន្ធគណនីជាតិ
- ធ្វើការតាមដានត្រួតពិនិត្យគណនីនិងហិរញ្ញវត្ថុ ទាក់ទងនឹងការអភិវឌ្ឍបៃតង។

**៦.៣.២- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពជាមួយបរិស្ថាន**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយសេដ្ឋកិច្ចបៃតង
- រៀបចំកសាងប្រភេទពន្ធដារបៃតងទៅតាមគោលការណ៍អភិវឌ្ឍន៍បៃតង
- រៀបចំសូចនាករដើម្បីបង្ហាញពីកំណើនសេដ្ឋកិច្ចបៃតងផ្អែកលើគោលការណ៍អភិវឌ្ឍន៍បៃតង
- រៀបចំយន្តការគ្រប់គ្រងក្នុងដំណាក់កាលអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតងឲ្យមានប្រសិទ្ធភាព
- ធ្វើការកែលម្អគុណភាពអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព ដោយបង្កើនផលិតភាពនិងបរិមាណផលិតផល
- ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចប្រពៃណីទៅកាន់សេដ្ឋកិច្ចបៃតង ដើម្បីបញ្ជ្រាប បន្ស៊ី និងបន្សុំាគ្នារវាងសេដ្ឋកិច្ចនិងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយប្រសិទ្ធភាព
- បង្កើតហេដ្ឋារចនាសម្ព័ន្ធប្រសិទ្ធភាពបៃតង តាមរយៈការធ្វើផែនការសេដ្ឋកិច្ចបៃតង
- បង្កើតឱកាសពាណិជ្ជកម្មបៃតងនៅថ្នាក់ជាតិ
- ពង្រឹងដល់កិច្ចការពារសុខុមាលភាពស្ត្រី កុមារ យុវជន ជនពិការ ប្រជាកសិករ ជនជាតិដើមភាគតិច ចាស់ជរា និងសហគមន៍ តាមរយៈកំណើនសេដ្ឋកិច្ចបៃតងនិងប្រព័ន្ធសុវត្ថិភាពសង្គមបៃតង
- ធ្វើការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច
- រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយហិរញ្ញវត្ថុបៃតង
- ធ្វើការបញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតងទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារ

- រៀបចំនីតិវិធីនិងការគ្រប់គ្រងលទ្ធកម្មបៃតង
- រៀបចំគម្រោងឥណទាន កម្ចីបៃតងឈរលើគោលការណ៍អភិវឌ្ឍន៍បៃតងនៅតាមបណ្ដាក្រុមហ៊ុនហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា
- រៀបចំប្រព័ន្ធសេវាកម្មបៃតង តាមរយៈម៉ាស៊ីនស្វ័យប្រវត្តសម្រាប់ដក ដាក់សាច់ប្រាក់នៅក្នុងបណ្ដាគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធបៃតងក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ ដោយប្រើបច្ចេកវិទ្យាបៃតង អគារបៃតង និងលម្អបៃតង
- ប្រើប្រព័ន្ធបច្ចេកវិទ្យាបៃតង ដើម្បីគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការគណនេយ្យនិងលំហូរហិរញ្ញវត្ថុ
- បង្កើតបរិយាកាសអំណោយផលនៅតាមបណ្ដាក្រុមហ៊ុនហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុបៃតងនៅថ្នាក់ជាតិនិងក្រោមជាតិ
- ធ្វើការពង្រឹងទីផ្សារហិរញ្ញវត្ថុឲ្យមានលក្ខណៈបៃតង
- ផ្ដល់ការចូលរួមរបស់សាធារណជន និងប្រជាជនទូទៅ ឲ្យប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារបៃតង
- កាត់បន្ថយភាពក្រីក្រទូទាំងប្រទេស តាមរយៈការផ្ដល់សេវាកម្មហិរញ្ញវត្ថុនិងធនាគារបៃតង ព្រមទាំងផលិតផលបៃតង ដូចជា ប្រតិបត្តិការហិរញ្ញវត្ថុស្អាតស្អំ ជំនាញហិរញ្ញវត្ថុ និងធនាគារបៃតង សេវាកម្មបៃតង អត្រាការប្រាក់សម្រាប់គុណភាពបរិស្ថាន ផ្ដើមចេញពីក្រុមហ៊ុនហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា
- រៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្ត សម្រាប់ការទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន
- ធ្វើការជំរុញផលិតភាពនៃសេវាប្រព័ន្ធអេកូឡូស៊ី នៅតាមបណ្ដាតំបន់ការពារធម្មជាតិ តំបន់អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរ
- ធ្វើការជំរុញការអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតង នៅតាមបណ្ដាតំបន់ការពារធម្មជាតិ តំបន់អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរ
- ប្រើប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន ជាឧបករណ៍លើកទឹកចិត្តដល់សហគមន៍មូលដ្ឋាននិងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីឲ្យចូលរួមការពារនិងថែរក្សាធនធានធម្មជាតិឲ្យមាននិរន្តរភាព
- បង្កើតយន្តការកម្រៃសេវាការពារប្រព័ន្ធបរិស្ថាន ឈរលើគោលការណ៍អភិវឌ្ឍន៍បៃតង។
- បញ្ជ្រាបប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថានទៅក្នុងការអភិវឌ្ឍបៃតងលើគ្រប់វិស័យអភិវឌ្ឍន៍ទាំងអស់
- ធ្វើការទាញយកទីផ្សារលក់ឥណទានកាបូន តាមរយៈការអនុវត្តការទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន នៅតាមបណ្ដាតំបន់ការពារធម្មជាតិ តំបន់អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើការសម្របសម្រួលដល់ការកំណត់តំបន់ ដើម្បីបែងចែកជាតំបន់សម្រាប់ផលិតភាពនៃសេវាការពារប្រព័ន្ធបរិស្ថាន
- តាមដានត្រួតពិនិត្យវិនិយោគទាំងផ្នែកឯកជននិងផ្នែកសាធារណៈ ដើម្បីប្រសិទ្ធភាពនៃសេដ្ឋកិច្ចបៃតងនិងការកាត់បន្ថយភាពក្រីក្រ។

### ៦.៣.៣- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- ធ្វើការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងអន្តរជាតិ ដើម្បីពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមានតុល្យភាពជាមួយបរិស្ថាននិងសង្គមក្នុងតំបន់សមុទ្រ
- ការគ្រប់គ្រងធនធានសមុទ្រ តំបន់ឆ្នេរ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឲ្យមានសុវត្ថិភាព ចីរភាព និងនិរន្តរភាព
- ការអភិរក្សនិងការប្រើប្រាស់ធនធានសមុទ្រប្រកបដោយនិរន្តរភាព
- ធ្វើការគ្រប់គ្រងលើការបំពុលសមុទ្រនិងប្រព័ន្ធអេកូឡូស៊ីពាក់ព័ន្ធ
- អង្កេតតាមដាន និងការធ្វើអធិការកិច្ចលើគុណភាពទឹកសមុទ្រដែលមានសារធាតុអាស៊ីដ
- ធ្វើការលើកទឹកចិត្តដល់អ្នកវិទ្យាសាស្ត្រស្រាវជ្រាវដែលរកឃើញនូវសារធាតុបំពុលទឹកសមុទ្រ និងថែរក្សាគុណភាពទឹកសមុទ្រ
- ការបង្កើនទិន្នផលស្តុកត្រីឲ្យដល់កម្រិតអតិបរមា និងការធ្វើវារីវប្បកម្មសមុទ្រ ដើម្បីផ្តល់នូវការផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់ដោយសម្រេចបាននូវគោលដៅការអភិវឌ្ឍបៃតង
- ពង្រឹងសមត្ថភាពការអភិរក្សនិងការគ្រប់គ្រងបរិស្ថានសមុទ្រប្រកបដោយនិរន្តរភាព
- សិក្សា ស្រាវជ្រាវ និងវិភាគពីការប្រែប្រួលអាកាសធាតុដែលនាំឲ្យមានការឡើងកម្ពស់ទឹកសមុទ្រនិងការហូរច្រោះឆ្នេរ
- រៀបចំទុកជាមុន បង្ការ និងការពារពីគ្រោះមហន្តរាយនៅតំបន់សមុទ្រ។

### ៦.៣.៤- ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- ពង្រឹងការអភិវឌ្ឍកសិកម្មបៃតង ការអភិរក្សកសិកម្ម និងកសិកម្មអេកូឡូស៊ី
- បំផុសបំផុលដល់ការចូលរួមក្នុងចលនាភូមិមួយ ផលិតផលមួយ
- ធ្វើការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ ការត្រួតពិនិត្យការបំពុលទឹក និងការត្រួតពិនិត្យការបំពុលខ្យល់
- អនុវត្តគោលការណ៍ការកាត់បន្ថយ ការប្រើប្រាស់ និងការកែច្នៃឡើងវិញ និងទាញយកធនធានពីសំណល់
- គោលការណ៍បង់ថ្លៃសម្រាប់អ្នកបង្កើតសំណល់ច្រើននិងអ្នកបំពុលបរិស្ថាន
- ការគ្រប់គ្រងធនធានទឹកសម្រាប់សន្តិសុខទឹកនិងភាពរីកចម្រើនសេដ្ឋកិច្ច
- ពង្រឹងលើការអភិរក្សធនធានព្រៃឈើនិងជីវៈចម្រុះ សម្រាប់បម្រើសេវាកម្មសេដ្ឋកិច្ចបរិស្ថានតាមរយៈការអនុវត្តគម្រោងឥណទានកាបូន
- ធ្វើការកំណត់តំបន់ឆ្នេរសមុទ្រសម្រាប់គោលដៅអភិវឌ្ឍន៍និងការអភិរក្ស
- ធ្វើការរៀបចំការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ
- ធ្វើការសិក្សា វាយតម្លៃ និងវិភាគឲ្យបានលម្អិតពីសកម្មភាពនានាទាក់ទងនឹងតំបន់ឆ្នេរសមុទ្រ និងតំបន់ពាក់ព័ន្ធនឹងឆ្នេរ
- គ្រប់គ្រងធនធានទឹកសមុទ្រនិងធនធានដែលពាក់ព័ន្ធនឹងទឹកសមុទ្រ
- ធ្វើការផ្សព្វផ្សាយនិងអប់រំពីការអភិវឌ្ឍបៃតងនៅតំបន់ឆ្នេរដល់សាធារណជនទូទៅ
- រៀបចំផែនការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាពសម្រាប់វិស័យទេសចរណ៍ កសិកម្ម ឧស្សាហកម្ម និងដីលំនៅឋាន
- រៀបចំផែនការអភិវឌ្ឍនិងវិនិយោគនិងការអភិវឌ្ឍរបស់ផ្នែកឯកជន

- ធ្វើការជំរុញការប្រើប្រាស់ប្រេងផូស៊ីលប្រកបដោយប្រសិទ្ធភាព និងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតំបន់ជនបទ
- ធ្វើការប្រកួតប្រជែងពីការប្រើប្រាស់ថាមពលកកើតឡើងវិញ ការកែលម្អប្រសិទ្ធភាពថាមពល និងការអភិវឌ្ឍឧស្សាហកម្មបៃតង សម្រាប់ផ្នែកសាធារណៈនិងផ្នែកឯកជន
- កសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- អនុវត្តការដឹកជញ្ជូនបៃតងដោយប្រើប្រាស់រថយន្តក្រុង រថភ្លើងដើរដោយចរន្តអគ្គិសនី ការប្រើប្រាស់កង់និងម៉ូតូអគ្គិសនីសម្រាប់ការធ្វើដំណើរក្នុងទីប្រជុំជន
- ធ្វើការវិភាគការបញ្ចេញឧស្ម័នពីយានយន្តនៅទីប្រជុំ រាជធានី ខេត្ត
- ពង្រឹងការអភិវឌ្ឍវិស័យទេសចរណ៍ ដើម្បីទប់ទល់នឹងបញ្ហាប្រឈមនៃវិបត្តិហិរញ្ញវត្ថុ
- ពង្រឹងវិស័យទេសចរណ៍ដែលគាំទ្រដល់សេដ្ឋកិច្ចមូលដ្ឋាននិងការកាត់បន្ថយភាពក្រីក្រ
- ធ្វើការលើកទឹកចិត្តដល់ផ្នែកឯកជនក្នុងការគាំទ្រដល់ទេសចរណ៍បៃតង
- ធ្វើការជំរុញការអភិវឌ្ឍទេសចរណ៍នៅក្នុងសហគ្រាសធុនតូចនិងមធ្យម។

### ៦.៣.៥- ការបណ្តុះបណ្តាលធនធានមនុស្សបៃតង

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- កសាងសមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនគំនិតនិងព័ត៌មានស្តីពីបញ្ហាពាណិជ្ជកម្មឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្មបៃតង
- បញ្ចូលការអប់រំពីការអភិវឌ្ឍបៃតងនៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត
- កសាងគ្រឹះស្ថានសិក្សាអភិវឌ្ឍន៍បៃតងនៅកម្រិតថ្នាក់ជាតិ
- ធ្វើការបណ្តុះបណ្តាលការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌក្រៅប្រព័ន្ធដល់ផ្នែកសាធារណៈ ឯកជន និងនៅតាមភូមិឃុំ
- រៀបចំនិងបង្កើតបណ្តាញការងារអភិវឌ្ឍន៍បៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ផ្លាស់ប្តូរបទពិសោធនិងចែករំលែកចំណេះដឹងពីការអភិវឌ្ឍបៃតងនៅកម្ពុជា
- ផ្លាស់ប្តូរបទពិសោធនិងបច្ចេកទេសបៃតងពីការអភិវឌ្ឍបៃតងរវាងប្រទេសក្នុងតំបន់អាស៊ាន ប្រទេសសមាជិកវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(អង្គការGGGI) និងពិភពលោក
- ផ្តល់ព័ត៌មានពីការអភិវឌ្ឍបៃតងដល់សាធារណជនទូទៅ តាមរយៈប្រព័ន្ធផ្សព្វផ្សាយពីការអភិវឌ្ឍបៃតង
- ផ្តល់នូវកម្មវិធីនិងវេទិកាជជែកពិគ្រោះយោបល់ពីការអភិវឌ្ឍបៃតងក្នុងចំណោមសិស្សានុសិស្ស និស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រ
- កសាងមជ្ឈមណ្ឌលសារព័ត៌មានបៃតង បណ្ណាល័យបៃតង ប្រព័ន្ធព័ត៌មានវិទ្យាបៃតង និងវិទ្យាស្ថានស្រាវជ្រាវបៃតង។

### ៦.៣.៦- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- បំពាក់បច្ចេកវិទ្យាបៃតងនៅក្នុងការអភិវឌ្ឍគ្រប់វិស័យ
- ជួយសម្រួលដល់ការវិនិយោគពាក់ព័ន្ធ និងការផ្ទេរ ការផ្លាស់ប្តូរបច្ចេកវិទ្យាទាំងឡាយសម្រាប់ផលិតកម្មបៃតងនិងទីផ្សារបៃតង
- នាំយកបច្ចេកវិទ្យាបរិស្ថានដល់ជនក្រីក្រដើម្បីសម្រួលការប្រើប្រាស់ និងពង្រីកសមត្ថភាពការនាំចេញថ្នាក់ជាតិអំពីបច្ចេកវិទ្យាបរិស្ថាន(បន្ទះទទួលពន្លឺព្រះអាទិត្យប្រសិទ្ធភាពថាមពល)

- ធ្វើការផ្លាស់ប្តូរនិងផ្ទេរបច្ចេកវិទ្យាបៃតងរវាងផ្នែកសាធារណៈនិងផ្នែកឯកជន
- ផ្តល់ការធ្វើពាណិជ្ជកម្មលើបច្ចេកវិទ្យាបៃតងនៅលើគ្រប់វិស័យ
- ធ្វើការសិក្សា ស្រាវជ្រាវ និងវិភាគពីបច្ចេកវិទ្យាបៃតងថ្មី
- ធ្វើការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាបៃតងដល់ផ្នែកសាធារណៈ ផ្នែកឯកជន និងសង្គមស៊ីវិល
- ចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាបៃតងនៅក្នុងសិក្ខាសាលាជាតិនិងអន្តរជាតិ
- ធ្វើការទាក់ទាញការវិនិយោគលើបច្ចេកវិទ្យាបៃតងក្នុងគ្រប់វិស័យ។

**៦.៣.៧- ជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- បង្កើតភូមិបៃតងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនិងនិរន្តរភាពបរិស្ថាន
- ពង្រឹងការអនុវត្តតួនាទីយេនឌ័រនៅក្នុងការអភិវឌ្ឍបៃតង
- ធ្វើការកែលម្អវិស័យសុខាភិបាល ដើម្បីពង្រឹងការអនុវត្តលើការអភិវឌ្ឍបៃតង
- ធ្វើការអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព
- ធ្វើការបញ្ជ្រាបការអភិវឌ្ឍបៃតងទៅក្នុងវិស័យការងារនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- បំផុសចលនាប្រឡងប្រណាំងទីក្រុងនិងជនបទស្អាត។

**៦.៣.៨- ការរក្សានិងការការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិ**

- ផ្លាស់ប្តូរបទពិសោធ ចំណេះដឹង និងបច្ចេកវិទ្យាបៃតងលើបេតិកភណ្ឌវប្បធម៌បៃតង
- រក្សា ការពារ អភិរក្ស ធ្វើទំនើបកម្ម និងធ្វើសមាហរណកម្មនូវបេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌវប្បធម៌អរូបី និងវប្បធម៌សង្គមបៃតង
- រក្សាអត្តសញ្ញាណជាតិឈរលើគោលការណ៍និងវឌ្ឍនភាពបៃតង
- ពង្រឹងលើការថែរក្សានិងអភិរក្សកេរដំណែលសម្បត្តិវប្បធម៌
- ធ្វើសុខដុមនីយកម្មរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដោយប្រើគោលការណ៍អភិវឌ្ឍន៍បៃតង
- ផ្លាស់ប្តូរបទពិសោធនិងចំណេះដឹងក្នុងការជំរុញអារ្យធម៌ជឿនលឿនតាមបែបធម្មជាតិ
- ធ្វើការលើកទឹកចិត្តដល់ការបង្កើតថ្មីឡើងវិញជាអចិន្ត្រៃយ៍នូវបេតិកភណ្ឌវប្បធម៌អរូបីបៃតងឈរលើគោលការណ៍អភិវឌ្ឍន៍បៃតង
- ធ្វើការលើកទឹកចិត្តដល់ការផ្ទេរស្នាដៃនិងគំនិតច្នៃប្រឌិត
- ពង្រឹងសមត្ថភាពពីការអភិវឌ្ឍបៃតងនិងវឌ្ឍនភាពអភិវឌ្ឍបៃតងដោយរក្សានិងលើកតម្កើងវប្បធម៌ប្រពៃណីនិងអត្តសញ្ញាណជាតិ។

**៦.៣.៩- អភិបាលកិច្ចលើការអភិវឌ្ឍបៃតង**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- ធ្វើការផ្លាស់ប្តូរបទពិសោធដឹកនាំនិងគ្រប់គ្រងលើការអភិវឌ្ឍបៃតងជាមួយស្ថាប័នអន្តរជាតិ
- ពង្រឹងភាពជាដៃគូជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធររាជធានី ខេត្ត និងអង្គការជាតិនានា
- ធ្វើការប្រើប្រាស់បច្ចេកវិទ្យាបៃតង ដើម្បីឲ្យអភិបាលកិច្ចបៃតងមានប្រសិទ្ធភាព
- ធ្វើការរៀបចំក្របខ័ណ្ឌគតិយុត្តនិងផែនការសកម្មភាពនានាឲ្យមានលក្ខណៈបៃតង
- ធ្វើការពិនិត្យឡើងវិញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់
- អនុវត្តអភិបាលកិច្ចបៃតងនៅគ្រប់ទិសដៅយុទ្ធសាស្ត្រ
- រៀបចំធ្វើច្បាប់ស្តីពីការអភិវឌ្ឍបៃតង

- ពង្រឹងសមត្ថភាពអភិបាលកិច្ចបៃតងដល់ស្រទាប់មន្ត្រីរាជការស៊ីវិល មន្ត្រីសាធារណៈ យុវជនបៃតង សមភាពយេនឌ័រ រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជន
- អប់រំការអភិវឌ្ឍបៃតងតាមរយៈការពង្រឹងសមត្ថភាពដល់គ្រូបង្រៀនគ្រប់កម្រិត
- បណ្តុះបណ្តាលជនបង្គោលអភិបាលកិច្ចបៃតងនៅគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើការទាក់ទាញវិនិយោគិនបរទេសដើម្បីជំរុញអភិបាលកិច្ចបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ស្វែងរកប្រភពធនធានហិរញ្ញវត្ថុទាំងអស់ទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ
- ពង្រឹងផ្នែកឯកជនឲ្យអនុវត្តអភិបាលកិច្ចបៃតងនៅក្នុងការវិនិយោគរបស់ខ្លួន
- ធ្វើប្រតិភូកម្មអំណាច ធនធានហិរញ្ញវត្ថុ និងការទទួលខុសត្រូវដល់ថ្នាក់ក្រោមជាតិ
- ទទួលបានព័ត៌មាននានាទាក់ទងនឹងការអភិវឌ្ឍបៃតង។

គម្រោងអាទិភាពសម្រាប់អនុវត្តផែនការសកម្មភាពអភិវឌ្ឍបៃតង ដែលទាក់ទងនឹងក្រសួង ស្ថាប័ននីមួយៗ ដោយមានបញ្ជាក់ពីរយៈពេលខ្លី និងរយៈពេលមធ្យមនិងវែង ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

## ៧. ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ បានមកពីថវិកាជាតិនិងប្រភពធនធានផ្សេងៗទៀត។

## ៨. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ផែនការយុទ្ធសាស្ត្រជាតិនេះទាមទារការតាមដានត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តទៅតាមដំណាក់កាលនីមួយៗ ដោយពឹងផ្អែកជាមូលដ្ឋានលើយុទ្ធសាស្ត្រនិងផែនការសកម្មភាពទាំងឡាយដែលបានដាក់ចេញរួមទាំងសូចនាករសំខាន់ៗ។ បន្ទាប់ពីផែនការយុទ្ធសាស្ត្រជាតិនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវអនុវត្តទៅតាមផ្នែកពាក់ព័ន្ធនីមួយៗដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ដូច្នេះ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃត្រូវធានាថាការអនុវត្តឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជននិងប្រទេសជាតិ។

## ៩. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលវាយតម្លៃខ្ពស់លើផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើទិសដៅយុទ្ធសាស្ត្រចំនួន៩ ជាអាទិ៍ ការវិនិយោគបៃតងនិងការបង្កើតការងារបៃតង ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានគុណភាពជាមួយបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ ការបណ្តុះបណ្តាលធនធានមនុស្សបៃតង ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព ការជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង ការរក្សានិងការពារបេតិកភណ្ឌវប្បធម៌បៃតងនិងអត្តសញ្ញាណជាតិ និងអភិបាលកិច្ចលើការអភិវឌ្ឍបៃតង ដែលមានយុទ្ធសាស្ត្រតូចៗជាច្រើនជាមធ្យោបាយសម្រាប់ការសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម គោលបំណង គោលដៅ និងទិសដៅជាយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រជាតិនេះ។ រាល់យុទ្ធសាស្ត្រនេះបង្ហាញនូវសារប្រយោជន៍ដ៏ចម្បងនៃយុទ្ធវិធីឈ្នះ ឈ្នះ តាមរយៈការអភិវឌ្ឍបៃតង និងជាដំណោះស្រាយដ៏ល្អដែលជួយប្រទេសឲ្យកាត់បន្ថយភាពក្រីក្រ មានការរីកចម្រើនសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាពបរិស្ថាន ដែលរក្សាបាននូវកេរដំណែលវប្បធម៌ជាតិឲ្យមានកិត្យានុភាពជាតិល្បីរន្ទឺ សំដៅធានាបានស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងក្លាយទៅជាប្រទេសអភិវឌ្ឍ។

# ឧបសម្ព័ន្ធ

## គម្រោងសំខាន់ៗសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០

| ល.រ | គម្រោងអាទិភាព | ពេលខ្លី ឆ្នាំ ២០១៣-២០១៧ (៣ឆ្នាំ ទៅ៥ឆ្នាំ) | ពេលមធ្យម វែង ឆ្នាំ ២០១៨-២០៣០ (៦ឆ្នាំ ទៅ ១៣ឆ្នាំ) | ក្រសួង ស្ថាប័ន នាំមុខឬទទួលខុសត្រូវ |
|---|---|---|---|---|
| I | **ការវិនិយោគបៃតង និងការបង្កើតការងារបៃតង** | | | |
| ១ | ធ្វើការទាក់ទាញវិនិយោគិនបៃតងលើថាមពលកកើតឡើងវិញ ទឹក ជីធ្លី ព្រៃឈើ និងជលផល ព្រមទាំងសហគ្រាស និងពាណិជ្ជកម្មបៃតង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ២ | ធ្វើការបញ្ជ្រាបការអភិវឌ្ឍបៃតងទៅក្នុងប្រព័ន្ធសេដ្ឋកិច្ច ធនាគារ និងហិរញ្ញវត្ថុ | √ | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា |
| ៣ | ចេញវិញ្ញាបនបត្របៃតងជូនក្រុមហ៊ុន សហគ្រាស សណ្ឋាគារ ភោជនីយដ្ឋាន អង្គការ គ្រឹះស្ថានហិរញ្ញវត្ថុ ធនាគារវិនិយោគ និងធនាគារពាណិជ្ជ | | √ | ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត |
| ៤ | រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយពាណិជ្ជកម្មបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ៥ | បង្កើតវិធានការជំរុញ ការលើកកម្ពស់និរន្តរភាពកសិកម្ម រួមទាំងប្រព័ន្ធធានារ៉ាប់រងដែលផ្អែកលើសន្ទស្សន៍និង/ឬមីក្រូហិរញ្ញប្បទាន | √ | √ | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦ | បង្កើតប្រព័ន្ធសម្រាប់ការវិនិយោគថ្នៃប្រឌិត ដើម្បីធានាឲ្យការគ្រប់គ្រងធនធានធម្មជាតិមាននិរន្តរភាព | | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ៧ | ជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឯកជននិងកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយអនុវត្តគោលការណ៍អភិបាលកិច្ចល្អ | √ | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ |

| | | | | |
|---|---|---|---|---|
| ៨ | រៀបចំគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធីនិងគម្រោងសាកល្បងបៃតង នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | | √ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធររាជធានី ខេត្ត |
| ៩ | រៀបចំមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតងសម្រាប់ការអភិវឌ្ឍបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធររាជធានី ខេត្ត |
| ១០ | ធ្វើការបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះគណនីបរិស្ថានបៃតង | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១១ | ធ្វើការតាមដានត្រួតពិនិត្យគណនីនិងហិរញ្ញវត្ថុទាក់ទងនឹងការអភិវឌ្ឍបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **II** | **ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពជាមួយបរិស្ថាន** | | | |
| ១ | រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយស្តីពីសេដ្ឋកិច្ចបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ២ | រៀបចំកសាងប្រភេទពន្ធដារបៃតងទៅតាមគោលការណ៍អភិវឌ្ឍន៍បៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ៣ | រៀបចំសូចនាករដើម្បីបង្ហាញពីកំណើនសេដ្ឋកិច្ចបៃតងដោយផ្អែកលើគោលការណ៍អភិវឌ្ឍន៍បៃតង | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ៤ | រៀបចំយន្តការគ្រប់គ្រងក្នុងដំណាក់កាលអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតងឲ្យមានប្រសិទ្ធភាព | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ៥ | កែលម្អគុណភាពអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាពដោយបង្កើនផលិតភាពនិងបរិមាណផលិតផល | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ៦ | ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចប្រពៃណីទៅកាន់សេដ្ឋកិច្ចបៃតងដើម្បីបញ្ច្រាប បន្សី និងបន្សាំគ្នារវាងសេដ្ឋកិច្ចនិងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយប្រសិទ្ធភាព | √ | √ | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |

| | | | | |
|---|---|---|---|---|
| ៧ | បង្កើតហេដ្ឋារចនាសម្ព័ន្ធប្រសិទ្ធភាពបៃតង តាមរយៈការធ្វើផែនការសេដ្ឋកិច្ចបៃតង | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងផែនការ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ៨ | ជំរុញនិងបង្កើតឱកាសពាណិជ្ជកម្មបៃតង សម្រាប់ផលិតផលបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនិងក្រសួងពាណិជ្ជកម្ម |
| ៩ | លើកកម្ពស់សុខុមាលភាពស្ត្រី កុមារ យុវជន ជនពិការ ប្រជាកសិករ ជនជាតិដើមភាគតិច ចាស់ជរា និងសហគមន៍ តាមរយៈកំណើនសេដ្ឋកិច្ចបៃតងនិងប្រព័ន្ធសុវត្ថិភាពសង្គមបៃតង | √ | √ | ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងអភិវឌ្ឍជនបទ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១០ | លើកកម្ពស់និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច | √ | √ | ក្រសួងបរិស្ថាន |
| ១១ | រៀបចំបទដ្ឋានគតិយុត្តនិងគោលនយោបាយហិរញ្ញវត្ថុបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ១២ | បញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតងទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ធនាគារជាតិនៃកម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ១៣ | រៀបចំនីតិវិធីនិងការគ្រប់គ្រងលទ្ធកម្មបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ១៤ | រៀបចំគម្រោងឥណទាន កម្ចីបៃតងដោយឈរលើគោលការណ៍អភិវឌ្ឍន៍បៃតងនៅផ្នែកសាធារណៈ និងឯកជន | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ១៥ | ការរៀបចំប្រព័ន្ធសេវាកម្មបៃតង តាមរយៈម៉ាស៊ីនស្វ័យប្រវត្តសម្រាប់ដក ដាក់សាច់ប្រាក់នៅក្នុងបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ១៦ | បង្កើតហេដ្ឋារចនាសម្ព័ន្ធបៃតងក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ ដោយប្រើបច្ចេកវិទ្យាបៃតង អគារបៃតង និងលម្អបៃតង | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |

| | | | | |
|---|---|---|---|---|
| ១៧ | ការប្រើប្រព័ន្ធបច្ចេកវិទ្យាបៃតង ដើម្បីគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការគណនេយ្យ និងលំហូរហិរញ្ញវត្ថុ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ១៨ | បង្កើតបរិយាកាសអំណោយផលនៅតាមបណ្តាក្រុមហ៊ុនហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងធនាគារជាតិនៃកម្ពុជា |
| ១៩ | ការបង្កើតទីផ្សារហិរញ្ញវត្ថុឲ្យមានលក្ខណៈបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ២០ | ជំរុញលើកទឹកចិត្តដល់សាធារណជន និងប្រជាជនទូទៅឲ្យប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារបៃតង | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានិងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ២១ | កាត់បន្ថយភាពក្រីក្រទូទាំងប្រទេស តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុ និងធនាគារបៃតង ព្រមទាំងផលិតផលបៃតង | √ | √ | ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ២២ | រៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្ត សម្រាប់ការទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាន | √ | | ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ២៣ | លើកម្ពស់ផលិតភាពនៃសេវាប្រព័ន្ធអេកូឡូស៊ីនៅតាមបណ្តាតំបន់ការពារធម្មជាតិ តំបន់អភិរក្ស តំបន់រក្សាទុក និងតំបន់ឆ្នេរ | | √ | ក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា |
| ២៤ | ជំរុញការអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតងនៅតាមបណ្តាតំបន់ការពារធម្មជាតិ តំបន់អភិរក្ស តំបន់រក្សាទុកនិងតំបន់ឆ្នេរ | | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ២៥ | ប្រើប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថានជាឧបករណ៍លើកទឹកចិត្តដល់សហគមន៍មូលដ្ឋាននិងអ្នកពាក់ព័ន្ធទាំងអស់ | √ | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ២៦ | បង្កើតយន្តការកម្រៃសេវាការពារប្រព័ន្ធបរិស្ថានឈរលើគោលការណ៍អភិវឌ្ឍន៍បៃតង | √ | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |

| | | | | |
|---|---|---|---|---|
| ២៧ | បញ្ជ្រាបប្រព័ន្ធទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថានទៅក្នុងការអភិវឌ្ឍបៃតងលើគ្រប់វិស័យអភិវឌ្ឍន៍ | √ | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ២៨ | ទាញយកទីផ្សារលក់ឥណទានកាបូន តាមរយៈការអនុវត្តការទូទាត់កម្រៃសេវាការពារប្រព័ន្ធបរិស្ថាននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | √ | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ២៩ | សម្របសម្រួលដល់ការកំណត់តំបន់ ដើម្បីបែងចែកជាតំបន់សម្រាប់ផលិតភាពនៃសេវាការពារប្រព័ន្ធបរិស្ថាន | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៣០ | បង្កើតយន្តការតាមដានត្រួតពិនិត្យការវិនិយោគទាំងផ្នែកឯកជន ទាំងផ្នែកសាធារណៈ ដើម្បីប្រសិទ្ធភាពនៃសេដ្ឋកិច្ចបៃតងនិងការកាត់បន្ថយភាពក្រីក្រ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| III | **ការអភិវឌ្ឍសេដ្ឋកិច្ចខៀវឲ្យមាននិរន្តរភាព** | | | |
| ១ | គ្រប់គ្រងធនធានសមុទ្រ តំបន់ឆ្នេរ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឲ្យមានសុវត្ថិភាព ចីរភាព និងនិរន្តរភាព | √ | √ | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា |
| ២ | អភិរក្សនិងប្រើប្រាស់ធនធានសមុទ្រប្រកបដោយនិរន្តរភាព | √ | √ | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា |
| ៣ | គ្រប់គ្រងការបំពុលសមុទ្រ | √ | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៤ | ជំរុញការងារអង្កេតតាមដាននិងការធ្វើអធិការកិច្ចលើគុណភាពទឹកសមុទ្រដែលមានសារធាតុអាស៊ីដ | √ | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៥ | ស្រាវជ្រាវរកឲ្យឃើញនូវសារធាតុបំពុលទឹកសមុទ្រនិងថែរក្សាគុណភាពទឹកសមុទ្រ | √ | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៦ | ស្វែងយល់ពីគ្រោះមហន្តរាយដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុនិងការបំពុលសមុទ្រ | √ | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៧ | ការកំណត់យុទ្ធសាស្ត្រក្នុងការពង្រឹងសមត្ថភាពនៃការអភិរក្សនិងការគ្រប់គ្រងបរិស្ថានសមុទ្រប្រកបដោយនិរន្តរភាពគឺជាការផ្ដល់ផលប្រយោជន៍សម្រាប់ប្រជានេសាទ | √ | | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |

| | | | | |
|---|---|---|---|---|
| ៨ | សិក្សា ស្រាវជ្រាវ និងវិភាគពីការប្រែប្រួលអាកាសធាតុដែលនាំឲ្យមានការឡើងកម្ពស់ទឹកសមុទ្រ និងការហូរច្រោះឆ្នេរ | √ | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៩ | រៀបចំទុកជាមុន បង្ការ និងការពារពីគ្រោះមហន្តរាយនៅតំបន់សមុទ្រ | √ | √ | ក្រសួងបរិស្ថាន ក្រសួងធនធានទឹកនិងឧតុនិយម និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| IV | **ការគ្រប់គ្រងបរិស្ថានបៃតងនិងធនធានធម្មជាតិ** | | | |
| ១ | បង្កើតកសិកម្មបៃតង ការអភិរក្សកសិកម្ម និងកសិកម្មអេកូឡូស៊ី | √ | √ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២ | គ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ ការត្រួតពិនិត្យការបំពុលទឹក និងការត្រួតពិនិត្យការបំពុលខ្យល់ត្រូវអនុវត្តទៅតាមបទដ្ឋានគតិយុត្ត | √ | √ | ក្រសួងបរិស្ថាន |
| ៣ | បង្កើតនិរន្តរភាពនៃផែនការយុទ្ធសាស្ត្រ កសិកម្មនិងជំរុញការប្រើប្រាស់ជីធម្មជាតិ | | √ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤ | គ្រប់គ្រងធនធានទឹកប្រកបដោយចីរភាព | | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៥ | គ្រប់គ្រងធនធានទឹកសម្រាប់សន្តិសុខទឹកនិងភាពរីកចម្រើនសេដ្ឋកិច្ច | | √ | ក្រសួងធនធានទឹកនិងឧតុនិយម |
| ៦ | ធ្វើសមាហរណកម្មប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងធនធានទឹក | | √ | ក្រសួងបរិស្ថាននិងក្រសួងធនធានទឹកនិងឧតុនិយម |
| ៧ | រៀបចំយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិ ធនធានរ៉ែ ព្រៃឈើ ទឹក និងជលផលដោយធ្វើឲ្យមានតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ ដើម្បីលើកស្ទួយសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចជនបទ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួង ស្ថាប័នពាក់ព័ន្ធ |
| ៨ | ពង្រឹងនិងជំរុញការអភិរក្សធនធានព្រៃឈើនិងជីវៈចម្រុះសម្រាប់បម្រើសេវាកម្មសេដ្ឋកិច្ចបរិស្ថានតាមរយៈការអនុវត្តគម្រោងឥណទានកាបូន | √ | √ | ក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៩ | រៀបចំផែនការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព | √ | √ | ក្រសួងបរិស្ថាននិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១០ | រៀបចំផែនការអភិវឌ្ឍនិងវិនិយោគ និងការអភិវឌ្ឍរបស់ផ្នែកឯកជន | | √ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| | | | | |
|---|---|---|---|---|
| ១១ | ជំរុញការកំណត់តំបន់សម្រាប់ជាមូលដ្ឋាននៃការធ្វើផែនការប្រើប្រាស់ដីធ្លី | √ | √ | ក្រសួងបរិស្ថាននិង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១២ | ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រេងផូស៊ីលនិងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតំបន់ជនបទ | √ | √ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងអភិវឌ្ឍន៍ជនបទ |
| ១៣ | បង្កើតបរិស្ថានពាណិជ្ជកម្មបៃតងជាមួយបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផលិតថាមពលត្រូវបានជំរុញឲ្យមានការប្រកួតប្រជែងសម្រាប់ការប្រើប្រាស់ថាមពលកកើតឡើងវិញ ការកែលម្អប្រសិទ្ធភាពថាមពល និងការអភិវឌ្ឍឧស្សាហកម្មបៃតង | | √ | ក្រសួងបរិស្ថាននិង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ១៤ | បង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបៃតងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | √ | √ | ក្រសួងសាធារណការ និងដឹកជញ្ជូន និងអាជ្ញាធររាជធានី ខេត្ត |
| ១៥ | ចែករំលែកការដឹកជញ្ជូនបៃតងដោយប្រើប្រាស់ឡានក្រុង រថភ្លើងដើរដោយចរន្តអគ្គិសនី ការប្រើប្រាស់កង់ និងម៉ូតូអគ្គិសនី សម្រាប់ការធ្វើដំណើរក្នុងទីប្រជុំជន | √ | √ | ក្រសួងបរិស្ថានក្រសួងសាធារណការ និងដឹកជញ្ជូន និងអាជ្ញាធររាជធានី ខេត្ត |
| ១៦ | អភិវឌ្ឍទេសចរណ៍បៃតង សម្រាប់ការអភិវឌ្ឍបៃតងឈានទៅដល់ភាពរីកចម្រើននៃសេដ្ឋកិច្ចជាតិ | | √ | ក្រសួងទេសចរណ៍ |
| ១៧ | អភិវឌ្ឍទេសចរណ៍ទប់ទល់នឹងបញ្ហាប្រឈមនៃវិបត្តិហិរញ្ញវត្ថុ កំណើនការងារបៃតងសម្រាប់គាំទ្រដល់សេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ | √ | √ | ក្រសួងទេសចរណ៍ |
| ១៨ | ជំរុញការវិនិយោគលើទេសចរណ៍បៃតងជួយកាត់បន្ថយលើការចំណាយទៅលើការប្រើប្រាស់ថាមពល ទឹក សំណល់ និងរក្សាតម្លៃប្រព័ន្ធអេកូឡូស៊ី និងបេតិកភណ្ឌមនុស្សលោក និងធម្មជាតិ | | √ | ក្រសួងទេសចរណ៍និង ក្រសួងបរិស្ថាន |
| ១៩ | បង្កើនការចូលរួមពីផ្នែកសាធារណៈ ផ្នែកឯកជន និងអ្នកទេសចរគាំទ្រដល់ទេសចរណ៍បៃតង | √ | | ក្រសួងទេសចរណ៍ |
| ២០ | បង្កើនសក្តានុពលសេដ្ឋកិច្ចក្នុងការងារទេសចរណ៍បៃតង សម្រាប់សហគ្រាសធុនតូច និងមធ្យម | √ | | ក្រសួងទេសចរណ៍ |
| ២១ | រៀបចំគោលនយោបាយនិងការវិនិយោគ សម្រាប់ផ្នែកឯកជនពាក់ព័ន្ធនឹងទេសចរណ៍បៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងទេសចរណ៍ |
| ២២ | អភិវឌ្ឍទេសចរណ៍ដោយផ្អែកលើសហគមន៍សម្រាប់កែលម្អការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើនឱកាសការងារ | √ | √ | ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| ២៣ | បង្កើនទេសចរណ៍បៃតងឲ្យមានសក្តានុពលជាវិជ្ជមានដល់សេដ្ឋកិច្ចជាតិ | | √ | ក្រសួងទេសចរណ៍ |
| ២៤ | ពង្រឹងវិស័យអភិវឌ្ឍទេសចរណ៍ដើម្បីទប់ទល់នឹងបញ្ហាប្រឈមនៃវិបត្តិហិរញ្ញវត្ថុ | √ | √ | ក្រសួងទេសចរណ៍និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ២៥ | ការកំណត់តំបន់ឆ្នេរសមុទ្រសម្រាប់គោលដៅអភិវឌ្ឍន៍និងការអភិរក្ស | √ | √ | គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជានិងក្រសួងបរិស្ថាន |
| ២៦ | បង្កើតអេកូឡាបែលសម្រាប់ប្រតិបត្តិករទេសចរណ៍ | | | ក្រសួងទេសចរណ៍ |
| ២៧ | រៀបចំការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ ក្នុងគោលដៅសាងសង់ហេដ្ឋារចនាសម្ព័ន្ធ លំនៅឋាន សំណង់សាធារណៈនិងឯកជន សម្រាប់បម្រើឲ្យវិស័យទេសចរណ៍ | | √ | គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជានិងក្រសួងបរិស្ថាន |
| ២៨ | ធ្វើការសិក្សា វាយតម្លៃ និងវិភាគឲ្យបានលម្អិតពីសកម្មភាពទាំងឡាយនៅតាមឆ្នេរសមុទ្រ បណ្តោយឆ្នេរសមុទ្រ ដៃសមុទ្រ ស្ទឹង ព្រែក(ដែលតភ្ជាប់នឹងសមុទ្រ) និងកោះ | | √ | គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជានិងក្រសួងបរិស្ថាន |
| ២៩ | ការគ្រប់គ្រងធនធានទឹកសមុទ្រនិងធនធានដែលពាក់ព័ន្ធនឹងទឹកសមុទ្រ | √ | √ | ក្រសួងធនធានទឹកនិងឧតុនិយម |
| ៣០ | ធ្វើការផ្សព្វផ្សាយនិងអប់រំពីការអភិវឌ្ឍបៃតងនៅតំបន់ឆ្នេរដល់សាធារណជនទូទៅ | √ | | គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជានិងក្រសួងបរិស្ថាន |
| ៣១ | កសាងយុទ្ធសាស្ត្រជាតិ សម្រាប់ឧស្សាហកម្មបៃតងដោយផ្អែកលើប្រសិទ្ធភាព ធនធាន និងគោលការណ៍កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ | √ | √ | ក្រសួងបរិស្ថាននិងក្រសួងទេសចរណ៍ |
| ៣២ | លើកកម្ពស់ប្រសិទ្ធភាពប្រើប្រាស់ធនធានដោយអនុវត្តគោលការណ៍អ្នកបំពុលជាអ្នកអ្នកបង់ថ្លៃ | √ | √ | ក្រសួងបរិស្ថាន |
| ៣៣ | និរន្តរភាពធនធានទឹកសម្រាប់ការប្រើប្រាស់(បរិភោគ)និងការស្រោចស្រព | | √ | ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៣៤ | បង្កើត និងអនុវត្តការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តរភាព | | √ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | |
|---|---|---|---|---|
| ៣៥ | បង្កើតផែនការយុទ្ធសាស្ត្រ សម្រាប់ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព | | √ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៣៦ | បង្កើតនិងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការគ្រប់គ្រងសំណល់ក្នុងប្រទេសឲ្យមាននិរន្តរភាព | | √ | ក្រសួងបរិស្ថាន |
| ៣៧ | រក្សានិរន្តរភាពនៃការដឹកជញ្ជូននិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង | | √ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៣៨ | គ្រប់គ្រងលើការប្រើប្រាស់ដីតាមបែបផែនការចូលរួម និងពង្រឹងប្រសិទ្ធភាពនៃការកសាងផែនការប្រើប្រាស់ដីសម្រាប់ជនជាតិដើមភាគតិច | | √ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៣៩ | អភិវឌ្ឍនិងគ្រប់គ្រងតំបន់ឆ្នេរប្រកបដោយនិរន្តរភាព និងការស្រាវជ្រាវអំពីប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងការអភិវឌ្ឍដើម្បីការអភិវឌ្ឍបៃតង | | √ | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤០ | កែលម្អនិងអនុវត្តវិទ្យាសាស្ត្រ បច្ចេកវិទ្យា សម្រាប់ផែនការសកម្មភាពជាតិបន្សាំទៅនិងការប្រែប្រួលអាកាសធាតុ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព | √ | √ | ក្រសួងបរិស្ថាន |
| ៤១ | កែលម្អនិងការអនុវត្តការគ្រប់គ្រងសំណល់រាវប្រកបដោយប្រសិទ្ធភាព | | √ | ក្រសួងបរិស្ថាន និងអាជ្ញាធររាជធានី ខេត្ត |
| ៤២ | ប្រើប្រាស់ដីនិងបរិស្ថានទីក្រុង ដែលសមស្របនឹងបរិស្ថាន និងផ្តល់សុខភាពល្អ ព្រមទាំងដាក់ឲ្យអនុវត្តគោលការណ៍សម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព | | √ | ក្រសួងបរិស្ថាន |
| ៤៣ | បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប្រេងផូស៊ីលដោយ ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតំបន់ជនបទនិងការបង្កើតបរិស្ថានពាណិជ្ជកម្មបៃតងជាមួយបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផលិតថាមពល | √ | √ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៤៤ | វាយតម្លៃប្រពលភាពនៃការប្រែប្រួលអាកាសធាតុ និងបង្កើតសេនារីយ៉ូនៃការប្រែប្រួលអាកាសធាតុនិងកំណើនកម្ពស់ទឹកសមុទ្រ | | √ | ក្រសួងបរិស្ថាន និងក្រសួងធនធានទឹកនិងឧតុនិយម |
| ៤៥ | ផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យសម្រាប់សហគមន៍ជនបទ និងការអភិវឌ្ឍមុខរបរជំនួសសម្រាប់ចិញ្ចឹមជីវិត | | √ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៤៦ | ពង្រឹងការអនុវត្តនិងបង្កើនការយល់ដឹងអំពីផលិតផលស្អាតនិងការអនុវត្តប្រកបដោយប្រសិទ្ធភាពតាមស្តង់ដាច្បាប់ | | √ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |

| | | | | |
|---|---|---|---|---|
| ៤៧ | បង្កើតឧស្សាហកម្មបៃតងនិងបញ្ចូលទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | | √ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៤៨ | បង្កើតផែនការអភិវឌ្ឍ ដើម្បីកាត់បន្ថយការស្ទះចរាចរណ៍និងគ្រោះថ្នាក់តាមរយៈការសាងសង់ចិញ្ចើមផ្លូវ | | √ | អាជ្ញាធររាជធានី ខេត្ត |
| ៤៩ | កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើនិងការរេចរឹលព្រៃឈើ (REDD) | | √ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និង អាជ្ញាធររាជធានី ខេត្ត |
| ៥០ | ស្រាវជ្រាវនិងបង្កើតកម្មវិធីឆ្លើយតបទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ | | √ | ក្រសួងបរិស្ថាន |
| **V** | **ការបណ្តុះបណ្តាលធនធានមនុស្សនិងការអប់រំបៃតង** | | | |
| ១ | ការកសាងសមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីបង្កើនគំនិតនិងព័ត៌មានស្តីពីបញ្ហាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្មបៃតង។ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងអប់រំ យុវជន និងកីឡា |
| ២ | បង្កើតការយល់ដឹងនិងដំណើរការពិគ្រោះយោបល់ក្នុងចំណោមអ្នកដទៃទៀត តាមរយៈការផ្សព្វផ្សាយសម្ភារៈអប់រំ និងសន្លឹកព័ត៌មានស្តីពីកន្លែងធ្វើការបៃតងនិងលំនៅឋានបៃតង | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនិងក្រសួងបរិស្ថាន |
| ៣ | បញ្ចូលការអប់រំពីការអភិវឌ្ឍបៃតងនៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត | | √ | ក្រសួងអប់រំ យុវជន និងកីឡា |
| ៤ | កសាងគ្រឹះស្ថានសិក្សាអភិវឌ្ឍន៍បៃតងនៅកម្រិតថ្នាក់ជាតិ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៥ | បណ្តុះបណ្តាលការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌ ក្រៅប្រព័ន្ធដល់ផ្នែកសាធារណៈ ឯកជន និងនៅតាមភូមិឃុំ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៦ | រៀបចំនិងបង្កើតបណ្តាញការងារអភិវឌ្ឍន៍បៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនិងក្រសួងមហាផ្ទៃ |
| ៧ | ផ្លាស់ប្តូរបទពិសោធ និងចែករំលែកចំណេះដឹងពីការអភិវឌ្ឍបៃតងនៅកម្ពុជា | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៨ | ផ្លាស់ប្តូរបទពិសោធនិងបច្ចេកទេសបៃតងពីការអភិវឌ្ឍបៃតងរវាងប្រទេសក្នុងតំបន់អាស៊ាន ប្រទេសសមាជិកអង្គការGGGI និងពិភពលោក | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៩ | ផ្តល់ព័ត៌មានពីការអភិវឌ្ឍបៃតងដល់សាធារណជនទូទៅ តាមរយៈប្រព័ន្ធផ្សព្វផ្សាយពីការអភិវឌ្ឍបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |

| | | | | |
|---|---|---|---|---|
| ១០ | ផ្តល់នូវកម្មវិធីនិងវេទិកាជជែកពិគ្រោះយោបល់ពីការអភិវឌ្ឍបៃតងក្នុងចំណោមសិស្សានុសិស្ស និស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងអប់រំ យុវជន និងកីឡា |
| ១១ | កសាងមជ្ឈមណ្ឌលសារព័ត៌មានបៃតង បណ្ណាល័យបៃតង ប្រព័ន្ធព័ត៌មានវិទ្យាបៃតង និងវិទ្យាស្ថានស្រាវជ្រាវបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| **VI** | **ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធភាព** | | | |
| ១ | បំពាក់បច្ចេកវិទ្យាបៃតងនៅក្នុងការអភិវឌ្ឍគ្រប់វិស័យ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួង ស្ថាប័នពាក់ព័ន្ធ |
| ២ | ជួយសម្រួលដល់ការវិនិយោគពាក់ព័ន្ធនិងការផ្ទេរផ្លាស់ប្តូរបច្ចេកវិទ្យាទាំងឡាយសម្រាប់ផលិតកម្មបៃតងនិងទីផ្សារបៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ៣ | នាំយកបច្ចេកវិទ្យាបរិស្ថានជូនដល់ជនក្រីក្រដើម្បីសម្រួលការប្រើប្រាស់និងពង្រីកសមត្ថភាពការនាំចេញថ្នាក់ជាតិអំពីបច្ចេកវិទ្យាបរិស្ថាន(បន្ទះទទួលពន្លឺព្រះអាទិត្យ ប្រសិទ្ធភាពថាមពល។ល។) | √ | | ក្រសួងបរិស្ថាននិងក្រសួងស្ថាប័នពាក់ព័ន្ធ |
| ៤ | ផ្លាស់ប្តូរនិងផ្ទេរបច្ចេកវិទ្យាបៃតងរវាងផ្នែកសាធារណៈនិងផ្នែកឯកជន | | √ | ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៥ | ផ្តល់ការធ្វើពាណិជ្ជកម្មលើបច្ចេកវិទ្យាបៃតងនៅលើគ្រប់វិស័យ | √ | √ | ក្រសួងពាណិជ្ជកម្ម |
| ៦ | សិក្សា ស្រាវជ្រាវ និងវិភាគពីបច្ចេកវិទ្យាបៃតង ថ្មី | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៧ | បណ្តុះបណ្តាលបច្ចេកវិទ្យាបៃតងដល់ផ្នែកសាធារណៈ ផ្នែកឯកជន និងសង្គមស៊ីវិល | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៨ | ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេវិទ្យាបៃតងនៅក្នុងសិក្ខាសាលាជាតិនិងអន្តរជាតិ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៩ | ទាក់ទាញការវិនិយោគលើបច្ចេកវិទ្យាបៃតងក្នុងគ្រប់វិស័យ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **VII** | **ជំរុញប្រព័ន្ធសុវត្ថិភាពសង្គមបៃតង** | | | |
| ១ | បង្កើតភូមិបៃតងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនិងនិរន្តរភាពបរិស្ថាន | | √ | ក្រសួងបរិស្ថាន |
| ២ | អភិវឌ្ឍនិងអនុវត្តតួនាទីយេនឌ័រ នៅក្នុងការអភិវឌ្ឍបៃតង | | √ | ក្រសួងកិច្ចការនារី |

| | | | | |
|---|---|---|---|---|
| ៣ | កែលម្អវិស័យសុខាភិបាល ដើម្បីពង្រឹងការអនុវត្តលើការអភិវឌ្ឍបៃតង | | √ | ក្រសួងសុខាភិបាល |
| ៤ | អភិវឌ្ឍឧស្សាហកម្ម សហគ្រាសខ្នាតតូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព | | √ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៥ | បញ្ចូលគោលគំនិតអំពីការអភិវឌ្ឍបៃតងទៅក្នុងវិស័យការងារនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ | | √ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **VIII** | **ការរក្សានិងការពារបេតិកភណ្ឌវប្បធម៌បៃតង និងអត្តសញ្ញាណជាតិ** | | | |
| ១ | ផ្លាស់ប្តូរបទពិសោធ ចំណេះដឹង និងបច្ចេកវិទ្យាបៃតងលើបេតិកភណ្ឌវប្បធម៌បៃតង | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរអប្សរា |
| ២ | រក្សា ការពារ អភិរក្ស ធ្វើទំនើបកម្ម និងធ្វើសមាហរណកម្មនូវបេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌវប្បធម៌អរូបីនិងវប្បធម៌សង្គមបៃតង | √ | √ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអាជ្ញាធរអប្សរា |
| ៣ | លើកតម្កើងកិត្យានុភាពជាតិនិងរក្សាអត្តសញ្ញាណជាតិឈរលើគោលការណ៍និងវឌ្ឍនភាពបៃតង | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរអប្សរា |
| ៤ | ពង្រឹងលើការថែរក្សានិងអភិរក្សកេរដំណែលសម្បត្តិវប្បធម៌ | √ | √ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ៥ | ការធ្វើសុខដុមនីយកម្មរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដោយប្រើគោលការណ៍អភិវឌ្ឍន៍បៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ |
| ៦ | ផ្លាស់ប្តូរបទពិសោធនិងចំណេះដឹងក្នុងការជំរុញអារ្យធម៌ជឿនលឿនតាមបែបធម្មជាតិ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ |
| ៧ | លើកកម្ពស់និងលើកទឹកចិត្តដល់ការប្រតិបត្តិការសម្តែងការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍វត្ថុ | √ | | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ |
| ៨ | ការលើកទឹកចិត្តដល់ការបង្កើតថ្មីឡើងវិញជាអចិន្ត្រៃយ៍ នូវបេតិកភណ្ឌវប្បធម៌អរូបីបៃតង ដោយឈរលើគោលការណ៍អភិវឌ្ឍន៍បៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ៩ | បង្កើនសុខដុមនីយកម្មរវាងមនុស្សនិងធម្មជាតិ | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| ១០ | លើកទឹកចិត្តដល់ការផ្ទេរស្នាដៃនិងគំនិតច្នៃប្រឌិត | | √ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័ន ពាក់ព័ន្ធ |
| ១១ | លើកកម្ពស់គុណភាពជីវិតដោយអនុវត្តគោលការណ៍អភិវឌ្ឍន៍បៃតង | | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនិងក្រសួង ស្ថាប័ន ពាក់ព័ន្ធ |
| ១២ | បង្កើនការយល់ដឹងអំពីការអភិវឌ្ឍបៃតងនិងវឌ្ឍនភាពអភិវឌ្ឍបៃតងនៅក្នុងវប្បធម៌ប្រពៃណីនិងអត្តសញ្ញាណជាតិ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួង ស្ថាប័ន ពាក់ព័ន្ធ |
| IX | **អភិបាលកិច្ចលើការអភិវឌ្ឍបៃតង** | | | |
| ១ | ផ្លាស់ប្តូរបទពិសោធដឹកនាំនិងគ្រប់គ្រងលើការអភិវឌ្ឍបៃតងជាមួយស្ថាប័នអន្តរជាតិ | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ២ | ពង្រឹងភាពជាដៃគូជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធររាជធានី ខេត្ត និងអង្គការជាតិនានា | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងស្ថាប័ន ពាក់ព័ន្ធ |
| ៣ | រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៤ | ពង្រឹងសមត្ថភាពស្តីពីអភិបាលកិច្ចលើការអភិវឌ្ឍបៃតងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | √ | √ | ក្រសួងមហាផ្ទៃ និង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៥ | ប្រើប្រាស់បច្ចេកវិទ្យាបៃតង ដើម្បីឲ្យអភិបាលកិច្ចបៃតងមានប្រសិទ្ធភាព | | √ | ក្រសួងមហាផ្ទៃ និង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៦ | រៀបចំក្របខ័ណ្ឌគតិយុត្តនិងផែនការសកម្មភាពនានាឲ្យមានលក្ខណៈបៃតង | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៧ | ពិនិត្យឡើងវិញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៨ | អនុវត្តអភិបាលកិច្ចបៃតងនៅគ្រប់ទិសដៅយុទ្ធសាស្ត្រ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៩ | រៀបចំបង្កើតច្បាប់ស្តីពីការអភិវឌ្ឍបៃតង | √ | | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ១០ | ពង្រឹងសមត្ថភាពអភិបាលកិច្ចបៃតងដល់ស្រទាប់មន្ត្រីរាជការស៊ីវិល មន្ត្រីសាធារណៈ យុវជនបៃតង សមភាពយេនឌ័រ រដ្ឋបាលថ្នាក់ក្រោមជាតិនិងផ្នែកឯកជន | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |

| | | | | |
|---|---|---|---|---|
| ១១ | អប់រំអំពីការអភិវឌ្ឍបៃតងតាមរយៈការពង្រឹងសមត្ថភាពដល់គ្រូបង្រៀនគ្រប់កម្រិត | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងអប់រំ យុវជន និងកីឡា |
| ១២ | បណ្តុះបណ្តាលជនបង្គោលអភិបាលកិច្ចបៃតងនៅគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ | √ | √ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ១៣ | ទាក់ទាញវិនិយោគិនបរទេសដើម្បីជំរុញអភិបាលកិច្ចបៃតងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | √ | ក្រសួងមហាផ្ទៃនិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ១៤ | ស្វែងរកប្រភពធនធានហិរញ្ញវត្ថុទាំងអស់ទាំងក្នុងកម្រិតជាតិ ទាំងអន្តរជាតិ | √ | √ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៥ | ពង្រឹងផ្នែកឯកជនឲ្យអនុវត្តអភិបាលកិច្ចបៃតងនៅក្នុងការវិនិយោគរបស់ខ្លួន | | √ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១៦ | ធ្វើប្រតិភូកម្មអំណាចធនធានហិរញ្ញវត្ថុ និងការទទួលខុសត្រូវដល់ថ្នាក់ក្រោមជាតិ | | √ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដែលមិនបានចែងខាងលើ អនុលោមតាមច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័ន និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នសាមី ត្រូវសហការជាមួយក្រសួង ស្ថាប័ននាំមុខឬទទួលខុសត្រូវ ដើម្បីអនុវត្តគម្រោងអាទិភាពនេះ។

# សទ្ទានុក្រម

**កសិកម្មបៃតង** សំដៅដល់ផលិតកម្មកសិកម្មដែលប្រើបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កការខូចខាតដល់បរិស្ថាន និងមិនប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ ដោយប្រើតែសារធាតុសរីរាង្គ(គ្មានសារធាតុគីមី)ដូចជាជីសរីរាង្គ ពូជដំណាំសរីរាង្គ និងធនធានរូបសាស្ត្រសរីរាង្គ(ទឹក ដី ខ្យល់ ភូគព្ភសាស្ត្រ ធម្មជាតិ) សម្រាប់ផលិតកម្មកសិកម្ម និងការបង្កបង្កើនផល។ កសិកម្មបៃតងគឺជួយលើកកម្ពស់សេដ្ឋកិច្ចបៃតង កសិឧស្សាហកម្មបៃតង និងទេសចរណ៍បៃតង (ទេសចរណ៍ធម្មជាតិឬអេកូទេសចរណ៍)។

**ការងារបៃតង** សំដៅដល់សកម្មភាពរបស់បុគ្គលនីមួយៗដែលបម្រើការនៅក្នុងវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង សេដ្ឋកិច្ចបៃតង វិនិយោគបៃតង ទេសចរណ៍បៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង និងវិស័យនានាដែលទាក់ទងនឹងការអភិវឌ្ឍបៃតង ដោយទទួលបានប្រាក់ចំណូលសមរម្យ។

**គមនាគមន៍បៃតង** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធនិងមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ទូរគមនាគមន៍ និងបណ្តាញថាមពលអគ្គិសនី ដែលជួយលើកកម្ពស់ដល់បរិស្ថានបៃតង ដូចជាផ្លូវអេយស្វ័យយាន ផ្លូវរថយន្តក្រុងដឹកអ្នកដំណើរ ផ្លូវនាវាចរណ៍ បណ្តាញខ្សែកាបអុបទិក ប្រព័ន្ធផ្កាយរណប បណ្តាញខ្សែបញ្ជូនអគ្គិសនី។

**គោលការណ៍អភិវឌ្ឍន៍បៃតង** សំដៅដល់ការអភិវឌ្ឍដែលមានលក្ខណៈបៃតង ដើម្បីធានាដល់សិទ្ធិទទួលបានពីការអភិវឌ្ឍ រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ការងារធនធានទឹកនិងអនាម័យការងារសន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការងារសេដ្ឋកិច្ចនិងវិនិយោគ ការងារគមនាគមន៍ ការងារឧស្សាហកម្មនិងថាមពល និងការងារទេសចរណ៍បៃតង។

**ថាមពលបៃតង** សំដៅដល់ប្រសិទ្ធភាពថាមពល ពិសេស ការផលិតនិងការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាថាមពលដើរដោយកម្លាំងខ្យល់ ពន្លឺព្រះអាទិត្យ កម្លាំងទឹករលក ជីវឧស្ម័ន ជីវម៉ាស់ ជីវឥន្ធនៈ និងវារីអគ្គិសនី។

**ទីផ្សារបៃតង** សំដៅដល់ទីផ្សារលក់ដូរ ផ្លាស់ប្តូរ និងធ្វើពាណិជ្ជកម្មនូវផលិតផលនិងសេវាបៃតង ដែលធានាប្រព័ន្ធសុវត្ថិភាពសង្គមវប្បធម៌ ប្រព័ន្ធសុវត្ថិភាពអេកូឡូស៊ីនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

**ទេសចរណ៍បៃតង** សំដៅដល់ការអភិវឌ្ឍទេសចរណ៍និងអ្នកទេសចរណ៍ដែលមិនបង្កការប៉ះពាល់ដល់និរន្តរភាពបរិស្ថានបៃតងនិងធនធានធម្មជាតិ ដោយរក្សាបាននូវសោភណភាព ទេសភាពធម្មជាតិបៃតង និងប្រព័ន្ធអេកូឡូស៊ី និងបានគិតគូរដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងរក្សាអត្តសញ្ញាណវប្បធម៌ដោយមានសុខដុមនីយកម្មរវាងការអភិវឌ្ឍ និងការអភិរក្ស ដើម្បីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិដ៏កម្រ ដែលត្រូវបន្សល់ទុកជូនអ្នកជំនាន់ក្រោយនូវសម្បត្តិធម្មជាតិសម្រាប់អនាគតរបស់ខ្លួន។

**ទូរគមនាគមន៍បៃតង** សំដៅដល់ការដំឡើងនិងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធតាមរយៈបច្ចេកវិទ្យាបៃតង និងប្រព័ន្ធព័ត៌មានបៃតង ដែលប្រើប្រាស់ធនធានតិចនិងបង្កើនទិន្នផលខ្ពស់ ដោយបានគិតគូរពីហានិភ័យនៃធាតុវិទ្យុសកម្មដែលនាំឲ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈនិងបរិស្ថាន។

**បណ្ណាល័យបៃតង** សំដៅដល់សំណង់អគារបៃតងដែលបំពាក់ដោយបច្ចេកវិទ្យាបៃតងសម្រាប់រក្សានិងតម្កល់ទុកឯកសារទាក់ទងនឹងការអភិវឌ្ឍបៃតង ការអភិវឌ្ឍប្រកបដោយចីរភាព សេដ្ឋកិច្ចបៃតង សេដ្ឋកិច្ចខៀវ ព័ត៌មានវិទ្យាបៃតង មនុស្សបៃតង ពិសេសអារ្យធម៌បៃតង ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗទៀត ដើម្បីប្រែក្លាយបណ្ណាល័យសម្រាប់ការអភិវឌ្ឍបៃតងគំរូក្នុងការសិក្សា ស្រាវជ្រាវ ច្នៃប្រឌិត និងបង្កើតផលិតផលនិងសេវាបៃតង ព្រមទាំងបង្កើនចំណេះដឹងអំពីការអភិវឌ្ឍបៃតង។

**បច្ចេកវិទ្យាបៃតង** សំដៅដល់ប្រព័ន្ធបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កឲ្យមានការខូចខាតដល់បរិស្ថាន ដូចជា បច្ចេកវិទ្យាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាត និងបច្ចេកវិទ្យាសម្រាប់ការកែច្នៃ និងការប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើរួច។

**បរិស្ថានបៃតង** សំដៅដល់ការអភិវឌ្ឍស្អាត ការមិនបំពុលបរិស្ថានក្នុងការថែរក្សាគុណភាពទឹក គុណភាពដី និងគុណភាពខ្យល់ សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការធានាបាននូវសុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ ធនធានទឹកជាអាទិ៍ប្រកបដោយនិរន្តរភាព ការប្រើប្រាស់ដីប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពសាធារណៈ ដែលជាកត្តាចម្បងក្នុងការលើកស្ទួយសេដ្ឋកិច្ចបៃតងឲ្យមានគុណភាពទៅនឹងចីរភាពបរិស្ថាន សង្គម និងវប្បធម៌។

**បេតិកភណ្ឌវប្បធម៌បៃតង** សំដៅដល់កេរដំណែលសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬកើតចេញពីធម្មជាតិ ឬរកឃើញនៅក្នុងទឹកដីនៃមាតុភូមិដែលជាស្នាដៃរបស់មនុស្ស និងផលិតផលរបស់ធម្មជាតិដោយមានលក្ខណៈវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា និងលក្ខណៈធម្មជាតិបៃតងដែលបង្ហាញពីការវិវត្តនៃសង្គមវប្បធម៌និងសង្គមសេដ្ឋកិច្ចរបស់ប្រទេស ផ្សារភ្ជាប់ទៅនឹងការវិវត្តនៃអភិវឌ្ឍន៍បៃតង និងអារ្យធម៌ជឿនលឿនតាមបែបធម្មជាតិ ហើយសម្បត្តិវប្បធម៌បៃតងជាតិទាំងឡាយបម្រើផលប្រយោជន៍ជូនប្រជាជននិងប្រទេសជាតិទាំងមូល។

**បេតិកភណ្ឌវប្បធម៌អរូបីបៃតង** សំដៅការប្រតិបត្តិ ការសម្តែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍វត្ថុ ដែលមានប្រភពសិប្បនិម្មិត លម្អបៃតង និងពិធិធភាវូនីយកម្មវប្បធម៌ ទទួលស្គាល់ និងទទួលយកក្នុងសង្គម ដោយត្រូវបានបន្តវេនពីជំនាន់មួយទៅជំនាន់មួយ ហើយត្រូវបានបង្កើតថ្មីឡើងវិញជាអចិន្ត្រៃយ៍នៅតាមសហគមន៍និងក្រុមមនុស្សផ្អែកទៅតាមកន្លែង ដែលបង្កើនសុខដុមនីយកម្មរបស់មនុស្សជាមួយនឹងធម្មជាតិ ព្រមទាំងជាមួយនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់និងអក្សរសាស្ត្ររបស់ពួកគេ ហើយបានផ្តេរនូវមនោសញ្ចេតនានៃអត្តសញ្ញាណនិងនិរន្តរភាព សម្រាប់រួមចំណែកក្នុងការជំរុញឲ្យមានការគោរពវប្បធម៌ប្លែកៗគ្នានិងភាពចេះបង្កើតថ្មីរបស់មនុស្ស។

**ផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព** សំដៅដល់ប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិដើម្បីបំពេញសេចក្តីត្រូវការផលិតនិងប្រើប្រាស់ក្នុងសេដ្ឋកិច្ច សង្គម ដែលបន្តរក្សានិរន្តរភាពធនធានធម្មជាតិ រួមមាន សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការបញ្ចេញសំណល់តិច កាត់បន្ថយការបំពុល ការប្រើប្រាស់និងកែច្នៃឡើងវិញសម្រាប់តម្រូវការនាពេលបច្ចុប្បន្ននិងជំនាន់ក្រោយ។

**ពន្ធបៃតង** សំដៅដល់ពន្ធកាត់បន្ថយការបំពុលបរិស្ថាន ពន្ធបញ្ចេញសំណល់រឹងនិងរាវ ពន្ធប្រើប្រាស់ធនធានធម្មជាតិ ដែលកើតចេញពីសកម្មភាពអភិវឌ្ឍន៍ដែលបំពុលនិងបង្កគ្រោះថ្នាក់ដល់បរិស្ថាន រួមជាមួយការធ្វើអាជីវកម្មនិងការប្រើប្រាស់ធនធានធម្មជាតិ។ ការយកពន្ធបៃតងគឺដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពបរិស្ថាន។

**ពាណិជ្ជកម្មបៃតង** សំដៅដល់ការនាំចេញ នាំចូលនូវផលិតផលកសិកម្មបៃតង ឧស្សាហកម្មបៃតង និងសេវាកម្មបៃតង ដែលមិនបង្កការខូចខាតដល់បរិស្ថាននិងសង្គម។

**មនុស្សបៃតង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានការយល់ដឹង ចំណេះដឹង បទពិសោធ និងជំនាញវិជ្ជាជីវៈលើការអភិវឌ្ឍបៃតង ដោយចូលរួមយ៉ាងសកម្មក្នុងការធ្វើឲ្យមានសុខដុមនីយកម្មរវាងបង្គោលគ្រឹះទាំង៤ គឺសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ហើយក្លាយជាជនបង្គោលបៃតងគំរូដែលមាន មនសិការស្រឡាញ់ធម្មជាតិ ព្រមទាំងការពារនិងថែរក្សាភពផែនដីឲ្យមាននិរន្តរភាព។

**ព័ត៌មានវិទ្យាបៃតង** សំដៅដល់ទិន្នន័យនិងព័ត៌មានទាក់ទងនឹងអភិវឌ្ឍន៍បៃតង សេដ្ឋកិច្ចបៃតង សេដ្ឋកិច្ចខៀវ ធនធានធម្មជាតិ ស្ថានភាពបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី សង្គមវប្បធម៌បៃតង និងបច្ចេកវិទ្យាបៃតងដែលត្រូវបានផ្លាស់ប្តូរតាមមធ្យោបាយប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយ មានជាអាទិ៍ វិទ្យុ ទូរទស្សន៍ អ៊ីនធឺណិត ទូរគមនាគមន៍បៃតង ប្រព័ន្ធផ្កាយរណប បណ្តាញខ្សែកាបអុបទិក។

**លទ្ធកម្មបៃតង** សំដៅដល់ដំណើរការនិងនីតិវិធីនៃការទិញវត្ថុធាតុដើមនិងផលិតផលបៃតងទាំងឡាយប្រកបដោយគុណភាពដែលធានាសុវត្ថិភាពអេកូឡូស៊ី តាមរយៈការប្រើប្រាស់ឲ្យចំទិសដៅ តម្លាភាព គណនេយ្យភាព និងកាលានុវត្តភាពតាមគោលការណ៍អភិវឌ្ឍន៍បៃតង។

**លម្ហបៃតង** សំដៅដល់ទីកន្លែងនិងលម្ហដែលរក្សាបាននូវសោភណភាពបៃតងនិងសុខភាពបរិស្ថានតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង អគារបៃតង ការសន្សំសំចៃថាមពលនិងទឹក និងការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព។

**វប្បធម៌បៃតង** សំដៅដល់ការរក្សា ការពារ អភិរក្ស ទំនើបកម្ម និងសមាហរណកម្មនូវវប្បធម៌បេតិកភណ្ឌបេតិកភណ្ឌវប្បធម៌អរូបី និងវប្បធម៌សង្គមបៃតង តាមរយៈពិពិធភាវូបនីយកម្មវប្បធម៌ និងការផ្លាស់ប្តូរវប្បធម៌សាសនា ប្រពៃណី ទំនៀមទម្លាប់រស់នៅ ទេសចរណ៍ កីឡា អប់រំ របកគំហើញថ្មី និងបច្ចេកវិទ្យាបៃតង ដែលរក្សានិងលើកតម្កើងកិត្យានុភាពជាតិនិងអត្តសញ្ញាណជាតិ ស្របតាមគោលការណ៍និងវឌ្ឍនភាពបៃតងដែលសម្រេចបានក្នុងវិស័យកសិកម្មបៃតង ពាណិជ្ជកម្មបៃតង ឧស្សាហកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង សំណង់អគារបៃតង ឧបករណ៍ហិរញ្ញវត្ថុបៃតង វិនិយោគបៃតង និងទីផ្សារហិរញ្ញវត្ថុបៃតង។

**វិទ្យាស្ថានបៃតង** សំដៅដល់គ្រឹះស្ថានស្រាវជ្រាវនិងអប់រំដែលសាងសង់ឡើងដោយសំណង់អគារបៃតងនិងបំពាក់ដោយបច្ចេកវិទ្យាបៃតង សម្រាប់ជាថ្នាលបណ្តុះបណ្តាល សិក្សា ស្រាវជ្រាវ និងវិភាគទិន្នន័យព្រមទាំងព័ត៌មាននានាទាក់ទងនឹងការអភិវឌ្ឍបៃតង ការអភិវឌ្ឍប្រកបដោយចីរភាព សេដ្ឋកិច្ចបៃតង សេដ្ឋកិច្ចខៀវ ព័ត៌មានវិទ្យា បៃតង មនុស្សបៃតង ពិសេសអារ្យធម៌បៃតង ព្រមទាំងផ្លាស់ប្តូរបទពិសោធចំណេះដឹង របកគំហើញ

ពីការសិក្សា ស្រាវជ្រាវ ដើម្បីបណ្តុះមនសិការបៃតងក្នុងជំនាន់បច្ចុប្បន្ននិងជំនាន់ក្រោយៗ ដែលធ្វើឲ្យប្រទេសមានការ អភិវឌ្ឍលើគ្រប់វិស័យ រហូតដល់សម្រេចបាននូវអារ្យធម៌បៃតង។

**វិនិយោគបៃតង** សំដៅដល់គម្រោងឬសកម្មភាពវិនិយោគលើការអភិវឌ្ឍបៃតងដែលផ្តោតលើបច្ចេកវិទ្យាបៃតង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បរិស្ថានបៃតងនិងធនធានធម្មជាតិ ធនធានទឹកនិងអនាម័យ សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព គមនាគមន៍ ឧស្សាហកម្មនិងថាមពល និងទេសចរណ៍ បៃតង។

**សេដ្ឋកិច្ចបៃតង** សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យា បៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតង ដូចជាពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទានបៃតង និងមីក្រូហិរញ្ញវត្ថុបៃតងជាដើម។

**សេដ្ឋកិច្ចខៀវ** សំដៅដល់សកម្មភាពសេដ្ឋកិច្ចដែលកើតចេញពីការអភិវឌ្ឍតំបន់សមុទ្រតាមគោលការណ៍អភិវឌ្ឍន៍បៃតង។

**សេវាកម្មបៃតង** សំដៅដល់ការផ្តល់សេវាទាំងផ្នែកសាធារណៈ ទាំងផ្នែកឯកជន មានជាអាទិ៍ការចែកចាយទំនិញ ការលក់ដូរទំនិញ ការដឹកជញ្ជូនទំនិញ ការគ្រប់គ្រងសហគ្រាស ការផ្តល់ប្រឹក្សាយោបល់ អគ្រាការប្រាក់ និងគំនិតច្នៃប្រឌិតដែលធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ចដើរទន្ទឹមនឹងការអភិវឌ្ឍបៃតង។

**សំណង់អគារបៃតង** សំដៅដល់សំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមានជាអាទិ៍ សំណង់អគារ កន្លែងធ្វើការ កន្លែងស្នាក់នៅ កន្លែងកម្សាន្ត មន្ទីរពេទ្យ សាលារៀន និងទីសាធារណៈដទៃទៀត ដែលត្រូវបំពាក់ដោយបច្ចេកវិទ្យាបៃតង និងប្រើប្រាស់បច្ចេកទេសបៃតងក្នុងការបង្កើនសោភណភាពបៃតង ជាសុកភាព និងគុណ ភាពជីវិត និងសុខដុមនីយកម្មរបស់មនុស្សជាមួយធម្មជាតិ។

**ហិរញ្ញវត្ថុបៃតង** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុ ដូចជាមូលប្បទានបត្រ ភាគហ៊ុន បណ្ណបំណុលជាតិ បណ្ណបំណុលក្រុមហ៊ុន បណ្ណរតនាគារ ទ្រព្យសកម្ម តម្លៃអចលនវត្ថុ ឥណទាន និងធានារ៉ាប់រង ព្រមទាំង ទីផ្សារហិរញ្ញវត្ថុ ដែលលើកកម្ពស់ការទិញដូរផលិតផលបៃតង និងសេវាកម្មបៃតង លើកទឹកចិត្តដល់ ការវិនិយោគលើវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវ និងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផល និងសេវាកម្មបៃតង ព្រមទាំង លទ្ធកម្មហិរញ្ញវត្ថុបៃតង។

**អភិវឌ្ឍន៍ប្រកបដោយចីរភាព** សំដៅដល់ការអភិវឌ្ឍដែលនាំមកនូវការរីកចម្រើនសេដ្ឋកិច្ចសង្គប្រកបដោយចីរភាពបរិស្ថាន ដោយផ្អែកលើតុល្យភាពនៃបង្គោលគ្រឹះ៤ គឺ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។

**អភិវឌ្ឍន៍បៃតង** សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពដែលមិនបង្កការខូចខាតដល់បរិស្ថាន ដោយផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិតិចដែលទទួលបានទិន្នផលខ្ពស់ ប្រសិទ្ធភាពថាមពល ការបញ្ចេញ

សំណល់តិច ការអភិវឌ្ឍស្អាត ការថែរក្សាភាពបៃតង និងបេតិកភណ្ឌធម្មជាតិ ព្រមទាំងការបង្កើនជីវភាពរស់នៅរបស់ប្រជាជន ដើម្បីសម្រេចបាននូវតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងនិរន្តរភាពបរិស្ថានដែលជាឧត្តមប្រយោជន៍ដល់សង្គមទាំងមូល។

**វប្បធម៌បៃតង** សំដៅដល់ការយល់ដឹងអំពីការអភិវឌ្ឍបៃតងនិងវឌ្ឍនភាពអភិវឌ្ឍបៃតង ដែលលើកតម្កើង និងថែរក្សាទំនៀមទម្លាប់ វប្បធម៌ប្រពៃណី និងអត្តសញ្ញាណជាតិ ដោយមានកំណើនសេដ្ឋកិច្ចបៃតង និងមានភាពរុងរឿងក្នុងសង្គមសេដ្ឋកិច្ច ឈរលើគោលការណ៍អភិវឌ្ឍបៃតង មានជាអាទិ៍ ១- ការប្រើប្រាស់វត្ថុធាតុដើម និងធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព ២- បច្ចេកវិទ្យាបៃតងរួមជាមួយបច្ចេកទេសកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ៣- គុណភាពបរិស្ថានសំដៅយកគុណភាពផលិតផល សេវាកម្មដែលគ្មានការបំពុលបរិស្ថាន ដូចជា ទឹក ដី ខ្យល់ ព្រៃឈើ ជលផល ជីវៈចម្រុះ ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ៤- ការបញ្ចេញសំណល់តិច ៥- ថាមពលកកើតឡើងវិញនិងប្រសិទ្ធភាពថាមពល ដែលធ្វើឲ្យកាន់តែមានប្រសិទ្ធភាពដល់ការផលិតនិងការប្រើប្រាស់ថាមពលដោយចំណាយតិច ផ្អែកលើទំនើបកម្មបច្ចេកទេសនិងបច្ចេកវិទ្យាបៃតង ៦- ការប្រើប្រាស់ទឹកនិងថាមពលដោយសន្សំសំចៃ ៧- មីក្រូនិងម៉ាក្រូហិរញ្ញវត្ថុបៃតង ដូចជាឥណទានកម្ចីថវិកាបៃតងដែលជួយការពារបរិស្ថាន និងថែរក្សាប្រព័ន្ធអេកូឡូស៊ីឲ្យមានសុវត្ថិភាព ៨- ការអភិវឌ្ឍសេដ្ឋកិច្ចដោយបញ្ចេញកាបូនតិច សំដៅបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងធន់ទ្រាំទៅនឹងអាកាសធាតុ ៩- ពន្ធបៃតងមានជាអាទិ៍ពន្ធកាត់បន្ថយការបំពុលបរិស្ថាន ពន្ធបញ្ចេញសំណល់រឹងនិងរាវ និងពន្ធប្រើប្រាស់ធនធានធម្មជាតិ។

**ឧស្សាហកម្មបៃតង** សំដៅដល់ផលិតកម្មស្អាតដែលប្រើប្រាស់បច្ចេកវិទ្យាបៃតង ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងខ្សែចង្វាក់ផលិតកម្មនៃសហគ្រាសធុនតូច មធ្យម និងធំ ដើម្បីធានាដល់និរន្តរភាពធនធានធម្មជាតិដោយអនុវត្តគោលការណ៍ផលិតកម្ម និងការប្រើប្រាស់ប្រកបដោយចីរភាព។

# សេចក្តីថ្លែងអំណរគុណ

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន និងជាប្រធាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង** ដែលបានដឹកនាំ និងផ្តល់ការណែនាំដល់ក្រុមការងារដើម្បីរៀបចំ គោលនយោបាយជាតិស្តីពីកាអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ប្រកបដោយជោគជ័យ។

សូមគោរពជូនពរ **ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង** សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំប្បីឃ្លាងឃ្លាតឡើយ។

## ក្រុមការងាររៀបចំ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០

| | |
|---|---|
| ១.ឯកឧត្តម **ខុង សំនួន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន |
| ២.ឯកឧត្តមបណ្ឌិត **ឈុន វណ្ណៈ** | អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ទីប្រឹក្សាផ្ទាល់**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងបរិស្ថាន និងសាស្ត្រាចារ្យ |
| ៣.ឯកឧត្តម **ហេង តារិទ្ធ** | ទីប្រឹក្សាក្រសួងបរិស្ថាននិងជាអគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ |
| ៤.ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស្វាយ ចាន់ដា** | អនុប្រធានបណ្ឌិតសភានគរបាលកម្ពុជានៃក្រសួងមហាផ្ទៃ |
| ៥.ឯកឧត្តម **ផៃ សុខេង** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិកក្រុមប្រឹក្សាភាសាខ្មែរ និងសមាជិកគណៈកម្មការបណ្ឌិតសភាអនុម័តពាក្យច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ៦.ឯកឧត្តម **ដាញ់ សេរី** | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ៧.លោកស្រីបណ្ឌិត **ខួន សុខា** | អគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជា |
| ៨.លោកបណ្ឌិត **តាំង សុខុទ្ធី** | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៩.លោក **ទន់ វណ្ណារិទ្ធ** | ទទួលបន្ទុកជាប្រធានផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| ១០.លោក **កៀង កេសរ បវរ ករុណា** | ប្រធានការិយាល័យគណនេយ្យ និងសហប្រតិបត្តិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |

រួមទាំងការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងការផ្លាស់ប្តូរបទពិសោធន៍ជាមួយក្រុមជំនាញ អង្គការ GGGI អង្គការ OECD អង្គការ UNESCAP និង UNEP ។